ICRtoP

INTERNATIONAL COALITION FOR **THE RESPONSIBILITY TO PROTECT** |
សម្ព័ន្ធភាពអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ

# បណ្តុំឧបករណ៍ស្តីពីទំនួលខុសត្រូវក្នុងការការពារ



រូបថតគម្របៈ អ្នករក្សាសន្តិភាពអង្គការសហប្រជាជាតិនិយាយជាមួយនឹងស្ត្រីភៀសខ្លួននៅក្នុងប្រទេសឆាត។
ប្រភពៈ រូបថតរបស់អង្គការសហប្រជាជាតិ ដោយ Olivia Grey Pritchard។

## តើអ្វីទៅជាគោលបំណងនៃបណ្តុំឧបករណ៍នេះ?

១. ជួយបង្កើនការយល់ដឹង និងការស្វែងយល់អំពីបទដ្ឋាននៃទំនួលខុសត្រូវក្នុងការការពារ ("RtoP" ឬ "R២P")។

២. គាំទ្រកិច្ចប្រឹងប្រែង ដើម្បីពង្រឹងសមត្ថភាពថ្នាក់ជាតិ និងតំបន់ក្នុងគោលបំណងបង្ការ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការលុបបំបាត់ជាតិសាសន៍។

## តើបណ្តុំឧបករណ៍នេះគួរត្រូវបានប្រើយ៉ាងដូចម្តេច?

នៅក្នុងបណ្តុំឧបករណ៍នេះ អ្នកនឹងឃើញផ្នែកចំនួនបី៖

១. ទិដ្ឋភាពទូទៅលម្អិតអំពីប្រភព និងការអភិវឌ្ឍន៍ទំនួលខុសត្រូវក្នុងការការពារ។
២. ទិដ្ឋភាពទូទៅនៃតួនាទីរបស់ភាគីពាក់ព័ន្ធនានានៅក្នុងការអភិវឌ្ឍន៍ និងលើកស្ទួយទំនួលខុសត្រូវក្នុងការការពារ (RtoP)។
៣. ធនធានបន្ថែមអំពីបទដ្ឋាន។

ផ្នែកទីមួយ និងទីបី គឺជាមូលដ្ឋានគ្រឹះសម្រាប់សិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលទាំងអស់ ដើម្បីលើកកម្ពស់ការយល់ដឹង និងជម្រុញការស្វែងយល់អំពីទំនួលខុសត្រូវក្នុងការការពារ (RtoP) ដោយធនធានបន្ថែមត្រូវបានបញ្ចូលនៅក្នុងផ្នែកទីបីតាមការសមស្រប។ ផ្នែកទីពីរអាចត្រូវបានកែសម្រួលតាមតម្រូវការរបស់អ្នកសម្របសម្រួលសិក្ខាសិលាផ្តល់ឲ្យអ្នកចូលរួម។

## តើអ្នកណាគួរប្រើប្រាស់បណ្តុំឧបករណ៍នេះ?

បណ្តុំឧបករណ៍នេះ ត្រូវបានផ្តោតជាចម្បងលើតួអង្គសង្គមស៊ីវិលនានាដែលមានបំណងលើកកម្ពស់ការយល់ដឹងអំពីទំនួលខុសត្រូវក្នុងការការពារ (RtoP) ក្នុងចំណោមអង្គការសង្គមស៊ីវិល (CSOs) បញ្ញវ័ន្ត ប្រព័ន្ធផ្សព្វផ្សាយ មន្ត្រីការទូត មន្ត្រីវិស័យសន្តិសុខ និងភាគីពាក់ព័ន្ធផ្សេងទៀត។ យើងក៏លើកទឹកចិត្តឲ្យមានការប្រើប្រាស់ផ្នែកនានានៃបណ្តុំឧបករណ៍នេះ ដោយរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ តំណាងរាស្ត្រ បញ្ញវ័ន្ត អ្នកដឹកនាំសាសនា និងក្រុមហ៊ុននានាផងដែរ។

# មាតិកា


## ផ្នែកទី ១៖ ការស្វែងយល់អំពីទំនួលខុសត្រូវក្នុងការការពារ

តើទំនួលខុសត្រូវក្នុងការការពារ គឺជាអ្វី?

ហេតុអ្វីបានជាទំនួលខុសត្រូវក្នុងការការពារ (RtoP) មានភាពចាំបាច់?

តើទំនួលខុសត្រូវក្នុងការការពារ (RtoP) អភិវឌ្ឍយ៉ាងដូចម្តេច?

វិសាលភាពនៃទំនួលខុសត្រូវក្នុងការការពារ (RtoP) ៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការលុបបំបាត់ជាតិសាសន៍

តើទំនួលខុសត្រូវក្នុងការការពារ (RtoP) មានវឌ្ឍនភាពយ៉ាងដូចម្តេចនៅអង្គការសហប្រជាជាតិ?

តើគេអាចចាត់វិធានការអ្វីខ្លះ ដើម្បីបង្ការ និងបញ្ឈប់អំពើឃោរឃៅទ្រង់ទ្រាយធំ?

ទំនួលខុសត្រូវក្នុងការការពារ (RtoP) នៅក្នុងស្ថានភាពវិបត្តិ

ការយល់ខុសទូទៅអំពីទំនួលខុសត្រូវក្នុងការការពារ (RtoP)

ទំនួលខុសត្រូវក្នុងការការពារ (RtoP) និងរបៀបវារៈអន្តរជាតិផ្សេងទៀត

## ផ្នែកទី ២៖ ការអភិវឌ្ឍន៍ទំនួលខុសត្រូវក្នុងការការពារ (RtoP) ៖ តួនាទីរបស់តួអង្គថ្នាក់ជាតិ និងតំបន់

អង្គការសង្គមស៊ីវិល

បញ្ញាវន្ត

ប្រព័ន្ធផ្សព្វផ្សាយ

មន្ត្រីរដ្ឋាភិបាល

តំណាងរាស្ត្រ

ការរៀបចំថ្នាក់តំបន់ និងថ្នាក់អនុតំបន់

## ផ្នែកទី ៣៖ សម្រាប់ព័ត៌មានបន្ថែមអំពីទំនួលខុសត្រូវក្នុងការការពារ

ឯកសារស្នូល

ធនធានបន្ថែម និងអង្គការសង្គមស៊ីវិល

អំពីសម្ព័ន្ធភាពអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ (ICRtop)

សេចក្តីថ្លែងអំណរគុណ

# ផ្នែកទី ១៖

# ការស្វែងយល់អំពី

# ទំនួលខុសត្រូវក្នុងការការពារ

# តើទំនួលខុសត្រូវក្នុងការការពារ គឺជាអ្វី?

ទំនួលខុសត្រូវក្នុងការការពារ ("RtoP ឬ R២P") គឺជាបទដ្ឋានថ្មីមួយ ដើម្បីទប់ស្កាត់ និងបញ្ឈប់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការលុបបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទំនួលខុសត្រូវក្នុងការការពារមិនមែនជាច្បាប់ទេ ប៉ុន្តែ គឺជាការប្តេជ្ញាចិត្តផ្នែកនយោបាយ ដើម្បីណែនាំរដ្ឋនានា និងការរៀបចំថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិក្នុងការការពារប្រជាជនពីឧក្រិដ្ឋកម្ម និងការរំលោភបំពានទាំងនេះ។

ទំនួលខុសត្រូវក្នុងការការពារចែងថា៖

១. រដ្ឋមានទំនួលខុសត្រូវចម្បងក្នុងការការពារប្រជាជនរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការលុបបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទំនួលខុសត្រូវនេះ រួមមាន ការទប់ស្កាត់ឧក្រិដ្ឋកម្ម និងការរំលោភបំពានទាំងនេះ ព្រមទាំងការញុះញង់ផងដែរ។

២. សហគមន៍អន្តរជាតិមានទំនួលខុសត្រូវក្នុងការជួយ និងលើកទឹកចិត្តរដ្ឋ ដើម្បីបំពេញកាតព្វកិច្ចការពាររបស់ខ្លួន។

៣. សហគមន៍អន្តរជាតិមានទំនួលខុសត្រូវក្នុងការចាត់វិធានការសមស្របផ្នែកការទូត មនុស្សធម៌ និងវិធានការសន្តិភាពផ្សេងទៀត ដើម្បីជួយការពារប្រជាជនពីឧក្រិដ្ឋកម្មទាំងនេះ។ សហគមន៍អន្តរជាតិក៏ត្រូវត្រៀមខ្លួនផងដែរ ក្នុងការចាត់វិធានការរួមឲ្យបានទាន់ពេលវេលា និងម៉ឺងម៉ាត់ ស្របតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ផ្អែកតាមករណីនីមួយៗ និងដោយសហប្រតិបត្តិការជាមួយអង្គការពាក់ព័ន្ធក្នុងតំបន់ ប្រសិនបើរដ្ឋណាខកខានមិនបានការពារប្រជាជនរបស់ខ្លួន រដ្ឋនោះ គឺជាអ្នកប្រព្រឹត្តអំពើឧក្រិដ្ឋតែម្តង។ យន្តការនេះរួមមានវិធានការបង្ខិតបង្ខំឲ្យប្រើប្រាស់កម្លាំងរួមគ្នា ប្រសិនបើសមស្រប តាមរយៈក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ។

## ហេតុអ្វីបានជាទំនួលខុសត្រូវក្នុងការការពារមានភាពចាំបាច់?

ហាយនភាព និងអំពើប្រល័យពូជសាសន៍កន្លងមកនៅក្នុងប្រទេសកម្ពុជា និងរ៉្វាន់ដា ក៏ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងអតីតប្រទេសយូហ្គោស្លាវី ទីម័រខាងកើត និងដាហ្វួរបានបង្ហាញនូវបរាជ័យដ៏ធំរបស់សហគមន៍អន្តរជាតិ ក្នុងការទប់ស្កាត់អំពើឃោរឃៅ។ ករណីនៃទុក្ខវេទនាដែលមិនអាចពណ៌នាបានទាំងនេះ និងការបាត់បង់ជីវិតរាប់លាននាក់បានផ្តល់នូវកម្លាំងជំរុញឲ្យមានការអំពាវនាវ "កុំឲ្យអំពើឃោរឃៅកើតមានឡើងជាថ្មីម្តងទៀត!"។



ចំណាងជើង៖ ជនភៀសខ្លួន Kosovar ដែលរត់គេចពីមាតុប្រទេសក្នុងឆ្នាំ១៩៩៩។ ប្រភព៖ រូបថតរបស់អង្គការសហប្រជាជាតិ និងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ដោយ R LeMoyne។

ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ទាំងមូល ភាពចម្រូងចម្រាសបានកើតឡើងរវាងបុគ្គលដែលគាំទ្រសិទ្ធិក្នុងការធ្វើអន្តរាគមន៍ ដើម្បីការពារប្រជាជន (អន្តរាគមន៍មនុស្សធម៌) និងបុគ្គលដែលផ្តល់ទឡ្ហីករណ៍ថា អធិបតេយ្យភាពរបស់រដ្ឋ ដែលទទួលស្គាល់ដោយធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ រារាំងអន្តរាគមន៍ណាមួយនៅក្នុងបញ្ហាផ្ទៃក្នុង។ នៅក្នុងប្រទេសរ៉្វាន់ដា សហគមន៍អន្តរជាតិបរាជ័យក្នុងការចាត់វិធានការ ដើម្បីការពារប្រជាជនពីឧក្រិដ្ឋកម្មសម្លាប់រង្គាល។ ប៉ុន្តែ នៅក្នុងករណីនៃកូសូវ៉ូ អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង (ណាតូ) បានអនុវត្តប្រតិបត្តិការយោធា ដើម្បីបញ្ឈប់មហន្តរាយមនុស្សជាតិ ដោយមិនចាំបាច់មានការអនុញ្ញាតពីក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិឡើយ។ ប្រតិកម្មផ្សេងគ្នាទាំងនេះ ដោយពាក់ព័ន្ធនឹងអាយុជីវិតរបស់ជនស៊ីវិល បានបង្ហាញនូវតម្រូវការជាបន្ទាន់ នូវការព្រមព្រៀងមតិជារួមជាអន្តរជាតិអំពីពេលវេលា ហើយនិងរបៀបចាត់វិធានការ ដើម្បីទប់ស្កាត់ និងបញ្ឈប់អំពើសម្លាប់រង្គាល និងនាំទៅរកការស្វែងយល់ជាថ្មីថា សន្តិសុខរបស់សហគមន៍ និងបុគ្គល មិនត្រឹមតែរដ្ឋប៉ុណ្ណោះទេ ត្រូវតែជាអាទិភាពបន្ទាន់សម្រាប់គោលនយោបាយជាតិ និងអន្តរជាតិ។ ដោយទទួលស្គាល់បញ្ហានេះ បន្ទាប់មកអគ្គលេខាធិការអង្គការសហប្រជាជាតិ គឺលោក កូហ្វី អាណាន់ នៅក្នុងសុន្ទរកថារបស់គាត់ទៅកាន់មហាសន្និបាតក្នុងឆ្នាំ១៩៩៩ និងឆ្នាំ២០០០ បានជំរុញឲ្យរដ្ឋជាសមាជិកធ្វើការកែសម្រួលគោលការណ៍ ស្តីពីអធិបតេយ្យភាពរបស់រដ្ឋ និងទំនួលខុសត្រូវរបស់សហគមន៍អន្តរជាតិ ដើម្បីការពារប្រជាជនពីការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។

ឯកសារបង្ហាញអំពីកុមារនៅក្នុងអំឡុងហាយនភាព នៅទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិ។ ប្រភព៖ រូបថតរបស់អង្គការសហប្រជាជាតិ ដោយ JC McIlwaine។



## សហភាពអាហ្វ្រិកផ្លាស់ប្តូរពីគោលនយោបាយមិនជ្រៀតជ្រែកទៅគោលនយោបាយមិនព្រងើយកន្តើយ

ក្នុងឆ្នាំ២០០០ ប្រជាជាតិអាហ្វ្រិកបានបង្កើតសហភាពអាហ្វ្រិក (AU) ហើយភ្លាមៗនោះ បានបង្កើតគោលការណ៍ ដែលក្រោយមក ត្រូវបានអះអាងឡើងវិញនៅក្នុងទំនួលខុសត្រូវក្នុងការការពារនៅក្នុងឯកសារបង្កើតសហភាពអាហ្វ្រិក (AU) គឺច្បាប់ធម្មនុញ្ញ។ គោលការណ៍ទាំងឡាយដែលចែងនៅក្នុងច្បាប់នេះ តំណាងឲ្យការផ្លាស់ប្តូរដ៏ធំមួយពី "ការមិនជ្រៀតជ្រែក" នៅក្នុងកិច្ចការរបស់រដ្ឋ ដែលជាគោលនយោបាយមួយ ដែលត្រូវបានរក្សាទុកដោយបុព្វការីរបស់សហភាពអាហ្វ្រិក (AU) គឺអង្គការឯកភាពអាហ្វ្រិកទៅជា "ការមិនព្រងើយកន្តើយ"។

ការសង្កត់ធ្ងន់របស់សហភាពអាហ្វ្រិក (AU) លើការធានាថា ការការពារប្រជាជនជាទំនួលខុសត្រូវរួមគ្នា អាចត្រូវបានមើលឃើញនៅក្នុងប្រការនានាដូចខាងក្រោមនៃច្បាប់ធម្មនុញ្ញ៖

- ប្រការ ៣(b) ចែងថា វត្ថុបំណងស្នូលនៃសហភាពអាហ្វ្រិក (AU) គឺ "ការពារអធិបតេយ្យភាព បូរណភាពដែនដី និងឯករាជ្យភាពនៃរដ្ឋជាសមាជិករបស់ខ្លួន"។
- ប្រការ ៤(h) ចែងថា "សហភាពមានសិទ្ធិជ្រៀតជ្រែកនៅក្នុងរដ្ឋសមាជិកមួយ (MS) អនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាតទាក់ទង នឹងស្ថានភាពធ្ងន់ធ្ងរ ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"។
- ប្រការ ៤(j) បញ្ជាក់ថា រដ្ឋជាសមាជិកមានសិទ្ធិស្នើសុំអន្តរាគមន៍ពីសហភាព ដើម្បីស្តារសន្តិភាព និងសន្តិសុខ។

ជាងនេះទៅទៀតសហភាពអាហ្វ្រិក (AU) មិនតម្រូវឲ្យមានការឯកភាពពីរដ្ឋ ដើម្បីធ្វើអន្តរាគមន៍នៅក្នុងស្ថានភាពនានា ដែលប្រជាជនស្ថិតក្នុងហានិភ័យឡើយ។ ផ្ទុយទៅវិញ អង្គការឯកភាពអាហ្វ្រិកបានប្រតិបត្តិការផ្អែកលើការព្រមព្រៀងមតិជារួម។ ជាការសំខាន់ និងស្របតាមគោលការណ៍ទំនួលខុសត្រូវក្នុងការការពារ (RtoP) សហភាពអាហ្វ្រិក (AU) ចាត់ទុកថា អន្តរាគមន៍យោធាដោយមិនចាំបាច់មានការឯកភាពពីរដ្ឋ ត្រូវតែជាជម្រើសចុងក្រោយ បន្ទាប់ពីវិធានការសន្តិភាពមួយចំនួនត្រូវបានប្រើប្រាស់រួចរាល់អស់ហើយ។




ជំនួបកំពូលរបស់សហភាពអាហ្វ្រិក (AU) នៅហ្គាំបៀរ។ ប្រភព៖ រូបថតរបស់អង្គការសហប្រជាជាតិ ដោយ Mark Garten។

## របាយការណ៍គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) បង្កើតពាក្យ "ទំនួលខុសត្រូវក្នុងការការពារ"

ក្នុងឆ្នាំ២០០១ រដ្ឋាភិបាលនៃប្រទេសកាណាដាបានព្យាយាមឆ្លើយតបទៅនឹងសំណួររបស់លោក កូហ្វី អាណាន់ និងបានបង្កើតអ្នកជំនាញអន្តរជាតិមួយក្រុម គឺគណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS)។ ក្រោយពីការពិគ្រោះយោបល់មួយចំនួនក្នុងចំណោម រដ្ឋាភិបាលនានា អង្គការមិនមែនរដ្ឋាភិបាល (NGOs) អង្គការអន្តររដ្ឋាភិបាល សាកលវិទ្យាល័យ និង គណៈកម្មាធិការស្រាវជ្រាវ និងពិគ្រោះយោបល់ គណៈកម្មការនេះបានចេញរបាយការណ៍របស់ខ្លួន ដែល មានចំណងជើងថា *ទំនួលខុសត្រូវក្នុងការការពារ* ក្នុងខែធ្នូ ឆ្នាំ២០០១។

ផ្អែកលើការងាររបស់បណ្ឌិត Francis Deng និងសហសេវិករបស់គាត់នៅវិទ្យាស្ថាន Brookings ស្តីពី ទស្សនៈទាននៃ*អធិបតេយ្យភាពជាទំនួលខុសត្រូវ* គណៈកម្មការនេះបានស្រាយចម្ងល់អំពីពេលណាដែល អធិបតេយ្យភាពរបស់រដ្ឋ - គោលការណ៍ជាមូលដ្ឋាននៃច្បាប់អន្តរជាតិ - ត្រូវតែផ្តល់អាទិភាពដល់ការ ការពារប្រឆាំងនឹងការរំលោភបំពានធ្ងន់ធ្ងរបំផុតលើច្បាប់មនុស្សធម៌ និងអន្តរជាតិ រួមទាំងអំពើប្រល័យពូជ សាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការលប់បំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

របាយការណ៍នេះបានផ្តល់អាទិភាព ដល់ការការពារប្រជាជនដែលស្ថិតក្នុងហានិភ័យនៃអំពើព្រៃផ្សៃ ដោយផ្លាស់ប្តូរពី*សិទ្ធិ*របស់រដ្ឋដែលធ្វើអន្តរាគមន៍ទៅជា*ទំនួលខុសត្រូវ*របស់រដ្ឋក្នុងការការពារប្រជាជន។ របាយការណ៍នេះចែងថា ប្រសិនបើរដ្ឋមួយត្រូវបានចាត់ទុកថាមានអធិបតេយ្យភាព រដ្ឋនោះត្រូវតែទទួល ស្គាល់កាតព្វកិច្ចផ្ទៃក្នុងរបស់ខ្លួនជាចម្បង គឺការការពារពលរដ្ឋរបស់ខ្លួន និងចាត់ទុកអធិបតេយ្យភាពមិន មែនជាយន្តការនៃការត្រួតពិនិត្យនោះទេ ប៉ុន្តែ ជាបន្ទុកនៃទំនួលខុសត្រូវ។

របាយការណ៍នេះក៏បានបញ្ជាក់ផងដែរថា ប្រសិនបើរដ្ឋពាក់ព័ន្ធមិនអាច ឬមិនមានចេតនាក្នុងការការពារ ពលរដ្ឋរបស់ខ្លួនទេនោះ មានទំនួលខុសត្រូវជាអន្តរជាតិមួយ ក្នុងការការពារជនស៊ីវិលទាំងនេះ។ សហគមន៍អន្តរជាតិ មិនគួរត្រឹមតែព្យាយាមបញ្ឈប់អំពើឃោរឃៅដែលកំពុងបន្តប៉ុណ្ណោះទេ ប៉ុន្តែ សហគមន៍អន្តរជាតិ ក៏ត្រូវតែមានគោលបំណងទប់ស្កាត់អំពើឧក្រិដ្ឋកុំឲ្យកើតឡើងម្តងទៀត ទោះជានៅ កន្លែងណាក៏ដោយផងដែរ។ ដើម្បីសម្រេចគោលដៅនេះ គណៈកម្មការបានអំពាវនាវឲ្យមានការបន្តវិធាន ការ ដើម្បីអនុវត្តទំនួលខុសត្រូវក្នុងការការពារ ចាប់ពីការទប់ស្កាត់ ដល់ប្រតិកម្ម និងការកសាងឡើងវិញ។ គណៈកម្មការនេះបង្ហាញនូវវិធានការមួយចំនួនក្នុងការអនុវត្តទស្សនៈទាននេះ ដោយមានអន្តរាគមន៍ យោធា ដែលចាត់ទុកជាជម្រើសចុងក្រោយប៉ុណ្ណោះ។

គម្របរបាយការណ៍ គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS)។ ប្រភព៖ សម្ព័ន្ធភាពអន្តរជាតិ ដើម្បីទំនួលខុសត្រូវក្នុងការការពារ (ICRtoP)



# របាយការណ៍គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) បង្កើតពាក្យ "ទំនួលខុសត្រូវក្នុងការការពារ"

ជាការសំខាន់ របាយការណ៍គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) បានដាក់កំហិតលើពេលវេលាដែលសហគមន៍អន្តរជាតិអាច និងគួរធ្វើសកម្មភាព ដើម្បីទប់ស្កាត់រដ្ឋនានាពីការលើកឡើងហេតុផលការពារមនុស្ស ខណៈដែលធ្វើសកម្មភាពជាចម្បង ដើម្បីការពារផលប្រយោជន៍នយោបាយផ្ទាល់របស់ខ្លួន។ ជាពិសេស របាយការណ៍នេះបានស្នើឡើងនូវគោលការណ៍ប្រុងប្រយ័ត្ននានា ដែលត្រូវពិចារណាមុនពេលអនុញ្ញាតឲ្យមានការប្រើប្រាស់កម្លាំងយោធា ដើម្បីការពារប្រជាជន ដូចជា៖

- ចេតនាត្រឹមត្រូវ
- ជម្រើសចុងក្រោយ
- មធ្យោបាយដែលមានសមាមាត្រ
- ការរំពឹងភាពជោគជ័យដោយសមហេតុផល

របាយការណ៍នេះក៏បានពិភាក្សាអំពី "សិទ្ធិអំណាចត្រឹមត្រូវ" ផងដែរ ដោយទទួលស្គាល់ថា ស្ថាប័នសមស្របបំផុត ដែលអនុញ្ញាតឲ្យមានការប្រើប្រាស់កម្លាំង គឺក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ប៉ុន្តែ ដោយបញ្ជាក់ថា សមាជិកក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិគួរត្រូវបានលើកទឹកចិត្តឲ្យធ្វើការទប់ស្កាត់ឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) ឲ្យកាន់តែមានប្រសិទ្ធភាព (ឧទាហរណ៍ ដោយដោះស្រាយស្ថានភាពវិបត្តិភ្លាមៗ និងសម្រាប់សមាជិកអចិន្ត្រៃយ៍ទាំងប្រាំ ដោយចៀសវាងការប្រើប្រាស់សិទ្ធិវេតូនៅក្នុងករណីទាំងនេះ)។ របាយការណ៍ក៏បានបញ្ជាក់ផងដែរអំពីតួនាទីរបស់មហាសន្និបាត កិច្ចព្រមព្រៀងថ្នាក់តំបន់ និងថ្នាក់អនុតំបន់ និងរដ្ឋពាក់ព័ន្ធផ្សេងទៀតផងដែរ ប្រសិនបើក្រុមប្រឹក្សាសន្តិសុខបរាជ័យក្នុងការដោះស្រាយស្ថានភាពបែបនេះនៅក្នុង "ពេលវេលាសមស្រប"។ របាយការណ៍នេះក៏បានពិភាក្សាផងដែរអំពីបញ្ហា "មូលហេតុត្រឹមត្រូវ" ដោយបញ្ជាក់ថា កម្លាំងគួរត្រូវបានពិចារណា ប្រសិនបើ "ការបាត់បង់ជីវិតទ្រង់ទ្រាយធំ ឬការលុបបំបាត់ជាតិសាសន៍" ត្រូវបានគំរាមកំហែង។

ជាអកុសល ការកំណត់ពេលវេលានៃការចេញរបាយការណ៍បានធ្វើឲ្យប៉ះពាល់ដល់ការទទួលយកជាបឋមនៃរបាយការណ៍ មួយផ្នែកដោយសារការឈ្លានពានប្រទេសអ៊ីរ៉ាក់ក្នុងឆ្នាំ២០០៣។ ប្រតិបត្តិការយោធាជាឯកតោភាគីរបស់សហរដ្ឋអាមេរិក ដែលស្នើឡើងមួយផ្នែកផ្អែកលើទឡ្ហីករណ៍នៃអន្តរាគមន៍មនុស្សធម៌ បានបង្កើនការព្រួយបារម្ភថាទំនួលខុសត្រូវក្នុងការការពារ (RtoP) នឹងត្រូវបានប្រើប្រាស់ដោយរដ្ឋមហាអំណាច ដើម្បីបំផ្លាញអធិបតេយ្យភាពរបស់ប្រទេសផ្សេងទៀត។ ប៉ុន្តែ ទោះជាការគាំទ្រសម្រាប់ទំនួលខុសត្រូវក្នុងការការពារ (RtoP) ត្រូវបានរឹតត្បិតជាបឋមក៏ដោយ មហន្តរាយមនុស្សជាតិជាបន្តរួមទាំងបរាជ័យក្នុងការការពារប្រជាជននៃតំបន់ដាហ្វួរ បានផ្តល់សញ្ញាថា វិធានការបន្ថែមទៀតចាំបាច់ត្រូវតែធ្វើឡើងដោយសហគមន៍អន្តរជាតិទាំងមូល ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងនៃអំពើហិង្សាទ្រង់ទ្រាយធំប្រឆាំងនឹងប្រជាជន។

សហប្រធានគណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) លោក Mohammed Sahnoun (ខាងឆ្វេង) និងលោក Gareth Evans។ ប្រភព៖ រូបថតរបស់អង្គការសហប្រជាជាតិ ដោយ Evan Schneider។



## របៀបដែលទំនួលខុសត្រូវក្នុងការការពារ (RtoP) បានវិវឌ្ឍ៖ ពី គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) ទៅជំនួបកំពូលពិភពលោក ឆ្នាំ២០០៥

ការគាំទ្រចំពោះ ទំនួលខុសត្រូវក្នុងការការពារ (RtoP) ត្រូវបានបញ្ចូលនៅក្នុងរបៀបវារៈកំណែទម្រង់អង្គការសហប្រជាជាតិរបស់អគ្គលេខាធិការ រួមទាំង៖

**ឆ្នាំ២០០៤៖ គណៈកម្មការជាន់ខ្ពស់ទទួលបន្ទុករបាយការណ៍ស្តីពីការគំរាមកំហែង បញ្ហាប្រឈម និងការផ្លាស់ប្តូរដែលមានចំណងជើងថា *ពិភពលោកមួយកាន់តែមានសន្តិសុខ៖ ទំនួលខុសត្រូវរួមរបស់យើង***

ដើម្បីត្រៀមរៀបចំសម្រាប់សម័យប្រជុំលើកទី ៦០ នៃមហាសន្និបាត អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ បានចាត់តាំងក្រុមឥស្សរជនឆ្នើម ដើម្បីវាយតម្លៃលើការគំរាមកំហែងសន្តិសុខសកលបន្ទាន់បំផុត និងចេញអនុសាសន៍ស្តីពីរបៀបប្រសើរបំផុតក្នុងការកាត់បន្ថយការគំរាមកំហែងទាំងនោះ។ របាយការណ៍នេះរួមបញ្ចូលនូវអនុសាសន៍ចំនួន ១០១ អំពីរបៀបដែលពិភពលោក ត្រូវតែដោះស្រាយ បញ្ហាប្រឈមផ្នែកសន្តិសុខរបស់ខ្លួនរួមគ្នា និងល្អិតល្អន់ រួមទាំង តាមរយៈការប្រកាន់យក និងការអនុវត្តទំនួលខុសត្រូវក្នុងការការពារផងដែរ។

**ឆ្នាំ២០០៥៖ របាយការណ៍របស់អគ្គលេខាធិការ*ក្នុងសេរីភាពធំជាងមុន៖ ឆ្ពោះទៅរកការអភិវឌ្ឍន៍ សន្តិសុខ និងសិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា***

បន្ទាប់មក អគ្គលេខាធិការ លោក កូហ្វី អាណាន់ បានចេញរបាយការណ៍មួយ ជាមួយនឹងអនុសាសន៍នានាស្តីពីបញ្ហាដែលប្រមុខរដ្ឋ និងរដ្ឋាភិបាលគួរដោះស្រាយនៅក្នុង "ជំនួបកំពូលពិភពលោក" ដែលនឹងមកដល់នៅពេលនោះក្នុងឆ្នាំ២០០៥ និងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។ នៅក្នុងផ្នែកមួយដែលមានចំណងជើងថា *សេរីភាពក្នុងការរស់នៅដោយមានសេចក្តីថ្លៃថ្នូរ* ដោយពិភាក្សាអំពីសរសរស្តម្ភនៃសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ អគ្គលេខាធិការបានផ្តល់អនុសាសន៍ឲ្យបណ្តារដ្ឋទាំងឡាយ ប្រកាន់យកបទដ្ឋាននៃទំនួលខុសត្រូវក្នុងការការពារ ដែលកំពុងលេចឡើង។

**ឆ្នាំ២០០៥៖ ការព្រមព្រៀងមតិរបស់បណ្តារដ្ឋអាហ្វ្រិកនៅ Ezulwini**

បណ្តារដ្ឋាភិបាលអាហ្វ្រិកបានអនុម័តទំនួលខុសត្រូវក្នុងការការពារនៅក្នុង "ការព្រមព្រៀងមតិនៅ Ezulwini" ដោយទទួលស្គាល់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាសន្តិសុខក្នុងការអនុញ្ញាតឲ្យប្រើប្រាស់កម្លាំងនៅក្នុងស្ថានភាពនៃអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការលុបបំបាត់ជាតិសាសន៍ និងទទូចថា ក្នុងករណីបែបនេះ អង្គការប្រចាំតំបន់ដែលមានទីតាំងស្ថិតនៅក្បែរជម្លោះ គប្បីត្រូវបានផ្តល់សិទ្ធិអំណាចឲ្យចាត់វិធានការ។



អគ្គលេខាធិការត្រូវបានដាក់ជូននូវរបាយការណ៍ របស់គណៈកម្មការជាន់ខ្ពស់ទទួលបន្ទុកការគំរាមកំហែង បញ្ហាប្រឈម និងការផ្លាស់ប្តូរ។
ប្រភព៖ រូបថតរបស់អង្គការសហប្រជាជាតិ ដោយ EskinderDebebe។

## ឯកសារលទ្ធផលជំនួបកំពូលពិភពលោក ឆ្នាំ២០០៥ រួមបញ្ចូលនូវការអនុម័តទំនួលខុសត្រូវក្នុងការការពារ (RtoP) ជាប្រវត្តិសាស្ត្រ

ក្នុងខែកញ្ញា ឆ្នាំ២០០៥ ប្រមុខរដ្ឋ និងរដ្ឋាភិបាលនានាបានអនុម័តជាឯកច្ឆន្ទលើទំនួលខុសត្រូវក្នុងការការពារ និងឯកភាពចំពោះអត្ថបទខាងក្រោមនៅក្នុងកថាខណ្ឌ ១៣៨-១៤០ នៃឯកសារលទ្ធផលនៃកិច្ចប្រជុំពេញអង្គជាន់ខ្ពស់នៃមហាសន្និបាត ដែលហៅថា "ជំនួបកំពូលពិភពលោក"។ នេះគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដោយសារគំនិតនៃការប្តេជ្ញាចិត្តចំពោះទំនួលខុសត្រូវអន្តរជាតិក្នុងការការពារ ទទួលបានការគាំទ្រពីបណ្តារដ្ឋាភិបាល និងសង្គមស៊ីវិលមកពីតំបន់ទាំងអស់ មួយផ្នែកដោយសារថ្នាក់ដឹកនាំមកពីបណ្តារដ្ឋនៅប៉ែកខាងត្បូងពិភពលោក ដូចជា ប្រទេសអាហ្សង់ទីន ឈីលី ហ្គាតេម៉ាឡា ម៉ិចស៊ិក រ្វ៉ាន់ដា និងអាហ្វ្រិកខាងត្បូង ដែលប្រទេសទាំងនេះ គឺជាអ្នកតស៊ូមតិដ៏ខ្លាំងក្លាឲ្យមានការបញ្ចូលបទដ្ឋាន។

១៣៨. រដ្ឋនីមួយៗមានទំនួលខុសត្រូវក្នុងការការពារប្រជាជនរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការលុបបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទំនួលខុសត្រូវនេះចែងអំពីការទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនេះ រួមទាំងការញុះញង់ឲ្យមានឧក្រិដ្ឋកម្មទាំងនេះ តាមរយៈមធ្យោបាយសមស្រប និងចាំបាច់។ យើងទទួលស្គាល់ថា ទំនួលខុសត្រូវ និងឆន្ទៈធ្វើសកម្មភាពស្របតាមមធ្យោបាយនេះ។ សហគមន៍អន្តរជាតិ ប្រសិនបើសមស្រប គួរលើកទឹកចិត្ត និងជួយបណ្តារដ្ឋនានាឲ្យអនុវត្តទំនួលខុសត្រូវនេះ និងគាំទ្រអង្គការសហប្រជាជាតិក្នុងការបង្កើតសមត្ថភាពព្រមានជាមុន។

១៣៩. តាមរយៈអង្គការសហប្រជាជាតិ សហគមន៍អន្តរជាតិក៏មានទំនួលខុសត្រូវផងដែរក្នុងការប្រើប្រាស់មធ្យោបាយការទូត មនុស្សធម៌ និងមធ្យោបាយសន្តិភាពផ្សេងទៀតដែលសមស្រប ស្របតាមជំពូក VI និង VIII នៃធម្មនុញ្ញ ដើម្បីជួយការពារប្រជាជនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការលុបបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងបរិបទនេះ យើងត្រៀមខ្លួនជាស្រេចក្នុងការចាត់វិធានការរួមគ្នាឲ្យបានទាន់ពេលវេលា និងម៉ឺងម៉ាត់ តាមរយៈក្រុមប្រឹក្សាសន្តិសុខ ស្របតាមធម្មនុញ្ញ រួមទាំងជំពូកទី VII តាមករណីនីមួយៗ និងដោយសហប្រតិបត្តិការជាមួយនឹងអង្គការពាក់ព័ន្ធប្រចាំតំបន់តាមភាពសមស្រប ប្រសិនបើមធ្យោបាយសន្តិភាពពុំមានភាពគ្រប់គ្រាន់ ហើយអាជ្ញាធរជាតិបរាជ័យយ៉ាងច្បាស់ក្នុងការការពារប្រជាជនរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការលុបបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ យើងសង្កត់ធ្ងន់លើតម្រូវការឲ្យមហាសន្និបាត បន្តពិចារណាទំនួលខុសត្រូវក្នុងការការពារប្រជាជនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការលុបបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងផលវិបាករបស់វា ដោយចងចាំក្នុងចិត្តនូវគោលការណ៍នៃធម្មនុញ្ញ និងច្បាប់អន្តរជាតិ។ យើងក៏មានបំណងប្តេជ្ញាចិត្តផងដែរ តាមការចាំបាច់ និងសមស្រប ក្នុងការជួយបណ្តារដ្ឋនានា កសាងសមត្ថភាព ដើម្បីការពារប្រជាជនរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការលុបបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងក្នុងការជួយប្រទេសទាំងឡាយដែលស្ថិតក្រោមសម្ពាធ មុនពេលវិបត្តិ និងជម្លោះផ្ទុះឡើង។

១៤០. យើងគាំទ្រយ៉ាងពេញទំហឹង ចំពោះបេសកកម្មរបស់ទីប្រឹក្សាពិសេស នៃអគ្គលេខាធិការទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍។

## ប្រៀបធៀប និងបង្ហាញភាពខុសគ្នា៖ របាយការណ៍គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) ក្នុងឆ្នាំ២០០១ និងឯកសារលទ្ធផលជំនួបកំពូលពិភពលោក (WSOD) ក្នុងឆ្នាំ២០០៥

ទោះជារបាយការណ៍គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) បានថែងមុនគេអំពីទំនួលខុសត្រូវក្នុងការការពារក៏ដោយ ក៏សមាសធាតុទាំងអស់ដែលបង្ហាញនៅក្នុងរបាយការណ៍ មិនសុទ្ធតែត្រូវបានអនុម័តដោយរដ្ឋជាសមាជិកនានានៅក្នុងឯកសារលទ្ធផលជំនួបកំពូលពិភពលោក (WSOD) ឡើយ។ នៅពេលយើងពិភាក្សាអំពីទំនួលខុសត្រូវក្នុងការការពារបច្ចុប្បន្ន យើងសំដៅជាពិសេសដល់អ្វីដែលត្រូវបានបញ្ចូលនៅក្នុងកថាខណ្ឌ ១៣៨, ១៣៩ និង ១៤០ នៃឯកសារលទ្ធផលជំនួបកំពូលពិភពលោក (WSOD) ដោយសារនេះគឺជាភាសាដែលរដ្ឋជាសមាជិកទាំងអស់បានឯកភាព។

**សេចក្តីថែងរៀងៗខ្លួននៃរបាយការណ៍គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) និងឯកសារលទ្ធផលជំនួបកំពូលពិភពលោក (WSOD) អំពីបទដ្ឋាន មានភាពខុសគ្នាតាមរបៀបដូចខាងក្រោម៖**

- ទោះបីជារបាយការណ៍គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) បានស្នើឲ្យពិចារណា "គោលការណ៍ប្រុងប្រយ័ត្ន" មុនពេលអនុញ្ញាតឲ្យប្រើប្រាស់កម្លាំង (សូមមើលទំព័រ ១១) ក៏ដោយ ក៏គោលការណ៍ទាំងនេះមិនត្រូវបានអនុម័តក្នុងឆ្នាំ២០០៥ឡើយ។
- បណ្តារដ្ឋជាសមាជិកនៅក្នុងឯកសារលទ្ធផលជំនួបកំពូលពិភពលោក (WSOD) បានព្រមព្រៀងថា វិសាលភាពនៃទំនួលខុសត្រូវក្នុងការការពារ មានលក្ខណៈចង្អៀត និងគ្របដណ្តប់តែលើឧក្រិដ្ឋកម្ម និងការរំលោភបំពានបួនប្រភេទប៉ុណ្ណោះ គឺអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការលុបបំបាត់ជាតិសាសន៍។ ផ្ទុយទៅវិញ របាយការណ៍គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) បានថែងអំពីវិសាលភាពទូលំទូលាយជាង និងរួមបញ្ចូល "មហន្តរាយធម្មជាតិ និងបរិស្ថានធ្ងន់ធ្ងរ ដែលរដ្ឋសាមីពុំមានឆន្ទៈ ឬមិនអាចជម្នះបាន ឬអំពាវនាវសុំជំនួយ" និង "ស្ថានភាពនៃការដួលរលំរបស់រដ្ឋ និងការដាក់ឲ្យប្រជាជនស្ថិតក្នុងគ្រោះទុរភិក្ស ធ្ងន់ធ្ងរ និង/ឬសង្គ្រាមស៊ីវិល"។
- "ទំនួលខុសត្រូវក្នុងការកសាងឡើងវិញ" ត្រូវបានថែងនៅក្នុងរបាយការណ៍គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) ជាផ្នែកមួយនៃការបន្តទំនួលខុសត្រូវក្នុងការការពារ ប៉ុន្តែ មិនត្រូវបានបញ្ចូលនៅក្នុងកថាខណ្ឌឯកសារលទ្ធផលជំនួបកំពូលពិភពលោក (WSOD) ឡើយ។ បញ្ហានេះមួយផ្នែកបណ្តាលមកពីវិធានការកសាងឡើងវិញ ទោះបីជាផ្នែកសំខាន់មួយនៃការទប់ស្កាត់ការកើតឡើងវិញនូវអំពើហិង្សា និងការការពារប្រជាជន នឹងត្រូវដោះស្រាយ តាមរយៈការបង្កើតគណៈកម្មការកសាងសន្តិភាពក៏ដោយ។



ជំនួបកំពូលពិភពលោក ឆ្នាំ២០០៥ បានប្រារព្ធធ្វើឡើងនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៥។ ប្រភព៖ រូបថតរបស់អង្គការសហប្រជាជាតិ ដោយ Mark Garten

### តើអ្វីទៅជាមូលដ្ឋានគ្រឹះផ្អែកបទដ្ឋាន និងច្បាប់នៃទំនួលខុសត្រូវក្នុងការការពារ (RtoP)?

ការស្វែងយល់ដែលកំពុងលេចឡើងដែលអធិបតេយ្យភាព រួមបញ្ចូលទាំងទំនួលខុសត្រូវ ព្រមទាំងសិទ្ធិ គឺជាគោលការណ៍ណែនាំមួយសម្រាប់ទំនួលខុសត្រូវក្នុងការការពារ (RtoP)។ សមាជិកភាពនៅក្នុងអង្គការសហប្រជាជាតិ គឺជាឧទាហរណ៍សំខាន់បំផុតនៃបណ្តារដ្ឋដែលស្ម័គ្រចិត្តទទួលយកកាតព្វកិច្ច និងការកំហិតលើទង្វើរបស់ខ្លួនជាសមាជិកនៃសហគមន៍អន្តរជាតិ។

ទស្សនៈទាននៃសន្តិសុខមនុស្សជាតិ ដែលចែងពីដំបូងដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនៅក្នុងរបាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ១៩៩៤ របស់ខ្លួន ក៏មានជាប់ទាក់ទងនឹងទំនួលខុសត្រូវក្នុងការការពារ (RtoP) ផងដែរ ដោយសារវាដើរតួនាទីដ៏ធំមួយនៅក្នុងការផ្លាស់ប្តូរចំណុចផ្តោតនៃសន្តិសុខពីដែនដីទៅកាន់ប្រជាជន។

ទំនួលខុសត្រូវក្នុងការការពារ (RtoP) ក៏ត្រូវបានបង្កើតឡើងផងដែរផ្អែកលើកាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិ យោងតាមសេចក្តីប្រកាស កិច្ចព្រមព្រៀង និងសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្ស និងការការពារមនុស្ស ច្បាប់មនុស្សធម៌អន្តរជាតិ និងជនភៀសខ្លួន និងច្បាប់ជាតិនានាដែលចែងអំពីបទដ្ឋាននៃការប្រព្រឹត្ត និងមធ្យោបាយអនុវត្តបទដ្ឋានទាំងនេះ។ អ្វីដែលពាក់ព័ន្ធជាពិសេស គឺសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាក្រុងហ្សឺណែវចំនួនបួន និងពិធីសារបន្ថែមចំនួនពីរ អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ អនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋនយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ និងលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។

## តើឧក្រិដ្ឋកម្ម និងការរំលោភបំពានទាំងបួនមានអ្វីខ្លះ ដែលបញ្ចូលនៅក្នុងទំនួលខុសត្រូវក្នុងការការពារ (RtoP)?

ទំនួលខុសត្រូវក្នុងការការពារ (RtoP) មានវិសាលភាពតូចចង្អៀតខ្លាំង និងអនុវត្តចំពោះតែឧក្រិដ្ឋកម្ម និងការរំលោភបំពានជាក់លាក់ចំនួនបួនប៉ុណ្ណោះ គឺអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការលុបបំបាត់ជាតិសាសន៍។ ដូច្នេះ បទដ្ឋាននេះមិនអនុវត្តចំពោះការគំរាមកំហែងផ្សេងទៀតចំពោះសន្តិសុខមនុស្សជាតិ ដូចជា វិបត្តិសុខភាព មហន្តរាយធម្មជាតិ ភាពក្រីក្រ ឬអំពើពុករលួយឡើយ។ ជាញឹកញាប់ យើងប្រើពាក្យ "អំពើឃោរឃៅទ្រង់ទ្រាយធំ" ដើម្បីរួមបញ្ចូលឧក្រិដ្ឋកម្ម និងការរំលោភបំពានទាំងបួន។

## អំពើប្រល័យពូជសាសន៍

ក្រោយពីភាពតក់ស្លុតនៃហាយនភាព បណ្តារដ្ឋជាសមាជិកនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាស្តីពីការទប់ស្កាត់ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤៨។ ប្រការ II ផ្តល់និយមន័យនៃពាក្យ "អំពើប្រល័យពូជសាសន៍" ជា៖

អំពើដែលប្រព្រឹត្តក្នុងចេតនាបំផ្លាញ ទាំងស្រុង ឬមួយផ្នែក នូវក្រុមជនរួមជាតិ ជនជាតិ ជាតិសាសន៍ ឬជាតិសាសនា រួមទាំង៖

- (ក) ការសម្លាប់សមាជិកនៃក្រុម
- (ខ) ការបង្កគ្រោះថ្នាក់ផ្នែករាងកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរចំពោះសមាជិកនៃក្រុម
- (គ) ការដាក់ដោយចេតនាលើក្រុមនូវលក្ខខណ្ឌជីវិត ដែលត្រូវបានចាត់ទុកថា នាំមកនូវការបំផ្លាញផ្នែករាងកាយរបស់ក្រុមទាំងស្រុង ឬមួយផ្នែក
- (ឃ)ការដាក់វិធានការដែលមានចេតនាទប់ស្កាត់កំណើតនៅក្នុងក្រុម
- (ង) ការផ្ទេរកុមារនៃក្រុមមួយទៅក្រុមមួយទៀតដោយបង្ខំ។

** កំណត់សម្គាល់៖ អំពើប្រល័យពូជសាសន៍អាចកើតឡើងនៅក្នុង ឬនៅក្រៅជម្លោះប្រដាប់អាវុធ។

# ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានអនុម័តនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២ ដើម្បីបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលជាស្ថាប័នតុលាការអន្តរជាតិអចិន្ត្រៃយ៍មួយ ដែលអាចស៊ើបអង្កេត និងផ្តន្ទាទោសរឿងក្តីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ រដ្ឋាភិបាលទាំងអស់ មិនមែនសុទ្ធតែជាហត្ថលេខីនៃលក្ខន្តិកៈទីក្រុងរ៉ូមឡើយ ប៉ុន្តែ ប្រការ VII នៃលក្ខន្តិកៈនេះកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ដែលមិនដូចអំពើប្រល័យពូជសាសន៍ដោយគ្មានចេតនាជាក់លាក់ឡើយ) ជា៖

អំពើដែលប្រព្រឹត្ត ជាផ្នែកមួយនៃការវាយប្រហារដែលរាលដាល ឬមានលក្ខណៈជាប្រព័ន្ធក្នុងគោលបំណងប្រឆាំងនឹងប្រជាជនស៊ីវិល ដោយដឹងអំពីការវាយប្រហារ។

(ក) ការធ្វើឃាត
(ខ) ការសម្លាប់ផុតពូជ
(គ) ការចាប់ធ្វើទាសករ
(ឃ)ការនិរទេស ឬការផ្ទេរប្រជាជនដោយបង្ខំ
(ង) ការចាប់ដាក់ពន្ធនាគារ ឬការដកហូតធ្ងន់ធ្ងរផ្សេងទៀតនូវសេរីភាពផ្នែករាងកាយដែលរំលោភបំពានវិធានជាមូលដ្ឋាននៃច្បាប់អន្តរជាតិ
(ច) ការធ្វើទារុណកម្ម
(ឆ) ការរំលោភសេពសន្ថវៈ អំពើទាសភាពផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានគភ៌ដោយបង្ខំ ការធ្វើឲ្យអារដោយបង្ខំ ឬទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទដែលមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា
(ជ) ការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងក្រុម ដែលអាចកំណត់អត្តសញ្ញាណបាន ឬក្រុមសមូហភាពផ្នែកនយោបាយ ជាតិសាសន៍ ជនរួមជាតិ ជនជាតិ វប្បធម៌ សាសនា យេនឌ័រ ដូចត្រូវបានកំណត់នៅក្នុងកថាខ័ណ្ឌទី៣ ឬមូលដ្ឋានផ្សេងទៀតដែលត្រូវបានទទួលស្គាល់ជាសកលថាមិនអាចអនុញ្ញាតបាន យោងតាមច្បាប់អន្តរជាតិទាក់ទងនឹងអំពើណាមួយដែលយោងដល់នៅក្នុងកថាខ័ណ្ឌនេះ ឬឧក្រិដ្ឋកម្មណាមួយ នៅក្នុងយុត្តាធិការនៃតុលាការ
(ឈ)ការបាត់ខ្លួនមនុស្សដោយបង្ខំ
(ញ) ឧក្រិដ្ឋកម្មអាប៉ាថេត (ការបែងចែកជាតិសាសន៍)
(ដ) អំពើអនុស្សធម៌ផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល ក្នុងចេតនាបង្កឲ្យមានទុក្ខវេទនាធ្ងន់ធ្ងរ ឬរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាពផ្លូវចិត្ត ឬផ្លូវកាយ។

## ឧក្រិដ្ឋកម្មសង្គ្រាម

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ សហគមន៍អន្តរជាតិបានអនុម័តអនុសញ្ញាក្រុងហ្សឺណែវចំនួនបួន។ អនុសញ្ញាទាំងនេះ និងពិធីសារបន្ថែមចំនួនពីរ ដែលអនុម័តក្នុងឆ្នាំ១៩៧៧ ការពារបុគ្គលទាំងឡាយណាដែលមិនជាប់ពាក់ព័ន្ធនៅក្នុងអំពើអរិភាពក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ។ អនុសញ្ញា និងពិធីសារបន្ថែមទាំងនេះ ចែងអំពីបទដ្ឋាននៃការប្រព្រឹត្តចំពោះបុគ្គលទាំងនេះ យោងតាមច្បាប់មនុស្សធម៌អន្តរជាតិ និងកំណត់និយមន័យឧក្រិដ្ឋកម្មសង្គ្រាមជាអំពើមួយដែលប្រព្រឹត្តឡើងក្នុងអំឡុងជម្លោះប្រដាប់អាវុធដែលរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិ ឬច្បាប់សិទ្ធិមនុស្ស។ កម្រិតនៃការរំលោភបំពានដែលបង្កើតបានជាឧក្រិដ្ឋកម្មសង្គ្រាម មានភាពទូលំទូលាយ ហើយ ក្នុងចំណោមឧក្រិដ្ឋកម្មផ្សេងទៀត រួមបញ្ចូលទាំងការធ្វើឃាត ឬការប្រព្រឹត្តអាក្រក់លើបុគ្គលណាម្នាក់ដែលមិន ឬលែងចូលរួមនៅក្នុងអំពើអរិភាព រួមទាំងជនស៊ីវិល អ្នកទោសសង្គ្រាម អ្នករបួស ឬអ្នកជំងឺ បុគ្គលិកវេជ្ជសាស្ត្រ និងសាសនា និងបុគ្គលិកប្រតិបត្តិការជួយសង្គ្រោះ។

** កំណត់សម្គាល់៖ ឧក្រិដ្ឋកម្មសង្គ្រាម យោងតាមទំនួលខុសត្រូវក្នុងការការពារ គួរត្រូវបានកំហិតត្រឹមឧក្រិដ្ឋកម្ម ដែលមានគោលបំណងប្រឆាំងប្រជាជនស៊ីវិល ដែលប្រព្រឹត្តឡើងក្នុងលក្ខណៈរាលដាល និងជាប្រព័ន្ធ។

## ការលុបបំបាត់ជាតិសាសន៍

ការលុបបំបាត់ជាតិសាសន៍ មិនត្រូវបានទទួលស្គាល់ជាផ្លូវការថាជាឧក្រិដ្ឋកម្មលេចធ្លោ យោងតាមច្បាប់អន្តរជាតិឡើយ ប៉ុន្តែ ពាក់ព័ន្ធនឹងគោលនយោបាយប្រកបដោយចេតនា ដែលតាក់តែងឡើងដោយក្រុមជនជាតិ ឬសាសនាមួយ ដើម្បីកំចាត់ តាមមធ្យោបាយហិង្សា និងជំរុញឲ្យមានអំពើភេរវកម្ម នូវប្រជាជនស៊ីវិលនៃក្រុមជនជាតិ ឬសាសនាមួយទៀតពីតំបន់ភូមិសាស្ត្រជាក់លាក់មួយចំនួន។ ដូច្នេះ ការលុបបំបាត់ជាតិសាសន៍ ត្រូវបានរាប់បញ្ចូលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលរួមបញ្ចូលទាំងការផ្ទេរ ឬការនិរទេសប្រជាជនដោយបង្ខំ។

# ការវិវត្តន៍នៅអង្គការសហប្រជាជាតិចាប់តាំងពីឆ្នាំ២០០៥

## លេខាធិការដ្ឋាន

ក្នុងឆ្នាំ២០០៤ អគ្គលេខាធិការ (UNSG) បានបង្កើតការិយាល័យទីប្រឹក្សាពិសេសទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍ (បច្ចុប្បន្នហៅថា ការិយាល័យទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងទំនួលខុសត្រូវក្នុងការការពារ) ដែលត្រូវបានដឹកនាំដោយទីប្រឹក្សាពិសេសចំនួនបីរូប ទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍ គឺលោក Juan Méndes (2004-2007) បណ្ឌិត Francis Deng (2007-2012) និងលោក AdamaDieng (2012-បច្ចុប្បន្ន)។ អគ្គលេខាធិការ (UNSG) ក៏បានតែងតាំងទីប្រឹក្សាពិសេសមួយរូបទទួលបន្ទុកទំនួលខុសត្រូវក្នុងការការពារ គឺបណ្ឌិត Edward Luck (2008-2012)។ បណ្ឌិត Jennifer Welsh បានកាន់កាប់តួនាទីជាទីប្រឹក្សាពិសេសរបស់អគ្គលេខាធិការ (UNSG) ទទួលបន្ទុកទំនួលខុសត្រូវក្នុងការការពារ ក្នុងឆ្នាំ២០១៣។

អគ្គលេខាធិការបង្ហាញរបាយការណ៍ទំនួលខុសត្រូវក្នុងការការពារ (RtoP) ឆ្នាំ២០០៩ ដល់មហាសន្និបាត។ ប្រភព៖ រូបថតរបស់អង្គការសហប្រជាជាតិ ដោយ Jenny Rockett។



## មហាសន្និបាត

ចាប់តាំងពីឆ្នាំ២០០៩ អគ្គលេខាធិការ (UNSG) បានបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីទំនួលខុសត្រូវក្នុងការការពារ (RtoP) ដែលត្រូវបានពិចារណាដោយមហាសន្និបាត (UNGA) នៅក្នុងកិច្ចសន្ទនាអន្តរកម្មនានារវាងរដ្ឋជាសមាជិក មន្ត្រីអង្គការសហប្រជាជាតិ និងអង្គការសង្គមស៊ីវិលនានា។ របាយការណ៍ដំបូងដែលបោះពុម្ពផ្សាយក្នុងឆ្នាំ២០០៩ និងមានចំណងជើងថា *ការអនុវត្តទំនួលខុសត្រូវក្នុងការការពារ* បាននាំឲ្យមហាសន្និបាត (UNGA) អនុម័តសេចក្តីសម្រេច A/RES/63/308 ដែលគាំទ្រដល់ការពិចារណាជាបន្តអំពីបទដ្ឋាន។ ក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយមក របាយការណ៍ និងកិច្ចពិភាក្សាជាបន្តបន្ទាប់បានផ្តោតលើមូលបទដូចខាងក្រោម៖

- *ការព្រមានជាមុន ការវាយតម្លៃ និងទំនួលខុសត្រូវក្នុងការការពារ* (២០១០)
- *តួនាទីនៃកិច្ចព្រមព្រៀងថ្នាក់តំបន់ និងអនុតំបន់ក្នុងការអនុវត្តទំនួលខុសត្រូវក្នុងការការពារ* (២០១១)
- *ទំនួលខុសត្រូវក្នុងការការពារ៖ ការឆ្លើយតបទាន់ពេលវេលា និងម៉ឺងម៉ាត់* (២០១២)
- *ទំនួលខុសត្រូវក្នុងការការពារ៖ ទំនួលខុសត្រូវ និងការទប់ស្កាត់របស់រដ្ឋ* (២០១៣)

## ការិយាល័យទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងទំនួលខុសត្រូវក្នុងការការពារ

ការិយាល័យនេះធ្វើសកម្មភាពជា "អ្នកឃ្លាំមើល" ដោយប្រកាសអាសន្នដល់តួអង្គសហប្រជាជាតិ សង្គមស៊ីវិល និងសាធារណជនទូទៅអំពីស្ថានភាពនានា ដែលប្រជាជនស្ថិតក្នុងហានិភ័យនៃអំពើឃោរឃៅទ្រង់ទ្រាយធំ តាមរយៈសេចក្តីថ្លែងជាសាធារណៈ និងកិច្ចប្រជុំសង្ខេបឯកជន និងបង្កើនសមត្ថភាពរបស់អង្គការសហប្រជាជាតិក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្ម និងការរំលោភបំពានទំនួលខុសត្រូវក្នុងការការពារ (RtoP)។ ការិយាល័យនេះក៏អនុវត្តបេសកកម្ម និងការបណ្តុះបណ្តាលទូទាំងពិភពលោកផងដែរ ដើម្បីពង្រឹងសមត្ថភាពនៃតួអង្គថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីការពារប្រជាជន។ ក្នុងបរិបទនេះ ការិយាល័យនេះបានធ្វើការជាមួយសន្និសញ្ញាអន្តរជាតិស្តីពីតំបន់ Great Lakes មន្ត្រីរដ្ឋាភិបាល និងមន្ត្រីអង្គការប្រចាំតំបន់នៅអាស៊ីអាគ្នេយ៍ អ្នកជំនាញផ្នែកទប់ស្កាត់អំពើប្រល័យពូជសាសន៍ថ្នាក់រដ្ឋនៅអាមេរិកឡាទីន និងប្រទេសជាច្រើនផ្សេងៗទៀត។

## ក្រុមប្រឹក្សាសន្តិសុខ

ក្រុមប្រឹក្សាសន្តិសុខបានប្រើប្រាស់ទំនួលខុសត្រូវក្នុងការការពារ (RtoP)ជាឯកសារយោងនៅក្នុងសេចក្តីសម្រេចជាច្រើន៖

- សេចក្តីសម្រេច ១៦៧៤ (២០០៦) និង ១៨៩៤ (២០០៩) ស្តីពី *ការការពារជនស៊ីវិលនៅក្នុងជម្លោះប្រដាប់ អាវុធ*
- *សេចក្តីសម្រេច ១៦៥៣ (២០០៦) ស្តីពីតំបន់ Great Lakes*
- *សេចក្តីសម្រេច ១៧០៦ (២០០៧) ស្តីពីស្ថានភាពនៅដាហ្វួរ*
- *សេចក្តីសម្រេច ១៩៧០ (២០១១), ១៩៧៣ (២០១១), ២០១៦ (២០១១), ២០៤០ (២០១២) និង ២០៩៥ (២០១៣) ស្តីពីស្ថានភាពនៅប្រទេសលីប៊ី*
- *សេចក្តីសម្រេច ១៩៧៥ (២០១១) ស្តីពីស្ថានភាពនៅប្រទេសកូដឌីវ័រ*
- *សេចក្តីសម្រេច ១៩៩៦ (២០១១) ស្តីពីស្ថានភាពនៅប្រទេសស៊ូដង់ខាងត្បូង*
- *សេចក្តីសម្រេច ២០១៤ (២០១១) ស្តីពីស្ថានភាពនៅប្រទេសយេម៉ែន*
- *សេចក្តីសម្រេច ២០៨៥ (២០១២) និង ២១០០ (២០១៣) ស្តីពីស្ថានភាពនៅប្រទេសម៉ាលី*
- *សេចក្តីសម្រេច ២០៩៣ (២០១៣) ស្តីពីស្ថានភាពនៅប្រទេសសូម៉ាលី*
- *សេចក្តីសម្រេច ២១០៩ (២០១៣) ស្តីពីស្ថានភាពនៅប្រទេស៊ូដង់/ស៊ូដង់ខាងត្បូង*
- *សេចក្តីសម្រេច ២១១៧ (២០១៣) ស្តីពីអាវុធធុនតូច និងអាវុធធុនស្រាល*
- *សេចក្តីសម្រេច ២១២១ (២០១៣) និង ២១២៧ (២០១៣), ២១៣៤ (២០១៤) និង ២១៤៩ (២០១៤) ស្តីពីស្ថានភាពនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល*
- *សេចក្តីសម្រេច ២១៣៩ (២០១៤) ស្តីពីស្ថានភាពនៅប្រទេសស៊ីរី*
- *សេចក្តីសម្រេច ២១៥០ (២០១៤) ស្តីពីការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើប្រល័យពូជសាសន៍*

## មហាសន្និបាត

ចាប់តាំងពីឆ្នាំ២០១១មក មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសេចក្ដីសម្រេចដែលថ្កោលទោសដល់ការរំលោភបំពានសិទ្ធិមនុស្ស ក្នុងលក្ខណៈជាប្រព័ន្ធនៅក្នុងប្រទេសស៊ីរីដោយប្រើប្រាស់ទំនួលខុសត្រូវក្នុងការការពារ។

- សេចក្ដីសម្រេច ១១៩៨ (ខែធ្នូ ឆ្នាំ២០១១: ១៣៣ គាំទ្រ ១១ ប្រឆាំង ៤៣ អនុប្បវាទ)
- សេចក្ដីសម្រេច ១១២០៧ (ខែកុម្ភៈ ឆ្នាំ២០១២: ១៣៧ គាំទ្រ ១២ ប្រឆាំង ១៧ អនុប្បវាទ)
- សេចក្ដីសម្រេច ១១២៦៦ (ខែសីហា ឆ្នាំ២០១២: ១៣៣ គាំទ្រ ១២ ប្រឆាំង ៣១ អនុប្បវាទ)
- សេចក្ដីសម្រេច ១១៣៧២ (ខែឧសភា ឆ្នាំ២០១៣: ១០៧ គាំទ្រ ១២ ប្រឆាំង ៥៩ អនុប្បវាទ)
- សេចក្ដីសម្រេច ១១៤៧៥ (ខែធ្នូ ឆ្នាំ២០១៣: ១២៧ គាំទ្រ ១៣ ប្រឆាំង ៤៧ អនុប្បវាទ)

## ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស

ក្រុមប្រឹក្សាសិទ្ធិមនុស្សបានពិចារណាទំនួលខុសត្រូវក្នុងការការពារ (RtoP) ក្នុងអំឡុងព្រឹត្តិការណ៍មួយដែលរៀបចំរួមគ្នាដោយក្រុមបេសកកម្មអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិប្រចាំក្រុងហ្សឺណែវ ដែលមកពីប្រទេសអូស្ត្រាលី ហុងគ្រី នីហ្សេរីយ៉ា ថៃ និងអ៊ុយរុយហ្គាយ ក្នុងខែមិថុនា ឆ្នាំ២០១២។ ព្រឹត្តិការណ៍នេះត្រូវបាននាំមុខដោយសេចក្ដីថ្លែងការណ៍ចំនួនពីរ ដែលធ្វើឡើងនៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្ស។ សេចក្ដីថ្លែងការណ៍ទីមួយត្រូវបានធ្វើឡើងតាងនាមឲ្យរដ្ឋជាសមាជិកចំនួន ៥៥ នៅក្នុងខែមីនា ឆ្នាំ២០១១ ហើយសេចក្ដីថ្លែងការណ៍ទីពីរត្រូវបានធ្វើឡើង តាងនាមឲ្យរដ្ឋាភិបាលប្រាំដដែល ដែលបានរៀបចំព្រឹត្តិការណ៍ក្នុងខែមីនា ឆ្នាំ២០១២។ ព្រឹត្តិការណ៍ខ្លួនឯង គឺជាឱកាសដំបូងបំផុត ដែលក្នុងឱកាសនេះសមាជិកក្រុមប្រឹក្សាសិទ្ធិមនុស្សត្រូវបានអញ្ជើញឲ្យពិភាក្សាអំពីទំនួលខុសត្រូវក្នុងការការពារនៅទីក្រុងហ្សឺណែវ និងតំណាងឲ្យជំហានសំខាន់មួយនៅក្នុងការជំរុញឲ្យមានការទទួលយកទំនួលខុសត្រូវក្នុងការការពារ (RtoP) និងពង្រឹងការអនុវត្តនៅក្នុងក្រុមប្រឹក្សា។

ឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស លោកស្រី Navi Pillay ក៏បានសំដែងការគាំទ្រជាបន្តរបស់គាត់ចំពោះទំនួលខុសត្រូវក្នុងការការពារ (RtoP) ផងដែរ ហើយចាប់តាំងពីឆ្នាំ២០០៩ បានរំឭកការប្ដេជ្ញាចិត្តរបស់រដ្ឋជាសមាជិកចំពោះទំនួលខុសត្រូវក្នុងការការពារ (RtoP) នៅក្នុងបរិបទនៃករណីថ្នាក់ប្រទេស រួមទាំងវិបត្តិនៅលីប៊ី និងស៊ីរី។ ក្នុងឆ្នាំ២០១៤ គណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកស៊ើបសួរសិទ្ធិមនុស្សនៅកូរ៉េខាងជើង ក៏បានដាក់របាយការណ៍មួយជូន UNHRC ស្ដីពីការរំលោភបំពានសិទ្ធិមនុស្សដែលមានលក្ខណៈជាប្រព័ន្ធនៅក្នុងប្រទេសនោះ ដែលបានចងក្រងឯកសារភ័ស្ដុតាងអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ។

## សមាសធាតុគន្លឹះនៃទំនួលខុសត្រូវក្នុងការការពារ (RtoP) ៖ សសរស្តម្ភទាំងបី

នៅក្នុងរបាយការណ៍ឆ្នាំ២០០៩ របស់គាត់ ដែលមានចំណងជើងថា *ការអនុវត្តទំនួលខុសត្រូវក្នុងការការពារ* អគ្គលេខាធិការ លោក បាន គីមូន បានបញ្ជាក់នូវយុទ្ធសាស្ត្រមួយដែលមានសសរស្តម្ភចំនួនបី៖

### សសរស្តម្ភទីមួយ៖ ទំនួលខុសត្រូវក្នុងការការពាររបស់រដ្ឋ

សសរស្តម្ភទីមួយចែងថា បណ្តារដ្ឋទាំងឡាយមានទំនួលខុសត្រូវចម្បងចំពោះការការពារប្រជាជនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការលប់បំបាត់ជាតិសាសន៍។

### សសរស្តម្ភទីពីរ៖ ជំនួយអន្តរជាតិ និងការកសាងសមត្ថភាព

សសរស្តម្ភទីពីរចែងថា សហគមន៍អន្តរជាតិមានទំនួលខុសត្រូវក្នុងការជួយ និងលើកទឹកចិត្តបណ្តារដ្ឋទាំងឡាយឲ្យបំពេញកាតព្វកិច្ចការពាររបស់ខ្លួន។

### សសរស្តម្ភទីបី៖ ការឆ្លើយតបទាន់ពេលវេលា និងម៉ឺងម៉ាត់

សសរស្តម្ភទីបីចែងថា ប្រសិនបើរដ្ឋមួយខកខានមិនបានការពារប្រជាជនរបស់ខ្លួន ពីឧក្រិដ្ឋកម្មទាំងនេះ ឬតាមពិត ជាអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ សហគមន៍អន្តរជាតិត្រូវតែឆ្លើយតបឲ្យបានទាន់ពេលវេលា និងម៉ឺងម៉ាត់ ដោយប្រើប្រាស់មធ្យោបាយសមស្របផ្នែកការទូត សេដ្ឋកិច្ច មនុស្សធម៌ និងមធ្យោបាយសន្តិវិធីផ្សេងទៀត ដើម្បីការពារប្រជាជន។ ប្រសិនបើមធ្យោបាយសន្តិវិធីមានភាពមិនគ្រប់គ្រាន់ សហគមន៍អន្តរជាតិត្រូវតែត្រៀមខ្លួនជាស្រេចក្នុងការចាត់វិធានការកាន់តែខ្លាំងក្លា រួមទាំងវិធានការអនុវត្តរួមគ្នា យោងតាមជំពូក VII នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

## តើគេអាចចាត់វិធានការអ្វីខ្លះ ដើម្បីទប់ស្កាត់ និងបញ្ឈប់អំពើឃោរឃៅទ្រង់ទ្រាយធំ?

គោលដៅចម្បងនៃទំនួលខុសត្រូវក្នុងការការពារ (RtoP) គឺការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងការលុបបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អំពើឃោរឃៅទាំងនេះអាចកើតឡើងទាំងក្នុងពេលមានសន្តិភាព និងទាំងក្នុងពេលមានជម្លោះខាងក្រៅ ឬជម្លោះផ្ទៃក្នុង ដោយមិនគិតពីប្រភេទនៃរដ្ឋាភិបាល ឬកម្រិតនៃការអភិវឌ្ឍន៍របស់រដ្ឋមួយឡើយ។ ដូច្នេះ តួអង្គថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិត្រូវតែអាចទទួលស្គាល់កត្តានានាដែលអាចបង្ហាញអំពីហានិភ័យនៃឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP)។ ការសិក្សាសំខាន់មួយត្រូវបានធ្វើឡើងដើម្បីកំណត់កត្តាទាំងនេះ ដែលឧទាហរណ៍សំខាន់មួយ គឺក្របខ័ណ្ឌវិភាគដែលរៀបចំឡើងដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងទំនួលខុសត្រូវក្នុងការការពារ (អតីតការិយាល័យទីប្រឹក្សាពិសេស ទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍) ដែលចែងអំពីកត្តាចំនួនប្រាំបី - រួមទាំងការរើសអើង ឬការញុះញង់ប្រឆាំងនឹងសហគមន៍ជនជាតិភាគតិច និងវត្តមាននៃអាវុធខុសច្បាប់ក្នុងចំណោមផ្សេងទៀត - ដែលអាចកំណត់ថាតើអាចមានហានិភ័យនៃអំពើប្រល័យពូជសាសន៍ នៅក្នុងស្ថានភាពនៃប្រទេសមួយ ឬយ៉ាងណា។

ទំនួលខុសត្រូវរបស់តួអង្គទាំងអស់ ពង្រីកហួសពីពេលដែលការគំរាមកំហែងចំពោះប្រជាជនលែងមានសក្តានុពលតទៅទៀត និងរួមបញ្ចូលទាំងការដាក់ឲ្យអ្នកប្រព្រឹត្តទទួលខុសត្រូវ ដោយបង្កើតយន្តការនានាសម្រាប់ការកសាងឡើងវិញ និងការសម្រុះសម្រួល និងទប់ស្កាត់ការកើតអំពើហិង្សាជាថ្មី។ ការការពារប្រជាជនពីឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការរំលោភបំពាន តម្រូវឲ្យមានការពង្រឹងសមត្ថភាពទប់ស្កាត់ និងការប្រមូលផ្តុំឆន្ទៈនយោបាយរបស់បណ្តារដ្ឋ អង្គការថ្នាក់តំបន់ និងអង្គការសហប្រជាជាតិ ដើម្បីឆ្លើយតបឲ្យបានឆាប់រហ័សនៅពេលការគំរាមកំហែងនៃឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការរំលោភបំពានកើតមានឡើង។

ការទប់ស្កាត់ពីដើមទីពាក់ព័ន្ធនឹងវិធានការនានាដែលរដ្ឋាភិបាលអាចប្រើប្រាស់នៅក្នុងប្រទេស របស់ខ្លួនដូចជា ការបង្កើតស្ថាប័ន និងគោលនយោបាយ និងការពង្រឹងវិស័យនានា ដែលកាត់បន្ថយហានិភ័យដែលអំពើឃោរឃៅទ្រង់ទ្រាយធំនឹងកើតឡើង។

ការទប់ស្កាត់ចុងទី ពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងការគំរាមកំហែង ដែលនឹងកើតឡើងនៃអំពើឃោរឃៅទ្រង់ទ្រាយធំ។ វិធានការទាំងនេះអាចមានលក្ខណៈសេដ្ឋកិច្ច នយោបាយ មនុស្សធម៌ ឬយោធា និងអាចត្រូវបានធ្វើឡើងដោយតួអង្គនានានៅក្នុងសហគមន៍អន្តរជាតិ រួមទាំងសង្គមស៊ីវិល រដ្ឋាភិបាលនីមួយៗ កិច្ចព្រមព្រៀងថ្នាក់តំបន់ និងថ្នាក់អនុតំបន់ និងស្ថាប័នអង្គការសហប្រជាជាតិ។

## តើមានវិធានការទប់ស្កាត់អ្វីខ្លះ យោងតាមទំនួលខុសត្រូវក្នុងការការពារ (RtoP)?

### វិធានការទប់ស្កាត់ដើមទី

#### សេដ្ឋកិច្ច

- ការកាត់បន្ថយការដកហូតសិទ្ធិ និងភាពក្រីក្រ
- ការកាត់បន្ថយវិសមភាព ជាពិសេស តាមខ្សែផ្តេក
- ការលើកស្ទួយកំណើនសេដ្ឋកិច្ច
- ការគាំទ្រកំណែទម្រង់រចនាសម្ព័ន្ធ
- ការផ្តល់ជំនួយបច្ចេកទេស
- ការកែលម្អលក្ខខណ្ឌពាណិជ្ជកម្ម និងការបើកចំហពាណិជ្ជកម្ម
- ការគាំទ្រការអភិវឌ្ឍន៍សហគមន៍ និងភាពជាម្ចាស់កម្មសិទ្ធិថ្នាក់មូលដ្ឋាន

#### អភិបាលកិច្ច

- ការកសាងសមត្ថភាពស្ថាប័ន និងការធានានូវការផ្តល់សេវាសង្គមកិច្ច
- ការពង្រឹង និងការគាំទ្រលទ្ធិប្រជាធិបតេយ្យ
- ការគាំទ្រការបែងចែក ឬការចែករំលែកអំណាច
- ការពង្រឹងឯករាជ្យភាពនៃតុលាការ
- ការលុបបំបាត់អំពើពុករលួយ
- ការពង្រឹងសមត្ថភាពដោះស្រាយជម្លោះក្នុងស្រុក

#### សិទ្ធិមនុស្ស

- ការការពារសិទ្ធិមនុស្សជាមូលដ្ឋាន និងការកសាងសមត្ថភាពថ្នាក់ជាតិ ជាមួយនឹងការការពារជាក់លាក់ចំពោះសិទ្ធិរបស់ក្រុមជនជាតិភាគតិច ស្ត្រី និងកុមារ
- ការគាំទ្រការងាររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

#### សន្តិសុខ

- ការពង្រឹងនីតិរដ្ឋ
- ការបញ្ចប់/ការទប់ស្កាត់និទណ្ឌភាព
- ការកែទម្រង់វិស័យសន្តិសុខ
- ការលើកទឹកចិត្តឲ្យដកហូតអាវុធ និងការត្រួតពិនិត្យ/ការគ្រប់គ្រងអាវុធប្រកបដោយប្រសិទ្ធភាព ជាមួយនឹងការយោងជាពិសេសដល់អាវុធធុនតូច

#### សង្គមកិច្ច

- ការកសាងទំនុកចិត្តរវាងក្រុម រួមទាំងកិច្ចពិភាក្សាប្រកបដោយការទុកចិត្តគ្នាទៅវិញទៅមក
- ការពង្រឹង និងការគាំទ្រសង្គមស៊ីវិល
- ការបង្កើតសេរីភាពសារព័ត៌មាន

- ការទប់ស្កាត់ និងការផ្តន្ទាទោសសម្តីដែលមានលក្ខណៈញុះញង់ និងស្អប់ខ្ពើម
- ការអប់រំអំពីភាពចម្រុះ និងការអត់ឱន

**ការទូត**

- ការស្វែងរកការពិត
- ការបង្កើត "ក្រុមមិត្តភក្តិ" ក្នុងចំណោមសមាជិកភាពថ្នាក់តំបន់/អង្គការសហប្រជាជាតិ
- ការប្រើប្រាស់បុគ្គលផ្ញើ/បេសកជនសម្រាប់ការសម្របសម្រួល
- ការប្រើប្រាស់មុខតំណែងល្អៗរបស់អគ្គលេខាធិការ ឬប្រធានអង្គការប្រចាំតំបន់
- ការអនុវត្តមជ្ឈត្តការ
- ការគាំទ្រដំណើរការដោះស្រាយជម្លោះជនជាតិតាមតំបន់

**ផ្លូវច្បាប់**

- បញ្ជូនបញ្ហាទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិ
- ស្វែងរកយុត្តិធម៌ តាមរយៈតុលាការយុត្តិធម៌អន្តរជាតិ ឬយន្តការច្បាប់ផ្សេងទៀត។

**ការព្រមានជាមុន**

- ការបង្កើតសមត្ថភាពព្រមាន និងវាយតម្លៃជាមុនថ្នាក់តំបន់ និងអង្គការសហប្រជាជាតិ។

**យោធា**

- ការប្រមូលទ័ពដាក់ពង្រាយបង្ការ
- ការអភិវឌ្ឍន៍ និង/ឬការគំរាមកំហែងសមត្ថភាពដាក់ពង្រាយទ័ពឆាប់រហ័ស
- ការបង្ការ និងមធ្យោបាយទប់ស្កាត់ការញុះញង់ផ្សេងទៀត។

**គ្រឿងលើកទឹកចិត្ត**

- ការលើកកម្ពស់គ្រឿងលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម
- ការផ្តល់គ្រឿងលើកទឹកចិត្តផ្នែកនយោបាយ។

**ទណ្ឌកម្ម**

- ការហាមឃាត់លើការធ្វើដំណើរ
- ការដាក់ទណ្ឌកម្មពាណិជ្ជកម្ម និងអាវុធ
- ការបង្កកទ្រព្យសម្បត្តិ (ការទប់ស្កាត់ការប្រើប្រាស់ទ្រព្យសម្បត្តិ)
- ការដាក់ទណ្ឌកម្មការទូត។

** តារាងទាំងនេះបានមកពី Alex Bellamy "អំពើឃោរឃៅទ្រង់ទ្រាយធំ និងជម្លោះប្រដាប់អាវុធ៖ ភាពលេចធ្លោ និងផលវិបាកសម្រាប់ទំនួលខុសត្រូវក្នុងការការពារ" មូលនិធិ Stanley ខែកុម្ភៈ ឆ្នាំ២០១១។

## តើទំនួលខុសត្រូវក្នុងការការពារ (RtoP) និយាយអ្វីខ្លះអំពីការប្រើប្រាស់កម្លាំង?

ក្នុងករណីដែលរដ្ឋមួយខកខានមិនបានទប់ស្កាត់អំពើឃោរឃៅទ្រង់ទ្រាយធំនៅក្នុងព្រំប្រទល់របស់ខ្លួន និងប្រសិនបើមធ្យោបាយការទូត មនុស្សធម៌ និងមធ្យោបាយសន្តិវិធីផ្សេងទៀត មានភាពមិនគ្រប់គ្រាន់ ក្រុមប្រឹក្សាសន្តិសុខអាចអនុញ្ញាតឲ្យប្រើប្រាស់កម្លាំងរួមគ្នា ដើម្បីការពារជនស៊ីវិលពីអំពើឃោរឃៅទ្រង់ទ្រាយធំ។

ទំនួលខុសត្រូវក្នុងការការពារ (RtoP) ព្យាយាមសង្កត់ធ្ងន់លើដែនកំណត់ដែលមានស្រាប់ ស្របតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ពេលវេលា និងរបៀបដែលអន្តរាគមន៍មួយអាចត្រូវបានធ្វើឡើង ដើម្បីទប់ស្កាត់អន្តរាគមន៍យោធាជាឯកតោភាគី ឬពហុភាគីដែលគ្មានការអនុញ្ញាត ជាញឹកញាប់ ត្រូវបានកំណត់ថាជា "អន្តរាគមន៍មនុស្សធម៌"។

ទោះជាយ៉ាងណាក៏ដោយ ការព្រមព្រៀងមតិមិនទាន់អាចសម្រេចបាន ទាក់ទងនឹងតម្លៃបន្ថែមនៃលក្ខណៈវិនិច្ឆ័យបន្ថែម ដើម្បីណែនាំការប្រើប្រាស់កម្លាំង ដើម្បីឆ្លើយតបទៅនឹងឧក្រិដ្ឋកម្ម និងការរំលោភបំពាន ទំនួលខុសត្រូវក្នុងការការពារ (RtoP) នៅឡើយទេ ហើយមានការសម្តែងកង្វល់ថា គោលការណ៍ណែនាំទាំងនេះអាចនាំទៅរក ឬថែមទាំងធ្វើឲ្យស្របច្បាប់ចំពោះការមិនចាត់វិធានការ។

របាយការណ៍គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) ឆ្នាំ២០០១ បានស្នើឡើងនូវលក្ខណៈវិនិច្ឆ័យនានា រួមទាំង "គោលការណ៍ប្រុងប្រយ័ត្ន" បួនយ៉ាង ដែលត្រូវពិចារណាមុនពេលអនុញ្ញាតឲ្យមានការប្រើប្រាស់កម្លាំង ប៉ុន្តែ លក្ខណៈវិនិច្ឆ័យទាំងនេះមិនត្រូវបានអនុម័ត ឬពិចារណាល្អិតល្អន់ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឬដោយរដ្ឋជាសមាជិកនៅក្នុងអង្គការសហប្រជាជាតិឡើយ។

"គោលការណ៍ប្រុងប្រយ័ត្ន" ដែលស្នើឡើងដោយរបាយការណ៍គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS)៖

- **ចេតនាត្រឹមត្រូវ៖** "គោលបំណងចម្បងនៃការធ្វើអន្តរាគមន៍ គឺបញ្ឈប់បញ្ចៀសទុក្ខវេទនារបស់មនុស្ស"។
- **ជម្រើសចុងក្រោយ៖** រាល់ជម្រើសមិនមែនយោធាទាំងអស់សម្រាប់ការទប់ស្កាត់ ឬដំណោះស្រាយដោយសន្តិវិធីនៃវិបត្តិ [ចាំបាច់ត្រូវ] ស្វែងរក ជាមួយមូលដ្ឋានសមស្របសម្រាប់ការជឿថា វិធានការកម្រិតតិចជាងនេះនឹងពុំទទួលបានជោគជ័យឡើយ។
- **មធ្យោបាយដែលមានសមាមាត្រ៖** "ទំហំ រយៈពេល និងភាពខ្លាំងក្លានៃអន្តរាគមន៍យោធាដែលគ្រោងទុក គួរតែជាអន្តរាគមន៍ចាំបាច់អប្បបរមា ដើម្បីធានានូវវត្ថុបំណងមនុស្សធម៌ដែលពាក់ព័ន្ធ"។
- **ការរំពឹងចង់បានសមស្រប៖** "ត្រូវតែមានឱកាសសមស្របនៃភាពជោគជ័យនៅក្នុងការបញ្ឈប់ ឬការបញ្ចៀសទុក្ខវេទនាដែលតម្រូវឲ្យមានអន្តរាគមន៍ ដោយផលវិបាកនៃវិធានការទំនងជាមិនអាក្រក់ជាងផលវិបាកនៃការមិនចាត់វិធានការ"។

របាយការណ៍គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរបស់រដ្ឋ (ICISS) ក៏ពិភាក្សាផងដែរអំពីលក្ខណៈវិនិច្ឆ័យបន្ថែម រួមទាំង**សិទ្ធិអំណាចត្រឹមត្រូវ**ដែលក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ចាំបាច់ត្រូវជាស្ថាប័នអនុញ្ញាតសម្រាប់កម្លាំងយោធា និង**មូលហេតុត្រឹមត្រូវ** ដែលថា កម្លាំងអាចត្រូវបានពិចារណាក្នុងករណី ឬការគំរាមកំហែងដែលអាចកើតឡើងនៃ "ការបាត់បង់ជីវិត ឬការលុបបំបាត់ជាតិសាសន៍ទ្រង់ទ្រាយធំ" ប៉ុណ្ណោះ។

ខាងក្រោម គឺជាឧទាហរណ៍នៃរបៀបដែលទំនួលខុសត្រូវក្នុងការការពារ (RtoP) បានអនុវត្ត ឬមិនអនុវត្ត ចំពោះស្ថានភាពប្រទេសកាលពីពេលថ្មីៗ នៅពេលដែលប្រជាជនបានជួបប្រទះការគំរាមកំហែងនៃអំពើឃោរឃៅទ្រង់ទ្រាយធំ។ ករណីទាំងនេះបង្ហាញនូវវិធានការមួយចំនួន ដែលមានចំពោះរដ្ឋ និងសហគមន៍អន្តរជាតិ នៅពេលឆ្លើយតបទៅនឹងការគំរាមកំហែងនានា ប៉ុន្តែ បញ្ជីនេះមិនមានលក្ខណៈលម្អិតគ្រប់ជ្រុងជ្រោយឡើយ។

**សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (DRC) ៖** ទោះបីជាសង្គ្រាមស៊ីវិលនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (DRC) បានបញ្ចប់ក្នុងឆ្នាំ២០០៣ ជាមួយនឹងការបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នក៏ដោយ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងប្រជាជនស៊ីវិល - រួមទាំងឃាតកម្ម ការរំលោភសេពសន្ថវៈ និងទាសភាពផ្លូវភេទ ការជ្រើសរើសទាហានកុមារ និងការជម្លៀសដោយបង្ខំ - នៅតែបន្តមានលក្ខណៈខ្លាំងក្លាដដែល។ សហគមន៍អន្តរជាតិបានចាត់វិធានការនានា ដើម្បីបំពេញទំនួលខុសត្រូវរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងអំពើឃោរឃៅជាបន្ត និងការកសាងឡើងវិញ ប៉ុន្តែ ការព្យាយាមលុបបំបាត់វិបត្តិមនុស្សធម៌ និងការអនុវត្តដំណើរការសន្តិភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (DRC) មានការរីកចម្រើនយ៉ាងយឺតៗ។

**ស៊ូដង់៖ ដាហ្វួរ** ក្នុងឆ្នាំ២០០៣ រដ្ឋាភិបាលស៊ូដង់បានឆ្លើយតបទៅនឹងការបះបោរនៅតំបន់ដាហ្វួរ នៃប្រទេសស៊ូដង់ និងបានចាប់ផ្តើមយុទ្ធនាការគួរឲ្យរន្ធត់ប្រឆាំងជនស៊ីវិល ដោយសម្លាប់ប្រជាជនអស់ជាង ៣០០,០០០ នាក់ និងជម្លៀសប្រជាជននៅដាហ្វួរ ជាងបីលាននាក់។ នៅពេលវិបត្តិបន្តកើតមានចូលដល់ឆ្នាំទីដប់របស់ខ្លួន ការវាយប្រហារពីសំណាក់រដ្ឋាភិបាលស៊ូដង់ និងកងជីវពលតំណាងរបស់ខ្លួនកំពុងតែបន្ត ហើយជនស៊ីវិលនៅតែស្ថិតក្នុងហានិភ័យនៃការទម្លាក់គ្រាប់បែកតាមអាកាស និងការវាយប្រហារតាមផ្លូវគោកដដែល។ ដោយសារសហភាពអាហ្វ្រិក និងបុគ្គលិកអង្គការសហប្រជាជាតិរួមគ្នានៅក្នុងតំបន់នោះ ខ្វះខាតធនធាន ដើម្បីធានាសន្តិសុខរបស់ប្រជាជន ប្រជាជនស៊ីវិលកំពុងស្ថិតក្រោមការគំរាមកំហែងបន្ថែម និងកើនឡើងនៃការលួចប្លន់ និងអំពើហិង្សាផ្អែកលើយេនឌ័រពីសំណាក់ចលនាឧទ្ទាម។

**ហ្គាសា (២០០៨-២០០៩)៖** បរាជ័យនៃបទឈប់បាញ់ និងការវាយប្រហារដោយយោធាមួយក្នុងខែធ្នូ ឆ្នាំ២០០៨ រវាងអ៊ីស្រាអែល និងហាម៉ាស បានបង្កឲ្យមានវិបត្តិមួយ ដែលភាគីទាំងសងខាងត្រូវបានចោទប្រកាន់ពីបទរំលោភបំពានច្បាប់ស្តីពីសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ។ ប្រជាជនស៊ីវិល គឺជាជនរងគ្រោះមួយភាគធំ នៅពេលវិបត្តិនេះបានឆក់យកជីវិតជាង ១,៣០០ នាក់ និងធ្វើឲ្យរបួសប្រជាជនជាង ៥,៤០០ នាក់។ ទោះបីជាស្ថិរភាពត្រូវបានស្តារឡើងវិញនៅដើមឆ្នាំ២០១៣ ក៏ដោយ អ៊ីស្រាអែលបានបិទខ្ទប់តំបន់ហ្គាសា ដោយអនុញ្ញាតចំពោះតែសេចក្តីត្រូវការចាំបាច់ប៉ុណ្ណោះ ដូចជា អាហារ និងឱសថ និងរារាំងកិច្ចប្រឹងប្រែងស្តារឡើងវិញ និងអភិវឌ្ឍន៍រយៈពេលវែង។ សំណួរនានានៅតែបន្តកើតមានទាក់ទងនឹងកម្រិតដែលបទឧក្រិដ្ឋដែលប្រព្រឹត្ត មានលក្ខណៈរាលដាល និងជាប្រព័ន្ធ និងអំពីថាតើការអនុវត្តន៍ទំនួលខុសត្រូវក្នុងការការពារ (RtoP) នឹងនាំមកនូវការផ្លាស់ប្តូរដែលត្រូវការ ដើម្បីការពារប្រជាជនស៊ីវិល នៅក្នុងស្ថានភាពនយោបាយធ្ងន់ធ្ងរនេះដែរឬយ៉ាងណា។ ភាពតានតឹងយ៉ាងខ្លាំងបន្តឈានដល់ការប៉ះទង្គិចដោយហិង្សារវាងកងទ័ពអ៊ីស្រាអែល និងកងកម្លាំងហាម៉ាស នៅហ្គាសា កាលពីពេលថ្មីៗបំផុតនៅចុងឆ្នាំ២០១២ ដែលក្នុងអំឡុងពេលនោះ ភាគីទាំងពីរត្រូវបានចោទប្រកាន់ពីបទរំលោភសិទ្ធិមនុស្ស។

## ទំនួលខុសត្រូវក្នុងការការពារ (RtoP) នៅក្នុងស្ថានភាពនៃវិបត្តិ

**ប្រទេសកេនយ៉ា (២០០៧-២០០៨) ៖** ក្រោយពីរលកនៃអំពើហិង្សានៅក្នុងប្រទេសកេនយ៉ា ដែលបង្កឡើងដោយវិវាទក្នុងការបោះឆ្នោតប្រធានាធិបតី ក្នុងខែធ្នូ ឆ្នាំ២០០៧ ប្រតិកម្មដ៏ឆាប់រហ័ស និងមានការសម្របសម្រួលពីសំណាក់សហគមន៍អន្តរជាតិ ដើម្បីសម្រេចបានដំណោះស្រាយនយោបាយ បានតម្រូវឲ្យមានក្រុមសម្របសម្រួលមួយ ដែលអនុញ្ញាតដោយសហភាពអាហ្វ្រិក ដើម្បីសម្រេចបានកិច្ចព្រមព្រៀងបែងចែកអំណាច។ ប្រការនេះត្រូវបានកោតសរសើរថាជា "គំរូនៃសកម្មភាពការទូត យោងតាមទំនួលខុសត្រូវក្នុងការការពារ (RtoP)" ពីសំណាក់អង្គការសង្គមស៊ីវិលជាច្រើន។ ទោះជាយ៉ាងណាក៏ដោយក្នុងការឈានឆ្ពោះទៅរកការបោះឆ្នោតប្រធានាធិបតី ឆ្នាំ២០១៣ ដោយពិចារណាលើប្រវត្តិនៃអំពើហិង្សាទាក់ទងនឹងការបោះឆ្នោតនៃប្រទេសកេនយ៉ា និងការណ៍ដែលថា បេក្ខជនពីររូបបានប្រឈមការចោទប្រកាន់ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយសារតួនាទីរបស់ពួកគេនៅក្នុងអំពើហិង្សា ឆ្នាំ២០០៧ សហភាពអាហ្វ្រិក និងសង្គមស៊ីវិលទូទាំងពិភពលោកបានចាត់វិធានការពិនិត្យតាមដាន និងធានាសុវត្ថិភាពរបស់ប្រជាជន ក្នុងអំឡុងពេលបោះឆ្នោត។

**ប្រទេសស្រីលង្កា (២០០៨-២០០៩) ៖** ក្នុងអំឡុងដំណាក់កាលចុងក្រោយនៃសង្គ្រាមស៊ីវិលនៅស្រីលង្កា អំពើហិង្សាបានកើនឡើងយ៉ាងខ្លាំងជាមួយនឹងការប៉ះទង្គិចនានា ដែលធ្វើឲ្យប្រជាជនស៊ីវិលរាប់សែននាក់ជាប់ក្នុងអន្ទាក់ ដោយពុំមានលទ្ធភាពទទួលបានតម្រូវការចាំបាច់ជាមូលដ្ឋាន ឬជំនួយមនុស្សធម៌ឡើយ។ ទោះបីជារដ្ឋាភិបាលស្រីលង្កា បានអះអាងថា វិធានការរបស់ខ្លួន មានគោលបំណងបញ្ឈប់សកម្មភាពភេរវកម្មក៏ដោយ ក៏ទីបំផុតខ្លួនទទួលខុសត្រូវចំពោះការស្លាប់ប្រជាជនស៊ីវិលក្នុងចំនួនដ៏ច្រើន និងបានខកខានមិនបានគោរពកាតព្វកិច្ចរបស់ខ្លួន យោងតាមទំនួលខុសត្រូវក្នុងការការពារ (RtoP)។ នៅពេលនោះដែរ អង្គការសង្គមស៊ីវិលជាច្រើនបានរិះគន់អង្គការសហប្រជាជាតិ ដោយសារកិច្ចប្រឹងប្រែងតិចតួចរបស់ខ្លួន ក្នុងការដាក់ឲ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ក្រោយមក របាយការណ៍មួយរបស់អង្គការសហប្រជាជាតិបានសន្និដ្ឋានថា ករណីនោះបានបង្ហាញនូវ "បរាជ័យដ៏ធ្ងន់ធ្ងររបស់អង្គការសហប្រជាជាតិ ក្នុងការឆ្លើយតបឲ្យបានគ្រប់គ្រាន់ ទៅនឹងការព្រមានជាមុន និងស្ថានភាពដែលកំពុងវិវត្ត"។

**ប្រទេសហ្គីណេ (២០០៩) ៖** នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៩ កម្លាំងរដ្ឋាភិបាលនៅក្នុងប្រទេសហ្គីណេ បានរារាំងការតវ៉ាផ្នែកនយោបាយដោយសន្តិវិធីមួយនៅក្នុងពហុកីឡាដ្ឋានមួយក្នុងទីក្រុងកូណាគ្រី និងបានបើកការបាញ់ប្រហារលើជនស៊ីវិល ដែលបណ្តាលឲ្យស្លាប់ជនស៊ីវិលអស់ជាង ១៥០ នាក់ រងរបួសយ៉ាងហោចណាស់ ១,៤០០ នាក់ និងការរាយការណ៍អំពីអំពើហិង្សាផ្លូវភេទ និងការរំលោភសេពសន្ថវៈយ៉ាងរីករាលដាល។ អំពើហិង្សានៅថ្ងៃនោះ ដែលត្រូវបានចោទប្រកាន់ថា មានទម្ងន់ស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយការព្រួយបារម្ភ ដែលថា សមាជិកឯករាជ្យនៃរដ្ឋាភិបាលយោធាដែលកាន់អំណាចបានប្រមូលផ្តុំកងជីវពលឯកជនពីក្នុងចំណោមខ្សែស្រឡាយជាតិសាសន៍ មុនពេលវាយប្រហារបានកើតមានឡើង។ សហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិច និងសហភាពអាហ្វ្រិក បានផ្តួចផ្តើមកិច្ចប្រឹងប្រែងសម្រុះសម្រួលបន្ទាន់មួយ និងបានដាក់ទណ្ឌកម្មសេដ្ឋកិច្ច ជាវិធានការដែលនាំទៅរកការបង្កើតរដ្ឋាភិបាលឯកភាពមួយយ៉ាងឆាប់រហ័ស។ ចាប់តាំងពីពេលនោះមក សហគមន៍ថ្នាក់តំបន់ត្រូវបានកោតសរសើរចំពោះការជួយសម្រួលឲ្យមានដំណោះស្រាយនយោបាយឆាប់រហ័ស ចំពោះអ្វីដែលអាចរីកធំឡើង ក្លាយជាជម្លោះធ្ងន់ធ្ងរយូរអង្វែង។

## ទំនួលខុសត្រូវក្នុងការការពារ (RtoP) នៅក្នុងស្ថានភាពនៃវិបត្តិ

**ប្រទេសកូដឌីវ័រ (២០១០-២០១១) ៖** អំពើហិង្សាបានផ្ទុះឡើងក្រោយពីការបោះឆ្នោតប្រធានាធិបតី ក្នុងឆ្នាំ ២០១០ ដែលបណ្តាលឲ្យជនស៊ីវិលស្លាប់ក្នុងចំនួនដ៏ច្រើន និងការជម្លៀសមនុស្សដ៏សន្ធឹកសន្ធាប់។ សហគមន៍អន្តរជាតិបានឆ្លើយតបយ៉ាងឆាប់រហ័សជាមួយនឹងទណ្ឌកម្មសេដ្ឋកិច្ច និងការអំពាវនាវឲ្យមានកំណែទម្រង់នយោបាយ។ នៅពេលជម្លោះកើនឡើងជាមួយនឹងអំពើឃោរឃៅទ្រង់ទ្រាយធំដែលរីករាលដាល ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបោះឆ្នោតជាឯកច្ឆ័ន្ទ ដើម្បីពង្រឹងបេសកកម្មរបស់អង្គការសហប្រជាជាតិតាមផ្លូវគោក ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការការពារប្រជាជនស៊ីវិល។ ទោះបីជាការគំរាមកំហែងនៃអំពើហិង្សាជាបឋមលើប្រជាជនត្រូវបានបញ្ឈប់ក៏ដោយ ក៏វប្បធម៌និទណ្ឌភាពនៅតែបន្តកើតមាន ដោយសារប្រវត្តិឧក្រិដ្ឋកម្មដ៏ធំធេងនៅតែមិនត្រូវបានស៊ើបអង្កេតដោយរដ្ឋាភិបាលជាតិ។

**ប្រទេសស៊ូដង់ខាងត្បូង ៖** អំពើហិង្សាអន្តរសហគមន៍នៅរដ្ឋ Jonglei រវាងក្រុមជាតិសាសន៍ Lou Nuer និង Murle បានចាប់ផ្តើមអស់រយៈពេលពីរបីខែ ក្រោយពីប្រទេសស៊ូដង់ខាងត្បូងបានទទួលឯករាជ្យ នៅខែកក្កដា ឆ្នាំ២០១១។ ការវាយបង្ក្រាបលើសត្វពាហនៈមួយចំនួន និងការវាយប្រហារសងសឹងរវាងសហគមន៍ទាំងពីរបាននាំឲ្យមនុស្សជាងមួយពាន់នាក់បាត់បង់ជីវិត និងជាច្រើននាក់ផ្សេងទៀតបានភៀសខ្លួន។ ទោះបីជារដ្ឋាភិបាលស៊ូដង់ខាងត្បូង បានចាប់ផ្តើមយុទ្ធនាការដកហូតអាវុធ ពង្រាយទ័ព និងសម្របសម្រួលកិច្ចចរចារវាងក្រុមទាំងពីរក៏ដោយ ហានិភ័យនៃអំពើហិង្សាប្រឆាំងនឹងប្រជាជនដោយសារភាពតានតឹងអន្តរសហគមន៍នៅតែបន្តកើតមានដដែល។ ក្នុងការក្លាយជារដ្ឋដែលមានឯករាជ្យ និងអធិបតេយ្យភាព រដ្ឋាភិបាលស៊ូដង់ខាងត្បូងបានទទួលយកទំនួលខុសត្រូវក្នុងការការពារប្រជាជនរបស់ខ្លួនពីឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការរំលោភបំពាន។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលិកមកពីក្រុមប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដែលបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខ ដើម្បី "ណែនាំ និងជួយ" រដ្ឋាភិបាលក្នុងការបំពេញទំនួលខុសត្រូវរបស់ខ្លួនក្នុងការពារ បានរាយការណ៍ថា កងទ័ពស៊ូដង់ខាងត្បូង បានប្រព្រឹត្តការសម្លាប់ក្រៅប្រព័ន្ធតុលាការ ការធ្វើទារុណកម្ម និងការរំលោភសេពសន្ថវៈក្នុងអំឡុងយុទ្ធនាការដកហូតអាវុធ។

**ប្រទេសស៊ូដង់ ៖ SOUTH KORDOFAN និង BLUE NILE៖** ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១១ កងកម្លាំងប្រដាប់អាវុធស៊ូដង់ (SAF) បានវាយប្រយុទ្ធប្រឆាំងនឹងចលនារំដោះប្រជាជនស៊ូដង់ - ខាងជើង (SPLM-N) ដោយធ្វើការទម្លាក់គ្រាប់បែកតាមផ្លូវអាកាសមិនរើសមុខ និងការវាយប្រហារផ្លូវគោក ដែលទំនងជាមានទម្ងន់ស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រឆាំងជនស៊ីវិលនៅក្នុងបណ្តារដ្ឋនៃ SOUTH KORDOFAN និង BLUE NILE។ ចលនារំដោះប្រជាជនស៊ូដង់ - ខាងជើង (SPLM-N) ក៏ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំផងដែរ ទោះជាមានកម្រិតស្រាលជាងកងកម្លាំងប្រដាប់អាវុធស៊ូដង់ (SAF) ក៏ដោយ។ ទោះបីជាសម្ព័ន្ធរដ្ឋអាហ្វ្រិក សហភាពអាហ្វ្រិក និងអង្គការសហប្រជាជាតិបានសម្រេចកិច្ចព្រមព្រៀងមួយក្នុងឆ្នាំ២០១២ ដើម្បីជួយប្រជាជនស៊ូដង់ឲ្យទទួលបានជំនួយមនុស្សធម៌ក៏ដោយ វិធានការជាក់ស្តែងឆ្ពោះទៅរកការអនុវត្តកិច្ចព្រមព្រៀង មិនត្រូវបានធ្វើឡើងឡើយ។ កងកម្លាំងប្រដាប់អាវុធស៊ូដង់ (SAF) និងចលនារំដោះប្រជាជនស៊ូដង់ - ខាងជើង (SPLM-N) ត្រូវតែបញ្ឈប់ឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំដែលកំពុងបន្ត និងត្រូវបានដាក់ឲ្យទទួលខុសត្រូវដោយសហគមន៍អន្តរជាតិ ចំពោះបរាជ័យរបស់ពួកគេ ក្នុងការអនុញ្ញាតឲ្យមានលទ្ធភាពទទួលបានជំនួយមនុស្សធម៌។

**ប្រទេសយេមែន (ឆ្នាំ២០១១) ៖** កងកម្លាំងសន្តិសុខដែលគាំទ្ររដ្ឋាភិបាលនៅក្នុងប្រទេសយេមែនបានសម្លាប់ និងធ្វើឲ្យរងរបួសដល់ជនស៊ីវិលរាប់រយនាក់ ខណៈពេលមានការបង្ក្រាបលើការតវ៉ាប្រឆាំងរដ្ឋាភិបាល ដែលចាប់ផ្តើមក្នុងខែមករា ឆ្នាំ២០១១។ អ្នកតវ៉ាទាំងឡាយទទួលរងនូវការវាយប្រហារជាច្រើនលើកច្រើនសារ នៅពេលមានជម្លោះរវាងកងកម្លាំងដែលគាំទ្ររដ្ឋាភិបាល និងប្រឆាំងរដ្ឋាភិបាលបានកើនឡើងដល់មាត់ជ្រោះនៃសង្គ្រាមស៊ីវិល។ ដើម្បីបញ្ឈប់អំពើឃោរឃៅដែលកំពុងកើតមាន ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ បានចរចាកិច្ចព្រមព្រៀងសន្តិភាពមួយ ដែលអនុញ្ញាតឲ្យប្រធានាធិបតីមានអភ័យឯកសិទ្ធិពីការផ្តន្ទាទោស ជាថ្នូរនឹងការចុះចេញពីអំណាចរបស់ខ្លួន។ កិច្ចព្រមព្រៀងនេះបានទទួលការរិះគន់ ដោយសារការបំផ្លាញទំនួលខុសត្រូវ និងការអនុញ្ញាតឲ្យមាននិទណ្ឌភាពសម្រាប់អំពើហិង្សាទ្រង់ទ្រាយធំ ប៉ុន្តែ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ព្រមទាំងសហគមន៍អន្តរជាតិជាច្រើន ក្នុងខែតុលា ឆ្នាំ២០១១។

**ប្រទេសលីប៊ី (ឆ្នាំ២០១១-២០១២) ៖** ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងរបស់អតីតមេដឹកនាំលីប៊ី Muammar Gaddafi ប្រឆាំងនឹងប្រជាជនស៊ីវិលលីប៊ី (រំឭកភាសាដែលប្រើដោយបុគ្គលទាំងឡាយដែលបានញុះញង់ឲ្យមានអំពើហិង្សាក្នុងអំឡុងរបបប្រល័យពូជសាសន៍នៅរ្វ៉ាន់ដា ក្នុងឆ្នាំ១៩៩៤) សហគមន៍អន្តរជាតិ និងថ្នាក់តំបន់បានចាត់វិធានការសេដ្ឋកិច្ច នយោបាយ ច្បាប់ និងបន្ទាប់មក វិធានការយោធាដែលត្រូវបានអនុញ្ញាតដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់ Gaddafi កុំឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនតទៅទៀត។ មានការកើតឡើងនូវភាពចម្រូងចម្រាសលើយុទ្ធសាស្រ្តដែលបានប្រើប្រាស់ក្នុងអំឡុងប្រតិបត្តិការយោធា និងបញ្ហាអំពីថាតើរដ្ឋដែលធ្វើអន្តរាគមន៍បានធ្វើសកម្មភាព ដើម្បីការពារប្រជាជន ឬធ្វើឲ្យមានការកើតឡើងនូវការផ្លាស់ប្តូររបបដែរឬទេ។ ទោះបីជាយ៉ាងណាក៏ដោយ សហគមន៍អន្តរជាតិ បានទទួលការកោតសរសើរយ៉ាងខ្លាំងចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការប្រកាន់យកទំនួលខុសត្រូវក្នុងការការពាររបស់ខ្លួន ដោយចាត់វិធានការយ៉ាងឆាប់រហ័ស ប្រើប្រាស់វិធានការជាច្រើន ដើម្បីការពារជនស៊ីវិល។ ជម្លោះបានបង្ហាញអំពីសារៈសំខាន់នៃការដោះស្រាយកង្វល់ ជាមួយនឹងការអនុវត្តដោយគ្មានការប្តេជ្ញាចិត្តគួរឲ្យចាប់អារម្មណ៍ក្នុងការការពារប្រជាជនពីឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP)។ ក្រោយជម្លោះប្រដាប់អាវុធ នៅពេលប្រទេសលីប៊ី ធ្វើការ ដើម្បីកសាងឡើងវិញ លើកស្ទួយគណនេយ្យភាព និងបង្កើតស្ថាប័ននានា ដើម្បីធានានូវការការពារជនស៊ីវិល ទំនួលខុសត្រូវក្នុងការជួយជ្រោមជ្រែងរបស់សហគមន៍អន្តរជាតិ និងថ្នាក់តំបន់បន្តកើតមាន។

**ប្រទេសស៊ីរី ៖** ការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបានចាប់ផ្តើមក្នុងខែមីនា ឆ្នាំ២០១១ នៅពេលកងកម្លាំងសន្តិសុខស៊ីរី បានឆ្លើយតបយ៉ាងហិង្សាទៅនឹងអ្នកតវ៉ាជាជនស៊ីវិល។ ភ័ស្តុតាងនៃអំពើឃោរឃៅដែលមានលក្ខណៈជាប្រព័ន្ធរួមទាំងការធ្វើទារុណកម្ម និងការចាប់ខ្លួនតាមអំពើចិត្ត បានចង្អុលបង្ហាញអំពីគោលនយោបាយច្បាស់លាស់មួយដោយថ្នាក់ដឹកនាំយោធា និងស៊ីវិលរបស់ស៊ីរី ដែលមានទម្ងន់ស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមគណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកការស៊ើបសួរ។ ជម្លោះកាន់តែមានស្ថានភាពអាក្រក់ និងប្រែក្លាយទៅជាសង្គ្រាមស៊ីវិល ដោយកម្លាំងសន្តិសុខ និងក្រុមប្រឆាំងប្រដាប់អាវុធត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម។ វាក៏បានក្លាយជាមានលក្ខណៈសាសនាកាន់តែខ្លាំងឡើង នៅពេលការវាយប្រហារសងសឹកកាន់តែខ្លាំង បានបែងចែករវាងសហគមន៍ជាតិសាសន៍នានា។ នៅពេលដែលអំពើឃោរឃៅនៅតែបន្ត សហគមន៍អន្តរជាតិបានមានប្រតិកម្ម ដោយប្រើវិធានការសេដ្ឋកិច្ច ការទូត និងនយោបាយ ប៉ុន្តែ បរាជ័យរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិក្នុងការឯកភាពលើវិធានការខ្លាំងក្លាជាងនេះ និងការប្រើប្រាស់សិទ្ធិវេតូម្តងហើយ

ម្តងទៀត ដោយសមាជិកក្រុមប្រឹក្សាសន្តិសុខមួយចំនួន បានបង្កើតឲ្យមានការរិះគន់យ៉ាងខ្លាំងពីសំណាក់បណ្តារដ្ឋ មន្ត្រីអង្គការសហប្រជាជាតិ និងសង្គមស៊ីវិល។

**សាធារណរដ្ឋអាហ្វ្រិកកណ្តាល (CAR) ៖** វិបត្តិបានផ្ទុះឡើងនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាលក្នុងខែមីនា ឆ្នាំ២០១៣ នៅពេលក្រុមសកម្មប្រយុទ្ធ Seleka បានដឹកនាំការធ្វើរដ្ឋប្រហារដោយហិង្សាមួយនៅក្នុងប្រទេស។ Seleka (ដែលភាគច្រើនជាអ្នកកាន់សាសនាឥស្លាម) បានទទួលខុសត្រូវចំពោះការស្លាប់របស់ជនស៊ីវិល និងការវាយប្រហារដែលរីករាលដាលនៅតាមភូមិនានា។ អំពើហិង្សារបស់ Seleka បានជំរុញឲ្យមានការលេចឡើងនៃកងជីវពល "ប្រឆាំង balaka" ដែលមានសមាសភាពចម្បងជាអ្នកកាន់សាសនាគ្រិស្ត និងភាគីវិញ្ញាណនិយមបានប្រឆាំងទៅនឹងការគ្រប់គ្រងរបស់កងជីវពល Seleka។ កងជីវពលប្រឆាំង balaka បានទទួលខុសត្រូវចំពោះការវាយប្រហារគួរឲ្យរន្ធត់ទៅលើសហគមន៍ឥស្លាម។ ជម្លោះជាតិសាសន៍-សាសនានៅសាធារណរដ្ឋអាហ្វ្រិកកណ្តាលបានឆក់យកជីវិតមនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់ និងបង្ហាញនូវហានិភ័យខ្ពស់នៃការលុបបំបាត់ជាតិសាសន៍ និងអំពើហិង្សាប្រល័យពូជសាសន៍។ សហគមន៍អន្តរជាតិបានឆ្លើយតប ដោយធ្វើការថ្កោលទោសការឃោសនាឲ្យមានការស្អប់ខ្ពើមនៅក្នុងប្រទេស អនុញ្ញាតឲ្យមានកម្លាំងអន្តរាគមន៍បណ្តោះអាសន្នរបស់បារាំង និងអនុញ្ញាតឲ្យកងកម្លាំងរក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ដែលមកពីច្រើនផ្នែក ជាមួយនឹងអាណត្តិការពារជនស៊ីវិល។ ស្ថានភាពនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាលនៅតែធ្ងន់ធ្ងរ ហើយកង្វះមូលនិធិ គឺជាឧបសគ្គចម្បងមួយចំពោះកិច្ចខិតខំប្រឹងប្រែងសង្គ្រោះផ្នែកមនុស្សធម៌ និងបានពន្យារការអនុញ្ញាត និងការអនុវត្តបេសកកម្មរក្សាសន្តិភាពខ្លាំងក្លា ដើម្បីការពារជនស៊ីវិល។

## ទំនួលខុសត្រូវក្នុងការការពារ (RtoP) នៅក្នុងស្ថានភាពនៃវិបត្តិ

### ការប្រើប្រាស់ទំនួលខុសត្រូវក្នុងការការពារ (RtoP) ដោយមិនត្រឹមត្រូវ

**ប្រទេសចចេៀ (ឆ្នាំ២០០៨)៖** ក្នុងខែសីហា ឆ្នាំ២០០៨ ប្រទេសរុស្ស៊ី បានចាប់ផ្តើមបេសកកម្មយោធាជាឯកតោភាគីមួយនៅក្នុងប្រទេសចចេៀ ដោយអះអាងថា ដើម្បីការពារពលរដ្ឋរុស្ស៊ី ពីអ្វីដែលរដ្ឋាភិបាលហៅថា អំពើប្រល័យពូជសាសន៍នៅតំបន់ Ossetia ខាងត្បូងនៃប្រទេស។ នៅពេលនោះ ប្រទេសរុស្ស៊ីបានពន្យល់មូលហេតុនៃវិធានការរបស់ខ្លួន ដោយនិយាយថា ខ្លួនកំពុងប្រកាន់យកទំនួលខុសត្រូវរបស់ខ្លួន ក្នុងការការពារពលរដ្ឋរបស់ខ្លួន។ ហេតុផលនេះត្រូវបានប្រឆាំង ដោយសារវាមានភាពមិនច្បាស់លាស់ថាតើកម្រិតនៃការគំរាមកំហែង គឺជាអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំ ឬថាតើកម្លាំងយោធា គឺជាវិធានការសមស្របដែរឬយ៉ាងណា។ ជាងនេះទៅទៀត យោងតាមទំនួលខុសត្រូវក្នុងការការពារ (RtoP) ដូចដែលត្រូវបានអនុម័តនៅក្នុងឯកសារលទ្ធផលនៃជំនួបកំពូលពិភពលោក ឆ្នាំ២០០៥ វិធានការយោធា ដើម្បីការពារជនស៊ីវិលពីឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP)នៅក្រៅព្រំដែននៃប្រទេសមួយ ត្រូវតែធ្វើឡើងរួមគ្នា និងស្របតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

**ប្រទេសភូមា/មីយ៉ាន់ម៉ា (ឆ្នាំ២០០៨)៖** មហន្តរាយធម្មជាតិមិនស្ថិតនៅក្នុងវិសាលភាពនៃទំនួលខុសត្រូវក្នុងការការពារ (RtoP) ឡើយ ដូច្នេះ ការបំផ្លិចបំផ្លាញក្រោយពីខ្យល់ព្យុះស៊ីក្លូន Nagis ក្នុងឆ្នាំ២០០៨ ដែលបានវាយប្រហារប្រទេសមីយ៉ាន់ម៉ា និងធ្វើឲ្យប្រជាជន ១,៥ លាននាក់ "ទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ" (ដូចត្រូវបានប៉ាន់ស្មានដោយទីភ្នាក់ងារអង្គការសហប្រជាជាតិ) មិនត្រូវបានចាត់ទុកថាជា "ស្ថានភាពទំនួលខុសត្រូវក្នុងការការពារ (RtoP)" ឡើយ។ នៅពេលនោះ មនុស្សមួយចំនួនមានចម្ងល់ថាតើការរារាំងជាបន្តចំពោះលទ្ធភាពផ្នែកមនុស្សធម៌ដោយអាជ្ញាធរភូមា ក្នុងការជួយកិច្ចប្រឹងប្រែងស្តារឡើងវិញ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬយ៉ាងណា។ ទោះជាយ៉ាងណាក៏ដោយ មន្ទិលសង្ស័យដែលរាលដាលថា សកម្មភាពទាំងនេះមានលក្ខណៈជាប្រព័ន្ធ និងជាផ្នែកមួយនៃផែនការទូលំទូលាយនៃការរំលោភបំពាន បាននាំឲ្យមានការព្រមព្រៀងមតិថា វិបត្តិនេះ គឺជាការប្រើប្រាស់ បទដ្ឋានទំនួលខុសត្រូវក្នុងការការពារ (RtoP) ដោយមិនត្រឹមត្រូវ។

### សំណួរពិភាក្សា

នៅក្នុងកិច្ចពិភាក្សារបស់អ្នកអំពីស្ថានភាពប្រទេស ចូរឆ្លុះបញ្ចាំងសំណួរដូចខាងក្រោម ដើម្បីការស្វែងយល់បន្ថែមរបស់អ្នកក្នុងការប្រើប្រាស់បទដ្ឋាននេះ៖

នៅក្នុងករណីប្រទេសនេះ៖ តើតួអង្គទាំងឡាយនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិប្រកាន់ខ្ជាប់នូវកាតព្វកិច្ចការពាររបស់ខ្លួន ដែលមានចែងនៅក្នុងក្របខ័ណ្ឌទំនួលខុសត្រូវក្នុងការការពារ (RtoP) យ៉ាងដូចម្តេច?

1. តើបញ្ហាប្រឈមអ្វីខ្លះចំពោះការអនុវត្តបទដ្ឋាននេះ៖ មានភាពច្បាស់លាស់ពីស្ថានភាពនេះ?

2. តើប្រតិកម្មរបស់សហគមន៍អន្តរជាតិចំពោះវិបត្តិនេះអាចជូនដំណឹងយ៉ាងដូចម្តេចចំពោះករណីនាពេលអនាគត នៅពេលប្រជាជនត្រូវបានគំរាមកំហែងដោយអំពើឃោរឃៅទ្រង់ទ្រាយធំ?

## បញ្ហាប្រឈមនៅក្នុងការអនុវត្តន៍ទំនួលខុសត្រូវក្នុងការការពារ (RtoP)

ចាប់តាំងពីសេចក្តីថ្លែងដំបូងរបស់ខ្លួនទំនួលខុសត្រូវក្នុងការការពារ (RtoP)បានបង្កើតនូវការយកចិត្តទុកដាក់ និងក្តីសង្ឃឹមយ៉ាងខ្លាំង ជាឧបករណ៍ប្រកបដោយថាមពលដ៏មានសក្តានុពលមួយ ដើម្បីលើកស្ទួយសន្តិភាពពិភពលោក និងបានដើរតួនាទីគន្លឹះនៅក្នុងការជះឥទ្ធិពល លើការឆ្លើយតបរបស់សហគមន៍អន្តរជាតិ ចំពោះការការពារជនស៊ីវិលនៅក្នុងករណីប្រទេសជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ ការធានានូវការអនុវត្តទំនួលខុសត្រូវក្នុងការការពារ (RtoP) ឲ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា នៅតែជាបញ្ហាប្រឈមដ៏ធំធ្ងន់មួយ។ ឱកាសមួយក្នុងការពិភាក្សាអំពីការដាក់ឲ្យអនុវត្តបទដ្ឋាន បានមកពីកំណត់សម្គាល់ទស្សនៈទានមួយ គឺ*ទំនួលខុសត្រូវខណៈពេលការពារ៖ សមាសភាពនានាសម្រាប់ការអភិវឌ្ឍន៍ និងការលើកស្ទួយទស្សនៈទាន* ដែលដាក់ជូនដោយបេសកកម្មអចិន្ត្រៃយ៍នៃប្រទេសប្រេស៊ីល ជូនទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដែលព្យាយាមដោះស្រាយកង្វល់នានាទាក់ទងនឹងការអនុវត្តវិធានការយោធា ដើម្បីការពារប្រជាជនពីឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP)។ ជាទូទៅ កង្វល់នានាទាក់ទងនឹងការដាក់ឲ្យអនុវត្តបទដ្ឋាន ដែលមានដូចៗគ្នា និងដោយមិនរើសមុខ បានរួមបញ្ចូលនូវ៖

- ការលំបាកក្នុងការគៀរគរឆន្ទៈនយោបាយ ដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងការគំរាមកំហែងនៃឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងអំពើហិង្សាទាំងនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ និងទាំងក្នុងចំណោមកិច្ចព្រមព្រៀងថ្នាក់តំបន់ និងអនុតំបន់។

- សមត្ថភាពកម្រិតថ្នាក់អន្តរជាតិ ថ្នាក់តំបន់ និងថ្នាក់ជាតិ មិនគ្រប់គ្រាន់ ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងអំពើហិង្សាទាំងបួន។

- តម្រូវការក្នុងការបញ្ជ្រាបគោលដៅ ទប់ស្កាត់អំពើឃោរឃៅទ្រង់ទ្រាយធំ ទៅក្នុងការងាររបស់អង្គការអន្តរជាតិ និងប្រចាំតំបន់ រដ្ឋនីមួយៗ និងក្រុមសង្គមស៊ីវិល។

- គម្លាតជាលក្ខណៈប្រព័ន្ធនៅក្នុងទំនាក់ទំនង និងសហប្រតិបត្តិការក្នុងចំណោមតួអង្គនានារួមទាំងនៅក្នុងប្រព័ន្ធព្រមានជាមុន ការចែករំលែកព័ត៌មានជាប្រចាំ និងសហប្រតិបត្តិការជាមួយកិច្ចប្រឹងប្រែងឆ្លើយតបជាអន្តរជាតិ ដូចជា បេសកកម្មស្វែងរកការពិត ការចេញដីកាចាប់ខ្លួន ឬការអនុញ្ញាតឲ្យមានទណ្ឌកម្ម។

- ការជ្រើសរើសសមាជិកក្រុមប្រឹក្សាសន្តិសុខ និងការប្រើប្រាស់សិទ្ធិវេតូ នៅក្នុងវិបត្តិនានាដែលពាក់ព័ន្ធនឹងអំពើឃោរឃៅទ្រង់ទ្រាយធំ ទោះជាមានរដ្ឋសមាជិកកាន់តែច្រើនបានអំពាវនាវឲ្យសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខ ជៀសវាងប្រើប្រាស់សិទ្ធិអំណាចវេតូរបស់ពួកគេនៅពេលពិចារណាលើករណីនៃអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង

- កង្វះគោលការណ៍ណែនាំសម្រាប់ការអនុវត្តការប្រើប្រាស់កម្លាំង ដើម្បីការពារប្រជាជន ដែលត្រូវបានឥស្សរមតិដោយរដ្ឋាភិបាលជាច្រើន ប៉ុន្តែ ត្រូវបានព្រមានឲ្យប្រុងប្រយ័ត្ន ដោយរដ្ឋាភិបាលផ្សេងទៀត ដែលបារម្ភថា លក្ខណៈវិនិច្ឆ័យទាំងនេះអាចរារាំងដល់ការឆ្លើយតបជាមុន ដើម្បីជួយប្រជាជនដែលស្ថិតក្នុងហានិភ័យ។

## ការយល់ច្រឡំទូទៅអំពីទំនួលខុសត្រូវក្នុងការការពារ (RtoP)

### តើទំនួលខុសត្រូវក្នុងការការពារ (RtoP) ដូចគ្នាទៅនឹងអន្តរាគមន៍មនុស្សធម៌ដែរឬទេ?

ទេ ទំនួលខុសត្រូវក្នុងការការពារ (RtoP) មិនមានចែងអំពីសិទ្ធិរបស់រដ្ឋក្នុងការធ្វើអន្តរាគមន៍នោះទេ ប៉ុន្តែ ចែងអំពីទំនួលខុសត្រូវរបស់រដ្ឋក្នុងការធានាថា ប្រជាជនត្រូវបានការពារពីឧក្រិដ្ឋកម្ម និងអំពើហិង្សា យោងតាមក្របខ័ណ្ឌនៃបទដ្ឋាន។ សហគមន៍អន្តរជាតិមានភារកិច្ចជួយរដ្ឋនានាក្នុងការការពារប្រជាជន ឬចាត់វិធានការឆាប់រហ័ស ប្រសិនបើរដ្ឋមួយមិនអាច ឬមិនឆ្លើយតបទៅនឹងការគំរាមកំហែង ឬការកើតឡើងនូវឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) ឬការរំលោភបំពានទេនោះ។ អន្តរាគមន៍មនុស្សធម៌ - ដែលសម្គាល់ដោយវិធានការយោធាដែលត្រូវបានប្រើប្រាស់ដោយគ្មានការយល់ព្រមពីរដ្ឋសាមី និងមិនត្រូវបានអនុញ្ញាត ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ - មិនត្រូវបានអនុម័តដោយបណ្តារដ្ឋ និងមិនត្រូវបានអនុញ្ញាត យោងតាមសសរស្តម្ភទីបីនៃទំនួលខុសត្រូវក្នុងការការពារ (RtoP) ឡើយ។ បទដ្ឋាននេះគាំទ្រអធិបតេយ្យភាពដែលមានទំនួលខុសត្រូវ និងបញ្ជាក់ពីដែនកំណត់ដែលមានស្រាប់នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ទាក់ទងនឹងពេលវេលា និងរបៀបដែលបណ្តារដ្ឋខាងក្រៅអាចឆ្លើយតបដើម្បីការពារប្រជាជន។ វិធានការយោធា ត្រូវបានអនុញ្ញាតផ្តាច់មុខដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងត្រូវបានប្រើប្រាស់តែនៅពេលដែលមធ្យោបាយសន្តិវិធីត្រូវបានបញ្ជាក់ថាមានភាពមិនគ្រប់គ្រាន់។

### តើការប្រើប្រាស់កម្លាំង គឺជាវិធានការតែមួយគត់នៅក្នុងសសរស្តម្ភទីបីនៃទំនួលខុសត្រូវក្នុងការការពារ (RtoP) ឬ?

ទេ សសរស្តម្ភទីបីនៃទំនួលខុសត្រូវក្នុងការការពារ (RtoP) កំណត់នូវទំនួលខុសត្រូវរបស់សហគមន៍អន្តរជាតិក្នុងការចាត់វិធានការរួមគ្នា ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងនៃអំពើឃោរឃៅទ្រង់ទ្រាយធំ ឲ្យបានទាន់ពេលវេលា និងម៉ឺងម៉ាត់ ផ្អែកតាមករណីនីមួយៗ និងស្របតាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិ។ យោងតាមសសរស្តម្ភទីបី សហគមន៍អន្តរជាតិអាចឆ្លើយតប ដោយប្រើឧបករណ៍សន្តិវិធី និង បង្ខិតបង្ខំជាច្រើន រួមទាំងទំនាក់ទំនងការទូតទប់ស្កាត់ បេសកកម្មស្វែងរកការពិត ទណ្ឌកម្ម និងការហ៊ុមព័ទ្ធផ្នែកសេដ្ឋកិច្ច និងប្រតិបត្តិការយោធា ដូចជា តំបន់គ្មានការហោះហើរ បេសកកម្មពិនិត្យតាមដាន និងការពារជនស៊ីវិល។

### តើទំនួលខុសត្រូវក្នុងការការពារ (RtoP) អាចត្រូវបានប្រើប្រាស់ជាយានសម្រាប់ការផ្លាស់ប្តូររបបដែរឬទេ?

ទេ ការផ្លាស់ប្តូររបបមិនមែនជាវិធានការមួយដែលបញ្ចូលនៅក្នុងទំនួលខុសត្រូវក្នុងការការពារ (RtoP) ឡើយ។ បទដ្ឋាននេះផ្តោតជាសំខាន់លើការទប់ស្កាត់ និងការបញ្ឈប់ឧក្រិដ្ឋកម្មទាំងបួន និងមិនអំពាវនាវឲ្យមានទម្រង់ជាក់លាក់នៃរដ្ឋាភិបាលឡើយ។ យុទ្ធសាស្ត្រឆ្លើយតបនៅក្នុងករណីទំនួលខុសត្រូវក្នុងការការពារ (RtoP)ជានិច្ចកាលមានគោលបំណងឲ្យរដ្ឋាភិបាលផ្លាស់ប្តូររបៀបដែលខ្លួនឆ្លើយតបទៅនឹងស្ថានភាពវិបត្តិ ដែលក្នុងករណីខ្លះអាចនាំឲ្យមានការផ្លាស់ប្តូរអំណាច។ ទោះជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូរបែបនេះមិនមែនចាំបាច់ត្រូវតែធ្វើនោះទេជាពិសេសនៅពេលរបបមួយកែសម្រួលគោលនយោបាយរបស់ខ្លួនដើម្បីការពារប្រជាជន។

## ទំនួលខុសត្រូវក្នុងការការពារ (RtoP)និងទំនាក់ទំនងរបស់ទំនួលខុសត្រូវក្នុងការការពារ (RtoP) ជាមួយនឹងរបៀបវារៈអន្តរជាតិផ្សេងទៀត

### ការការពារជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ

ទំនួលខុសត្រូវក្នុងការការពារ (RtoP) មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងរបៀបវារៈទូលំទូលាយ នៃការទប់ស្កាត់ជម្លោះប្រដាប់អាវុធ ទោះបីជាឧក្រិដ្ឋកម្ម និងការរំលោភបំពានដែលស្ថិតក្រោមទំនួលខុសត្រូវក្នុងការការពារ (RtoP) អាច ឬមិនអាចកើតឡើងក្នុងអំឡុងជម្លោះប្រដាប់អាវុធក៏ដោយ ជាពិសេសទំនួលខុសត្រូវក្នុងការការពារ (RtoP) បានផ្សារភ្ជាប់ទៅនឹង ទោះជាខុសប្លែកពី របៀបវារៈនៃការការពារជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ (POC) ក្របខ័ណ្ឌសម្រាប់សកម្មភាពការទូត ច្បាប់ មនុស្សធម៌ និងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិដែលផ្តោតលើការការពារប្រជាជនក្នុងអំឡុងជម្លោះប្រដាប់អាវុធ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើការការពារជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ (POC) ដោះស្រាយបញ្ហាការពារទូលំទូលាយជាង នៅក្នុងករណីជាក់លាក់នៃជម្លោះប្រដាប់អាវុធទំនួលខុសត្រូវក្នុងការការពារ (RtoP) អនុវត្តចំពោះតែករណីទាំងឡាយណា ដែលប្រជាជនត្រូវបានគំរាមគំហែងដោយអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការលុបបំបាត់ជាតិសាសន៍ប៉ុណ្ណោះ ដោយមិនគិតអំពីថាតើស្ថានភាពនោះអាច ឬមិនអាចត្រូវបានកំណត់ថាជាជម្លោះប្រដាប់អាវុធនោះឡើយ។

### ស្ត្រី សន្តិភាព និងសន្តិសុខ

ទំនួលខុសត្រូវក្នុងការការពារ (RtoP) គឺជាចំណុចបំពេញបន្ថែមដ៏សំខាន់មួយនៃការប្តេជ្ញានានា នៅពេលបច្ចុប្បន្នរបស់អន្តររដ្ឋាភិបាលចំពោះសិទ្ធិមនុស្ស និងសន្តិសុខរបស់ស្ត្រី ដូចជា វេទិកាក្រុងប៉េកាំង ដើម្បីសកម្មភាព និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ១៣២៥, ១៨៨៨, ១៨៨៩ និង ១៩៦០ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ វិធានការប្រតិបត្តិការចំពោះ "ការបង្កើតឲ្យមានទំនួលខុសត្រូវក្នុងការការពារ" អាចរួមចំណែកដល់ការបញ្ចូលភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងការទប់ស្កាត់ និងការបញ្ឈប់អំពើឃោរឃៅទ្រង់ទ្រាយធំ និងការធានាថា ស្ត្រី និងបុរសមានភាពស្មើគ្នានៅក្នុងការទប់ស្កាត់ និងដំណោះស្រាយជម្លោះ ក៏ដូចជាកិច្ចប្រឹងប្រែងកសាងឡើងវិញ។

រួមជាមួយនឹងការទទួលស្គាល់តួនាទីរបស់ស្ត្រីនៅក្នុងការទប់ស្កាត់ និងការការពារ មានការបង្កើនការយល់ដឹងថា ស្ថានភាពជម្លោះបច្ចុប្បន្ន និងស្ថានភាពក្រោយជម្លោះ ប៉ះពាល់ដល់ស្ត្រី និងបុរសខុសគ្នា។ អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក បាន គីមូន បានបញ្ជាក់អះអាងជាថ្មីថា ការរំលោភសេពសន្ថវៈ និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទអាចមានទម្ងន់ស្មើនឹងអំពើឃោរឃៅទ្រង់ទ្រាយធំ និងថា អំពើហិង្សាផ្អែកលើយេនឌ័រ គឺជាសូចនាករព្រមានជាមុនមួយនៃឧក្រិដ្ឋកម្មទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ អំពើហិង្សាផ្លូវភេទ និងផ្អែកលើយេនឌ័រ នៅតែបន្តមានសភាពធ្ងន់ធ្ងរដដែល ដោយព័ត៌មាន និងធនធានដែលចាំបាច់ ដើម្បីស្វែងយល់អំពីមូលហេតុនៅមានកម្រិត និងមិនអាចរកបាន។ លំនាំនេះត្រូវតែផ្លាស់ប្តូរ ដើម្បីធានានូវការទប់ស្កាត់កាន់តែមានប្រសិទ្ធភាព នៅពេលឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការរំលោភបំពានកំពុងមានការគំរាមកំហែង។

## ទំនួលខុសត្រូវក្នុងការការពារ (RtoP) និងទំនាក់ទំនងរបស់ទំនួលខុសត្រូវក្នុងការការពារ (RtoP) ជាមួយនឹងរបៀបវារៈអន្តរជាតិផ្សេងទៀត

### ប្រព័ន្ធយុត្តិធម៌អន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ

ជាគំនិតផ្តួចផ្តើមមួយ ដើម្បីបញ្ឈប់ ឬបញ្ចៀសអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទំនួលខុសត្រូវក្នុងការការពារ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងកិច្ចព្រមព្រៀងនានានៅក្នុងប្រព័ន្ធយុត្តិធម៌អន្តរជាតិ ដើម្បីបញ្ចប់និទណ្ឌភាពសម្រាប់ឧក្រិដ្ឋកម្មទាំងនេះ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ដែលចូលជាធរមានក្នុងឆ្នាំ២០០២ គឺជាស្ថាប័នតុលាការអន្តរជាតិអចិន្ត្រៃយ៍ដំបូងបំផុត ដែលត្រូវបានផ្តល់អាណត្តិឲ្យធ្វើការស៊ើបអង្កេតលើការប្រព្រឹត្ត និងការកាត់ទោសជនល្មើសដែលត្រូវបានចោទប្រកាន់សម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតទាំងនេះ។ តុលាការព្រហ្មទណ្ឌអន្តរជាតិធ្វើឲ្យជនល្មើសទទួលខុសត្រូវ ដោយមិនមានអភ័យឯកសិទ្ធិសម្រាប់ឋានៈជាប្រមុខរដ្ឋ និងយោងតាមគោលការណ៍នៃភាពបំពេញបន្ថែមគ្នា ស៊ើបអង្កេតអំពើឃោរឃៅទ្រង់ទ្រាយធំដែលអាចកើតមាន នៅពេលសមត្ថភាពតុលាការថ្នាក់ជាតិ និងថ្នាក់តំបន់មានការខ្វះខាត។ យោងតាមទំនួលខុសត្រូវក្នុងការការពារ (RtoP) ការបញ្ជូនទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានចាត់ទុក ជាវិធានការទប់ស្កាត់មួយ ដោយសារវាអាចរារាំងការគំរាមកំហែងនៃអំពើឃោរឃៅទ្រង់ទ្រាយធំ និងជាវិធានការឆ្លើយតបមួយ ដែលរួមចំណែកដល់គណនេយ្យភាព និងការទប់ស្កាត់និទណ្ឌភាព។

### ការរីករាលដាល និងការធ្វើពាណិជ្ជកម្មអាវុធធុនតូច និងអាវុធផ្សេងទៀត

ការផ្ទេរអាវុធ និងគ្រាប់រំសេវដោយគ្មានការទទួលខុសត្រូវ និងការរីកដាលអាវុធធុនតូចខុសច្បាប់ មានផលប៉ះពាល់ដោយផ្ទាល់ទៅលើការទប់ស្កាត់អំពើឃោរឃៅទ្រង់ទ្រាយធំ និងអាចរារាំងសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការការពារប្រជាជនរបស់ខ្លួន។ មួយផ្នែក ពីព្រោះអាវុធធុនតូច និងគ្រាប់រំសេវអាចត្រូវបានផ្ទេរ លួច ឬបង្វែរទិសដៅយ៉ាងងាយស្រួល អាវុធទាំងនេះ ជាញឹកញាប់ គឺជាអាវុធដែលអាចជ្រើសរើសបាននៅក្នុងជម្លោះប្រដាប់អាវុធ។ អាវុធខុសច្បាប់ ក៏អាចដុតបញ្ឆេះបន្ថែមដល់វិវាទនានាផងដែរ ដែលអាចត្រូវបានដោះស្រាយ តាមរយៈកិច្ចប្រឹងប្រែងផ្នែកការទូត ដោយមានហានិភ័យធ្វើឲ្យជម្លោះកាន់តែធ្ងន់ធ្ងរ ដល់កម្រិតនៃអំពើឃោរឃៅទ្រង់ទ្រាយធំ និងអាចត្រូវបានប្រើប្រាស់ ដើម្បីបំផ្លាញវិស័យសន្តិសុខរបស់រដ្ឋ ព្រមទាំងយន្តការកសាងសមត្ថភាពថ្នាក់តំបន់ និងអន្តរជាតិ ដែលព្យាយាមធ្វើឲ្យមានស្ថិរភាពចំពោះស្ថានភាពវិបត្តិដែលអាចមាន។ នៅឆ្នាំ២០០១ បណ្តារដ្ឋជាសមាជិកបានប្តេជ្ញាចិត្ត បញ្ឈប់ការធ្វើពាណិជ្ជកម្មអាវុធធុនតូចខុសច្បាប់ និងមិនទទួលខុសត្រូវ តាមរយៈកម្មវិធីសកម្មភាពរបស់អង្គការសហប្រជាជាតិស្តីពីអាវុធធុនតូច និងអាវុធធុនស្រាល។ រដ្ឋនានាក៏ស្ថិតក្នុងដំណើរការបញ្ចប់ការចរចាអំពីសន្ធិសញ្ញាស្តីពីពាណិជ្ជកម្មអាវុធ ដែលព្យាយាមត្រួតពិនិត្យការផ្ទេរអាវុធធម្មតា ជាមួយនឹងបញ្ញត្តិដែលទប់ស្កាត់ការផ្ទេរអាវុធ ដែលមានហានិភ័យខ្ពស់ក្នុងការត្រូវបានប្រើប្រាស់ ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំផងដែរ។

# ផ្នែកទី ២៖

# ការពង្រឹងទំនួលខុសត្រូវក្នុងការការពារ (RtoP) ៖ តួនាទីរបស់តួអង្គថ្នាក់ជាតិ និងថ្នាក់តំបន់

## តួនាទីរបស់អង្គការសង្គមស៊ីវិល៖ តើអង្គការសង្គមស៊ីវិលកំពុងធ្វើអ្វីខ្លះហើយ ដើម្បីទប់ស្កាត់ និងបញ្ឈប់អំពើឃោរឃៅទ្រង់ទ្រាយធំ?

ការលើកស្ទួយទំនួលខុសត្រូវក្នុងការការពារមានភាពជាន់គ្នាជាមួយវិស័យជាច្រើន ដូចជា សិទ្ធិមនុស្ស ការទប់ស្កាត់ជម្លោះ អភិបាលកិច្ច និងនីតិរដ្ឋ សន្តិភាព និងសន្តិសុខ យុត្តិធម៌អន្តរជាតិ ការកសាងសន្តិភាព ជំនួយមនុស្សធម៌ សិទ្ធិរបស់ស្ត្រី និងទស្សនវិស័យជំនឿ។ អង្គការសង្គមស៊ីវិល (CSOs) បានរួមចំណែករួចហើយដល់ការការពារប្រជាជន តាមរយៈវិធានការ និងគំនិតផ្តួចផ្តើមជាច្រើន៖

### ១. ការពិនិត្យតាមដាន និងការចងក្រងជាឯកសារនូវអំពើឃោរឃៅ

- ការពិនិត្យតាមដានវិបត្តិដែលអាចកើតមានជាក់ស្តែង ឬតាមដានពីចម្ងាយ តាមរយៈគំនិតផ្តួចផ្តើមស្វែងរកការពិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម និងតាមបែបចាស់ ដែលពិនិត្យតាមដាន និងពិនិត្យមើលជាពិសេសលើសូចនាករនានានៃអំពើឃោរឃៅទ្រង់ទ្រាយធំ រួមទាំងការញុះញង់ ការវាយប្រហារលើសហគមន៍ជនជាតិភាគតិច និងអំពើហិង្សាផ្លូវភេទ និងផ្អែកលើយេនឌ័រ។

### ២. ការចែករំលែកការព្រមាន និងការវាយតម្លៃជាមុន

- ការផ្តល់ដំណឹងជាមុនដល់តួអង្គផ្សេងទៀត អំពីជម្លោះដែលអាចកើតមាន និងកំពុងចាប់ផ្តើម តាមរយៈការចែករំលែកព័ត៌មាន និងការវាយតម្លៃជាការព្រមានជាមុន រួមជាមួយនឹងយន្តការព្រមានជាមុនថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ រួមទាំងក្នុងអំឡុងរយៈពេលងាយរងគ្រោះ ដូចជាការប្រែប្រួលស្ថានការណ៍នយោបាយ និងការបោះឆ្នោត។

### ៣. ការសម្រុះសម្រួល ការចរចា និងដំណោះស្រាយវិវាទ

- ការលើកទឹកចិត្តឲ្យភាគីវិវាទធ្វើការចរចា និងដោះស្រាយវិបត្តិដោយអហិង្សា។
- កិច្ចប្រឹងប្រែងគាំទ្រ ចូលរួម ឬដឹកនាំ ដើម្បីសម្រុះសម្រួល ឬដោះស្រាយជម្លោះ។

### ៤. ការបណ្តុះបណ្តាលបុគ្គលិកការពារជនស៊ីវិល

- ការសម្របសម្រួលការបណ្តុះបណ្តាលបុគ្គលិកស៊ីវិល និងយោធាសម្រាប់ប្រតិបត្តិការការពារ រួមទាំងការផ្តល់ការណែនាំអំពីការសម្គាល់សូចនាករនៃអំពើឃោរឃៅទ្រង់ទ្រាយធំ ការកាត់បន្ថយជនរងគ្រោះស៊ីវិលឲ្យស្ថិតក្នុងកម្រិតអប្បបរមា និងការទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងផ្អែកលើយេនឌ័រ និងការគំរាមកំហែងចំពោះកុមារនៅក្នុងជម្លោះប្រដាប់អាវុធ។
- ការវាយតម្លៃសូចនាករទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការវិភាគវិបត្តិកន្លងមក ដើម្បីរាយការណ៍អំពីមេរៀនដែលទទួលបាន និងទម្លាប់អនុវត្តន៍ល្អប្រសើរ ដើម្បីពង្រឹងយុទ្ធសាស្ត្រទប់ស្កាត់។

## តើអង្គការសង្គមស៊ីវិលកំពុងធ្វើអ្វីខ្លះហើយ ដើម្បីទប់ស្កាត់ និងបញ្ឈប់អំពើឃោរឃៅទ្រង់ទ្រាយធំ?

### ៥. ការស្តារឡើងវិញក្រោយការប៉ះទង្គិចផ្លូវចិត្ត

- ការអនុវត្តការវាយតម្លៃលើសេចក្តីត្រូវការរបស់សហគមន៍ ដើម្បីបង្កើតយុទ្ធសាស្ត្រកសាងឡើងវិញ និងផ្សះផ្សាដោយឯករាជ្យ ឬដោយសហការជាមួយនឹងតួអង្គសង្គមស៊ីវិល រដ្ឋាភិបាល និងអន្តររដ្ឋាភិបាលផ្សេងទៀត។
- ការសម្របសម្រួល និងការជួយជ្រោមជ្រែងតាមរយៈដំណើរការសន្តិភាព និងការអភិវឌ្ឍន៍ក្រោយវិបត្តិ ការផ្តោតលើសារៈសំខាន់នៃការធានាឲ្យមានភាពជាតំណាងដោយស្មើភាពលើប្រជាជនភាគតិច ស្ត្រី និងក្រុមងាយរងគ្រោះផ្សេងទៀតនៅក្នុងកិច្ចប្រឹងប្រែងផ្សះផ្សា។

### ៦. ការគាំទ្រ និងការពង្រឹងប្រព័ន្ធយុត្តិធម៌ក្នុងស្រុក និងតំបន់

- ការពិនិត្យតាមដានការងារ និងការផ្តល់ការគាំទ្រផ្លូវច្បាប់ចំពោះស្ថាប័នតុលាការ។

### ៧. ការតស៊ូមតិឲ្យមានស្ថាប័នកាន់តែរឹងមាំ ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានទំនួលខុសត្រូវក្នុងការការពារ (RtoP) ហើយអំពាវនាវដល់៖

- អ្នកនយោបាយឲ្យលើកឡើងអំពីការទប់ស្កាត់ និងការពារប្រជាជនពីអំពើឃោរឃៅ ទ្រង់ទ្រាយធំនៅក្នុងសេចក្តីថ្លែងការណ៍នានា។
- ការអនុម័តច្បាប់ ដើម្បីធានាសិទ្ធិស្មើគ្នាសម្រាប់ក្រុមភាគតិច ស្ត្រី និងប្រជាជនងាយរងគ្រោះ។
- រដ្ឋ និងអង្គការថ្នាក់តំបន់ ឲ្យពង្រឹង ឬ ប្រសិនបើមិនទាន់មាន បង្កើតគោលនយោបាយក្នុងស្រុក និងថ្នាក់តំបន់ និងរចនាសម្ព័ន្ធនានា ដើម្បីទប់ស្កាត់អំពើឃោរឃៅទ្រង់ទ្រាយធំ។
- រដ្ឋាភិបាលនានាឲ្យចុះហត្ថលេខាលើសន្ធិសញ្ញា និងពិធីសារសិទ្ធិមនុស្សអន្តរជាតិ ឬបង្កើតជនបង្គោលថ្នាក់ជាតិស្តីពីទំនួលខុសត្រូវក្នុងការការពារ (RtoP)។

### ៨. ការគាំទ្រសហគមន៍ក្នុងស្រុកក្នុងកិច្ចប្រឹងប្រែងទប់ស្កាត់ និងការពារ

- ការជួយតួអង្គក្នុងស្រុកក្នុងការកសាងសមត្ថភាពរបស់ពួកគេ ដើម្បីកំណត់ និងបង្ការការគំរាមកំហែងនៃឧក្រិដ្ឋកម្ម និងការរំលោភបំពានទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការផ្សព្វផ្សាយជាសាធារណៈ និង/ឬក្នុងការបន្តអនុវត្តតាមកិច្ចប្រឹងប្រែងទាំងនេះ ប្រសិនបើអាចធ្វើទៅបាន។

ទិវានារីអន្តរជាតិដែលប្រារព្ធធ្វើឡើងនៅប្រទេសលីបេរីយ៉ា។
ប្រភព៖ រូបថតរបស់អង្គការសហប្រជាជាតិ ដោយ Eric Kanalstein



## តួនាទីរបស់អង្គការសង្គមស៊ីវិលៈ តើអង្គការសង្គមស៊ីវិលពង្រឹង ឬអាចពង្រឹងទំនួលខុសត្រូវក្នុងការការពារ (RtoP )យ៉ាងដូចម្ដេច?

អង្គការសង្គមស៊ីវិលអាចប្រើប្រាស់ទំនួលខុសត្រូវក្នុងការការពារ ដើម្បីពង្រឹងការងារជាបន្តរបស់ពួកគេក្នុងគោលបំណងទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ។ នៅក្នុងខណៈពេលដ៏សំខាន់នោះក្នុងប្រវត្តិសាស្ត្រ នៅពេលដែលរដ្ឋាភិបាលបានអនុម័តទំនួលខុសត្រូវក្នុងការការពារ (RtoP) នៅក្នុងឯកសារលទ្ធផលជំនួបកំពូលពិភពលោក ដោយទទួលស្គាល់តួនាទីយ៉ាងសកម្មរបស់ខ្លួននៅក្នុងការការពារប្រជាជននៅទូទាំងពិភពលោកពីឧក្រិដ្ឋកម្មអាក្រក់បំផុតចំពោះមនុស្សជាតិ អង្គការសង្គមស៊ីវិលទទួលបានមូលដ្ឋានមួយដែលមិនអាចប្រកែកបាន ដែលតាមរយៈនេះ ដាក់ឲ្យបណ្ដារដ្ឋនានាទទួលខុសត្រូវចំពោះការសន្យារបស់ខ្លួន។ ក្រៅពីការបញ្ចូលបទដ្ឋាននេះទៅក្នុងអាណត្តិរៀងៗខ្លួនរបស់ពួកគេ និងការប្រើប្រាស់វាដើម្បីធ្វើការតស៊ូមតិឲ្យមានការទប់ស្កាត់ និងការការពារប្រកបដោយប្រសិទ្ធភាព អង្គការសង្គមស៊ីវិលអាចធ្វើសកម្មភាពផ្សេងៗគ្នាជាច្រើនសំដៅលើកកម្ពស់ការយល់ដឹង និងកសាងការគាំទ្រចំពោះបទដ្ឋាននេះ។

### ១. បង្កើនការយល់ដឹងអំពីទំនួលខុសត្រូវក្នុងការការពារក្នុងចំណោមសាធារណជន រដ្ឋាភិបាល តំណាងរាស្ត្រ ប្រព័ន្ធផ្សព្វផ្សាយ វិស័យឯកជន និងបញ្ញាវ័ន្ត

- រៀបចំព្រឹត្តិការណ៍សាធារណៈ ឬសិក្ខាសាលាបិទទ្វារស្ដីពីទំនួលខុសត្រូវក្នុងការការពារ (RtoP) ករណីរបស់ប្រទេស និងមូលបទដែលពាក់ព័ន្ធ។

- បង្កើត បកប្រែ និងផ្សព្វផ្សាយសម្ភារអប់រំជាភាសាក្នុងស្រុក។

- ឯកសារយោងទំនួលខុសត្រូវក្នុងការការពារ (RtoP) នៅពេលបោះពុម្ពផ្សាយអត្ថបទ បទវិភាគ និងរបាយការណ៍គោលនយោបាយស្ដីពីករណីប្រទេស ឬមូលបទដែលពាក់ព័ន្ធ។

- អំពាវនាវដល់តួអង្គនានានៅគ្រប់លំដាប់ថ្នាក់ឲ្យចាត់វិធានការនៅពេលមានហានិភ័យដែលអាចកើតមាននៃឧក្រិដ្ឋកម្ម និងការរំលោភបំពានទំនួលខុសត្រូវក្នុងការការពារ (RtoP) និងដាក់ឲ្យរដ្ឋាភិបាលនានាទទួលខុសត្រូវនៅក្នុងស្ថានភាព ដែលប្រជាជនត្រូវបានគំរាមកំហែង ឬឧក្រិដ្ឋកម្មកំពុងកើតមាន។ ការអំពាវនាវនេះ រួមបញ្ចូលទាំងការនិយាយលើកឡើងនៅក្នុងស្ថានភាពនានាដែលទំនួលខុសត្រូវក្នុងការការពារ (RtoP) កំពុងត្រូវបានប្រើប្រាស់មិនត្រឹមត្រូវ ឬរំលោភបំពាន និងការបញ្ជាក់អំពីពេលវេលា ដែលវិធានការនេះគួរត្រូវបានអនុវត្ត។

- បញ្ចូលទំនួលខុសត្រូវក្នុងការការពារ (RtoP) និងកញ្ចក់ឆ្លុះបញ្ចាំងពីការការពារអំពើឃោរឃៅទ្រង់ទ្រាយធំនៅក្នុងកិច្ចពិភាក្សាអំពីរបៀបវារៈដែលពាក់ព័ន្ធ រួមទាំងយុត្តិធម៌អន្តរជាតិ និងថ្នាក់តំបន់ ស្ត្រី សន្តិភាព និងសន្តិសុខ ការត្រួតពិនិត្យអាវុធ និងការការពារជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ។

## ២. បង្កើតក្រុមដែលមានចក្ខុវិស័យរួមដែលគាំទ្រចំពោះទំនួលខុសត្រូវក្នុងការការពារ (RtoP) និងបង្កើនការងាររបស់អង្គការសង្គមស៊ីវិលលើបទដ្ឋាន

- កោះប្រជុំ ឬគាំទ្រកិច្ចពិភាក្សាទៀងទាត់ជាមួយអង្គការសង្គមស៊ីវិលមួយក្រុមតូច ប្រសិនបើពួកគេអាចដេញដោល និងពិភាក្សាអំពីព័ត៌មានថ្មីចុងក្រោយបំផុតអំពីទំនួលខុសត្រូវក្នុងការការពារ (RtoP) ការអនុវត្តទំនួលខុសត្រូវក្នុងការការពារ (RtoP) ចំពោះស្ថានភាពវិបត្តិ ការឆ្លើយតបរបស់រដ្ឋាភិបាល និងអង្គការថ្នាក់តំបន់ចំពោះការអភិវឌ្ឍន៍តាមបទដ្ឋាន និងការកំណត់យុទ្ធសាស្ត្រអំពីការតស៊ូមតិ។

- ផ្សារភ្ជាប់ជាមួយអង្គការសង្គមស៊ីវិលផ្សេងទៀត ស្ថាប័នអប់រំ និងសាធារណជនទូទៅ ដោយប្រើប្រាស់បណ្ដាញសង្គម ដើម្បីចែករំលែកព័ត៌មាន និងការវិភាគ ការបោះពុម្ពផ្សាយ និងព្រឹត្តិការណ៍នានា។

- ចូលរួមនៅក្នុងសម្ព័ន្ធអន្តរជាតិ ដើម្បីទំនួលខុសត្រូវក្នុងការការពារ។

## តួនាទីរបស់អង្គការសង្គមស៊ីវិល៖ តើអង្គការសង្គមស៊ីវិលពង្រឹង ឬអាចពង្រឹងទំនួលខុសត្រូវក្នុងការការពារ (RtoP) យ៉ាងដូចម្តេច?

### ៣. តស៊ូមតិឲ្យមានការបង្កើនការគាំទ្រតាមបទដ្ឋានសម្រាប់ទំនួលខុសត្រូវក្នុងការការពារ (RtoP)

- អំពាវនាវដល់អ្នកនយោបាយឲ្យលើកឡើងពីទំនួលខុសត្រូវក្នុងការការពារ (RtoP) នៅក្នុងសេចក្តីថ្លែងការណ៍ និងដើម្បីឲ្យរដ្ឋ និងអង្គការថ្នាក់តំបន់បញ្ចូលទំនួលខុសត្រូវក្នុងការការពារ (RtoP) ទៅក្នុងយុទ្ធសាស្ត្រសន្តិសុខថ្នាក់ជាតិ និងតំបន់ សៀវភៅស ។ល។

### ៤. ការស្រាវជ្រាវ និងការអភិវឌ្ឍន៍គោលនយោបាយ

- បោះពុម្ពផ្សាយការស្រាវជ្រាវ និងគោលនយោបាយសង្ខេបស្តីពីទិដ្ឋភាពផ្សេងៗ និងមូលបទពាក់ព័ន្ធនឹងបទដ្ឋាន ដើម្បីបង្កើនការយល់ដឹងអំពី និងរួមចំណែកចំពោះកិច្ចពិភាក្សាលម្អិតអំពីទំនួលខុសត្រូវក្នុងការការពារ (RtoP)។

### សំណួរពិភាក្សាសម្រាប់អង្គការសង្គមស៊ីវិល

**នៅក្នុងបណ្តាញ និងសហគមន៍របស់អ្នក ចូរពិចារណាសំណួរដូចខាងក្រោមអំពីរបៀបដាក់ឲ្យអនុវត្តទំនួលខុសត្រូវក្នុងការការពារ (RtoP) ៖**

- តើអង្គការសង្គមស៊ីវិល និងសហគមន៍របស់អ្នក មានចម្ងល់ ឬកង្វល់ចម្បងអ្វីខ្លះអំពីទំនួលខុសត្រូវក្នុងការការពារ (RtoP)?
- តើអង្គការសង្គមស៊ីវិលគួរស្នើសុំអង្គការសហប្រជាជាតិ បណ្តារដ្ឋាភិបាល និងអង្គការថ្នាក់តំបន់ឲ្យអនុវត្តវិធានការមិនបង្ខិតបង្ខំអ្វីខ្លះ? ប្រសិនបើវិធានការទាំងនេះពុំមានភាពគ្រប់គ្រាន់ក្នុងការការពារទេនោះ តើអង្គការសង្គមស៊ីវិលរបស់អ្នកនឹងពិចារណាលើការអំពាវនាវឲ្យមានវិធានការបង្ខិតបង្ខំ តាមរយៈអង្គការសហប្រជាជាតិ ឬអង្គការថ្នាក់តំបន់ដែរឬទេ? ប្រសិនបើមិនមានវិធានការគ្មានការបង្ខិតបង្ខំ ឬវិធានការបង្ខិតបង្ខំ ទេនោះ តើស្ថាប័នទាំងនេះគួរអភិវឌ្ឍសមត្ថភាពរបស់ខ្លួនយ៉ាងដូចម្តេច ដើម្បីការពារប្រជាជនពីឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការរំលោភបំពាន?

**ពិចារណាអំពីការលើកឡើងនូវសំណួរដូចខាងក្រោមនៅពេលមានការចូលរួមពីសំណាក់មន្ត្រីថ្នាក់តំបន់ និងមន្ត្រីរដ្ឋាភិបាល៖**

- តើមន្ត្រីទាំងឡាយដឹងអំពីការប្តេជ្ញាចំពោះទំនួលខុសត្រូវក្នុងការការពារ (RtoP) ដែលធ្វើឡើងនៅក្នុងជំនួបកំពូលពិភពលោក ឆ្នាំ២០០៥ ដែរឬទេ?
- តើមន្ត្រី/តំណាងរាស្ត្រមានចម្ងល់អំពីគោលការណ៍ទំនួលខុសត្រូវក្នុងការការពារ (RtoP) ដែរឬទេ?
- តើយុទ្ធសាស្ត្រ និងយន្តការអ្វីខ្លះត្រូវបានបង្កើតឡើងនៅក្នុងរដ្ឋាភិបាល ឬអង្គការថ្នាក់តំបន់របស់អ្នក ដើម្បីទប់ស្កាត់អំពើឃោរឃៅទ្រង់ទ្រាយធំ? តើស្ថាប័នទាំងនេះកំពុងធ្វើការ ដើម្បីពង្រឹងសមត្ថភាពទប់ស្កាត់ និងការពាររបស់ខ្លួន?
- តើរដ្ឋាភិបាលរបស់អ្នកកំពុងចាត់វិធានការ ដើម្បីបញ្ចូលទំនួលខុសត្រូវក្នុងការការពារ (RtoP) ទៅក្នុងគោលនយោបាយរបស់ខ្លួនដែរឬទេ?
- តើកិច្ចព្រមព្រៀងថ្នាក់រដ្ឋាភិបាល ឬថ្នាក់តំបន់របស់អ្នក មានយន្តការដើម្បីធ្វើអន្តរកម្មជាមួយសង្គមស៊ីវិលស្តីពីបញ្ហាទាំងនេះដែរឬទេ?

## តើអ្នកអាចទៅទាក់ទងក្រុមណាខ្លះបាន?

ការងាររបស់អង្គការសង្គមស៊ីវិល ដើម្បីពង្រឹងទំនួលខុសត្រូវក្នុងការការពារ អាចត្រូវបានធ្វើឡើងនៅក្នុងបរិបទនៃវិស័យមួយចំនួនធំ។ អ្នក ឬអង្គការរបស់អ្នកអាចសហការជាដៃគូជាមួយវិទ្យាស្ថានគោលនយោបាយ និងស្រាវជ្រាវ អង្គការផ្តល់សេវា ក្រុមជំនឿ និងស្ថាប័នអប់រំ ដើម្បីលើកស្ទួយបទដ្ឋាន និងទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើឃោរឃៅទ្រង់ទ្រាយធំ។



## តើបញ្ញាវន្តអាចលើកស្ទួយទំនួលខុសត្រូវក្នុងការការពារ (RtoP)យ៉ាងដូចម្តេច?

បញ្ញាវន្ត គឺជាតួអង្គសំខាន់បំផុតនៅក្នុងការពង្រឹងបទដ្ឋានទំនួលខុសត្រូវក្នុងការការពារ (RtoP) ទាំងជាអ្នកស្រាវជ្រាវ ទាំងជាគ្រូបង្រៀន។ ពួកគេអាចធ្វើឲ្យមានការចូលរួមពីសំណាក់វិស័យផ្សេងៗនៃអង្គការសង្គមស៊ីវិល ព្រមទាំងមន្ត្រីការទូតថ្នាក់ជាតិ និងតំបន់នៅក្នុងកិច្ចពិភាក្សាអំពីទិដ្ឋភាពជាច្រើននៃបទដ្ឋាន។ ដូចដែលអ្នកបានឃើញនៅក្នុងផ្នែកមុននេះ មានសំណួរសំខាន់ៗអំពីរបៀបព្យាករណ៍ ទប់ស្កាត់ និងឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងឧក្រិដ្ឋកម្ម និងការរំលោភបំពានទំនួលខុសត្រូវក្នុងការការពារ (RtoP)។ ក្រៅពីការអនុវត្តការស្រាវជ្រាវលើបញ្ហាទាំងនេះ បញ្ញាវន្តអាចបង្កើតកម្មវិធីសិក្សា និងសម្ភារៈអប់រំ រៀបចំសិក្ខាសាលា និងបង្រៀនវគ្គនានា ដែលពិនិត្យទំនួលខុសត្រូវក្នុងការការពារ (RtoP) និងរបៀបដែលទំនួលខុសត្រូវក្នុងការការពារ (RtoP) អនុវត្តចំពោះករណីរបស់ប្រទេស និងមូលបទដែលពាក់ព័ន្ធ។ មានការយល់ខុសទូទៅផងដែរអំពីបទដ្ឋានដែលអ្នកជំនាញអាចជួយនៅក្នុងការស្រាយបំភ្លឺនៅក្នុង និងនៅក្រៅមជ្ឈដ្ឋានអប់រំ។

### ១. ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយអាចផ្តោតលើ៖

- ការវាយតម្លៃហានិភ័យ និងការព្រមានជាមុនសម្រាប់អំពើឃោរឃៅទ្រង់ទ្រាយធំ។
- ការវិភាគ និងការស្រាវជ្រាវជម្លោះ។
- មូលហេតុ ផ្លូវទៅរកភាពធ្ងន់ធ្ងរ និងការកាត់បន្ថយជម្លោះ។
- ករណីសិក្សាអំពីស្ថានភាពប្រទេសកាលពីអតីតកាល ដែលនឹងកើតមានឡើង និងបច្ចុប្បន្ន ព្រមទាំងប្រភេទនៃវិធានការដែលចាំបាច់ត្រូវតែកំណត់ ដើម្បីទប់ស្កាត់ និងឆ្លើយតបជាពិសេសទៅនឹងឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការរំលោភបំពាន។
- ការបញ្ជាក់ឲ្យបានច្បាស់អំពីបញ្ហាប្រឈមផ្នែកទស្សនៈទាន និងអនុវត្តន៍សម្រាប់ទំនួលខុសត្រូវក្នុងការការពារ (RtoP)។

### ២. ការអប់រំអំពីទំនួលខុសត្រូវក្នុងការការពារ (RtoP) អាចត្រូវបានបញ្ចូលទៅក្នុងវិស័យដូចខាងក្រោមនៃការសិក្សា ក្នុងចំណោមវិស័យផ្សេងទៀត៖

- សន្តិភាព និងជម្លោះ
- ការសិក្សាអំពីអំពើប្រល័យពូជសាសន៍
- ការទប់ស្កាត់
- ទំនាក់ទំនងអន្តរជាតិ
- ច្បាប់អន្តរជាតិ
- យុត្តិធម៌អន្តរកាល
- ការរក្សាសន្តិភាព និងការកសាងសន្តិភាព

## តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយ៖ តើតំណាងប្រព័ន្ធផ្សព្វផ្សាយអាចធ្វើអ្វីខ្លះ ដើម្បីការពារប្រជាជន?

អ្នកសារព័ត៌មាន និងបុគ្គលវិជ្ជាជីវៈនៃប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត ជាញឹកញាប់ គឺជាសាក្សីនៃស្ថានភាពដែលជនស៊ីវិលស្ថិតក្នុងហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅ ឬការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរផ្សេងទៀត និងដោយហេតុនេះហើយ បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ (សារព័ត៌មាន ទស្សនាវដ្ដី ទិនានុប្បវត្តិ វិទ្យុអ៊ីនធឺណិត និងទូរទស្សន៍) ជាបណ្ដាញមួយនៃពិភពលោក ដើម្បីជូនដំណឹង និងជំរុញឲ្យមានវិធានការទប់ស្កាត់។ ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបណ្ដាញសង្គម ដូចជា Twiter, Facebook និង Youtube បានអនុញ្ញាតឲ្យបុគ្គលទាំងឡាយអាចចែករំលែកខ្លឹមសារដែលអាចមើលបានភ្លាមៗនៅទូទាំងពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ ភាពផ្ទុយគ្នាទាំងស្រុងមួយក៏កើតមានឡើងផងដែរទាក់ទងនឹងតួនាទីដែលប្រព័ន្ធផ្សព្វផ្សាយអាចមាន៖ ទោះបីជាប្រព័ន្ធផ្សព្វផ្សាយមានតួនាទីជូនដំណឹង និងជំរុញឲ្យមានប្រតិកម្មទប់ស្កាត់ក៏ដោយ វាអាចត្រូវបានប្រើប្រាស់មិនត្រឹមត្រូវ ដើម្បីគាំទ្រភាគីវិវាទ ឬរដ្ឋាភិបាលដែលគាបសង្កត់ ក្នុងគោលបំណងញុះញង់ឲ្យមានអំពើឃោរឃៅទ្រង់ទ្រាយធំ។

### តើប្រព័ន្ធផ្សព្វផ្សាយអាចចូលរួមនៅក្នុងការរាយការណ៍ប្រកបដោយទំនួលខុសត្រូវនៅក្នុងស្ថានភាពអំពើឃោរឃៅទ្រង់ទ្រាយធំយ៉ាងដូចម្ដេច?

អ្នកសារព័ត៌មាន និងបុគ្គលិកវិជ្ជាជីវៈនៃប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត គួរ៖

- ធានានូវការរាយការណ៍ប្រកបដោយតុល្យភាពអំពីព្រឹត្តិការណ៍ និងស្ថានភាពសំខាន់ៗ។
- ប្រើប្រាស់បច្ចេកវិទ្យាផ្សព្វផ្សាយថ្មីៗ ដើម្បីផ្សព្វផ្សាយការរាយការណ៍នេះទៅដល់ជនគោលដៅកាន់តែច្រើន និងមានលក្ខណៈចម្រុះជាងមុន។
- គាំទ្រដល់អ្នកឆ្លើយឆ្លងបរទេស ដែលអាចយកព័ត៌មានអំពីស្ថានភាពនានាសម្រាប់រយៈពេលវែងជាងនេះ។
- ធានានូវការបណ្ដុះបណ្ដាលប្រកបដោយវិជ្ជាជីវៈគ្រប់គ្រាន់ និងបទដ្ឋានខ្ពស់នៃការអនុវត្តផ្នែកសារព័ត៌មានក្នុងចំណោមបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ។
- គាំទ្រប្រភពនៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងចម្រុះ ដើម្បីឲ្យសាធារណជនទទួលបានទស្សនៈផ្សេងៗគ្នា។
- យកចិត្តទុកដាក់ចំពោះការរំលោភសិទ្ធិមនុស្សទ្រង់ទ្រាយធំ និងលក្ខខណ្ឌនានាដែលនាំឲ្យមានអំពើឃោរឃៅទ្រង់ទ្រាយធំ។

## តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយ៖ តើអ្នកអាចប្រើប្រាស់បណ្តាញផ្សព្វផ្សាយ ដើម្បីការពារប្រជាជនយ៉ាងដូចម្តេច?

### តើតួអង្គផ្សេងទៀតអាចពិនិត្យតាមដាន និងចូលរួមជាមួយប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពយ៉ាងដូចម្តេច?

សង្គមស៊ីវិល និងមន្ត្រីការទូតថ្នាក់ជាតិ តំបន់ និងអន្តរជាតិ គួរ៖

- ផ្ទៀងផ្ទាត់ វិភាគ និងផ្សព្វផ្សាយព័ត៌មានឲ្យបានច្រើន ដែលទទួលបានពីសាក្សីឃើញផ្ទាល់ភ្នែកនានា។
- បកប្រែព័ត៌មាននៅក្នុងរបាយការណ៍អំពីអំពើឃោរឃៅជាភាសាផ្សេងទៀត ដើម្បីធានាថា អ្នករាល់គ្នាយល់ច្បាស់ និងទទួលបានព័ត៌មានទាំងនេះ។
- ផ្តល់សិទ្ធិដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងការចូលទៅដល់ និងមានសេរីភាពដើរហើរនៅក្នុងបណ្តាប្រទេសដែលឧក្រិដ្ឋកម្មទាំងនេះកំពុងមានការគំរាមគំហែង ឬកំពុងកើតមានឡើង សំដៅជួយដល់ការទទួលបាន និងរាយការណ៍អំពីហេតុការណ៍នានា។
- ធានានូវសុវត្ថិភាពសម្រាប់អ្នករាយការណ៍ និងអ្នកសារព័ត៌មាន ដែលធ្វើការនៅក្នុងប្រទេសមានជម្លោះ។
- រាយការណ៍ និងតបតចំពោះករណីនៃការញុះញង់ ដូចជា តាមរយៈការផ្សព្វផ្សាយសារដែលលើកទឹកចិត្តឲ្យមានភាពចម្រុះ និងជំរុញឲ្យមានការដាក់កំហិត។
- អនុញ្ញាត ឬធ្វើការតស៊ូមតិសម្រាប់ពលរដ្ឋនៅក្នុងប្រទេសទាំងអស់ឲ្យទទួលបាន និងចូលរួមនៅក្នុងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ចម្រុះ និងយុត្តិធម៌។

## តើរដ្ឋាភិបាលរបស់អ្នក - និងបណ្តារដ្ឋទាំងអស់ - អាចលើកស្ទួយ និងអនុវត្តទំនួលខុសត្រូវក្នុងការការពារ (RtoP) យ៉ាងដូចម្តេច?

រដ្ឋមានទំនួលខុសត្រូវចម្បងក្នុងការការពារប្រជាជនរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការលុបបំបាត់ជាតិសាសន៍។ រដ្ឋាភិបាលទាំងឡាយក៏គួរចងចាំផងដែរអំពីទំនួលខុសត្រូវរបស់ខ្លួន ក្នុងការជួយរដ្ឋផ្សេងទៀតក្នុងការប្រកាន់យកកាតព្វកិច្ចការពាររបស់ពួកគេ និងក្នុងការរួមចំណែកចំពោះការឆ្លើយតបរួមគ្នា ប្រសិនបើរដ្ឋណាមួយខកខានមិនបានទប់ស្កាត់អំពើឃោរឃៅទ្រង់ទ្រាយធំនៅក្នុងព្រំដែនរបស់ខ្លួន។ រដ្ឋាភិបាលទាំងឡាយអាចចាត់វិធានការជាច្រើនដើម្បីលើកស្ទួយទំនួលខុសត្រូវក្នុងការការពារ (RtoP) និងកសាងសមត្ថភាពថ្នាក់ជាតិ ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះការគំរាមកំហែងនៃឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការរំលោភបំពាន៖

### ១. ការគាំទ្រតាមបទដ្ឋាន និងស្ថាប័នសម្រាប់ទំនួលខុសត្រូវក្នុងការការពារ (RtoP)

- ចូលរួមនៅក្នុងកិច្ចពិភាក្សាអន្តរជាតិ និងថ្នាក់តំបន់អំពីទំនួលខុសត្រូវក្នុងការការពារ (RtoP) និងអនុម័តបទដ្ឋាននេះនៅក្នុងសេចក្តីថ្លែងការណ៍ និងជំហោះស្រាយផ្លូវការ។
- បង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍រួមមួយ ឬក្រុមសភាទទួលបន្ទុកទំនួលខុសត្រូវក្នុងការការពារ (RtoP)។
- តែងតាំងជនបង្គោលថ្នាក់ជាតិ ឬមន្ត្រីជាន់ខ្ពស់មួយក្រុម ដើម្បីធ្វើការតស៊ូមតិសម្រាប់ការអនុវត្តន៍ទំនួលខុសត្រូវក្នុងការការពារ (RtoP)ថ្នាក់ជាតិ។

### ២. កាត់បន្ថយហានិភ័យនៃការគំរាមកំហែងនៃឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការរំលោភបំពាន

- ឆ្លុះបញ្ចាំងអំពីគោលនយោបាយដែលមានស្រាប់ ដើម្បីគាំទ្រចំពោះភាពចម្រុះ បង្កើនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងរក្សាវិស័យសន្តិសុខត្រឹមត្រូវ និងពិចារណាអំពីរបៀបបញ្ចូលកញ្ចក់ឆ្លុះបញ្ចាំងអំពើឃោរឃៅទ្រង់ទ្រាយធំទៅក្នុងស្ថាប័នទាំងនេះ។
- ផ្តល់អាទិភាពដល់ការទប់ស្កាត់អំពើឃោរឃៅទ្រង់ទ្រាយធំនៅក្នុងយុទ្ធសាស្ត្រសន្តិសុខជាតិ សៀវភៅសការពារជាតិ ។ល។
- អនុម័តច្បាប់ក្នុងស្រុកប្រឆាំងនឹងឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP )និងការរំលោភបំពាន និងច្បាប់ស្តីពីការការពារសិទ្ធិសម្រាប់ក្រុមជនជាតិភាគតិច ស្ត្រី ជនភៀសខ្លួន និងប្រជាជនងាយរងគ្រោះផ្សេងទៀត។
- ផ្តល់សច្ចាប័ន និងអនុវត្តកាតព្វកិច្ចនៃលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធអំពីសិទ្ធិមនុស្ស ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ស្តីពីជនភៀសខ្លួន និងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។
- ធានា និង/ឬសម្របសម្រួលការងាររបស់អង្គការអន្តរជាតិ និងថ្នាក់តំបន់ រួមទាំង តាមរយៈការរួមចំណែកចំពោះប្រតិបត្តិការរក្សាសន្តិភាព និងការគាំទ្រកិច្ចប្រឹងប្រែង ដើម្បីពង្រឹងអង្គភាពក្នុងមូលដ្ឋាន ដូចជា នគរបាល ទាហាន តុលាការ អ្នកតាក់តែងច្បាប់ និងបុគ្គលផ្សេងទៀតដែលជួយត្រួតពិនិត្យការអនុវត្តសិទ្ធិមនុស្ស និងបទដ្ឋានមនុស្សធម៌។

## តើរដ្ឋាភិបាលរបស់អ្នក - និងបណ្តារដ្ឋទាំងអស់ - អាចលើកស្ទួយ និងអនុវត្តទំនួលខុសត្រូវក្នុងការការពារ (RtoP) យ៉ាងដូចម្តេច?

### ៣. ទប់ស្កាត់ការរីករាលដាលនៃជម្លោះ តាមរយៈការទទួលស្គាល់ជាមុន ដំណោះស្រាយវិវាទ និងការផ្សះផ្សា

- បង្កើតស្ថាប័នជាតិឯករាជ្យ ដូចជា គណៈកម្មការសិទ្ធិមនុស្សដែលមានសមាជិកចម្រុះ រួមទាំងសមាជិកនៃក្រុមជនជាតិភាគតិច និងក្រុមសាសនាភាគតិច និងស្ត្រី ដើម្បីធ្វើសកម្មភាពជា "អ្នកឃ្លាំមើល" និងការពារសិទ្ធិមនុស្ស។
- ពិនិត្យឡើងវិញលើយន្តការព្រមានជាមុនសម្រាប់ការទប់ស្កាត់អំពើឃោរឃៅទ្រង់ទ្រាយធំ បង្កើនការយល់ដឹងអំពីសូចនាករពាក់ព័ន្ធ ដូចជា អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រ និងពាក្យសម្តីដែលជំរុញឲ្យមានការស្អប់ខ្ពើម ឬការវាយប្រហារខ្លាំងឡើងៗលើសហគមន៍ជនជាតិភាគតិច និងធានាថា ព័ត៌មានព្រមានជាមុនពីថ្នាក់មូលដ្ឋានត្រូវបានប្រមូល វិភាគ និងចែករំលែកជាមួយនឹងតួអង្គពាក់ព័ន្ធនានា។
- កែលម្អការសម្របសម្រួលក្នុងចំណោមការិយាល័យរដ្ឋាភិបាល ដើម្បីឆ្លើយតបចំពោះស្ថានភាពទំនួលខុសត្រូវក្នុងការការពារ (RtoP) ដែលអាចកើតឡើង ឬកំពុងបន្ត។
- ពង្រឹងការសម្របសម្រួលថ្នាក់ជាតិ និងមូលដ្ឋាន ដំណោះស្រាយវិវាទ និងសមត្ថភាពស្វែងរកការពិត។
- បណ្តុះបណ្តាលបុគ្គលិកសន្តិសុខ និងរក្សាសន្តិភាព ដើម្បីត្រៀមរៀបចំប្រតិបត្តិការការពារ និងបង្កើនសុវត្ថិភាពជនស៊ីវិលជាអតិបរមា រួមទាំង តាមរយៈការផ្តល់ការណែនាំអំពីការកាត់បន្ថយជនរងគ្រោះស៊ីវិលឲ្យនៅកម្រិតអប្បបរមា ព្រមទាំងទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រ និងការគំរាមកំហែងចំពោះកុមារនៅក្នុងជម្លោះប្រដាប់អាវុធ។
- ធានាថាមានស្ថាប័នតុលាការសម្រាប់ដំណើរការរឿងក្តី ដើម្បីឲ្យរដ្ឋាភិបាលអាចផ្តន្ទាទោស និងស៊ើបអង្កេតជនប្រព្រឹត្តអំពើហិង្សាទ្រង់ទ្រាយធំ ឬគាំទ្រករណីស្រដៀងគ្នា នៅក្នុងតុលាការថ្នាក់តំបន់ ឬតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។
- លើកទឹកចិត្តដល់ការផ្សះផ្សា និងការប្រាប់ការពិត តាមរយៈគណៈកម្មការសន្តិភាព និងផ្សះផ្សាជាតិ។

## តើសមាជិកសភាអាចគាំទ្រទំនួលខុសត្រូវក្នុងការការពារ (RtoP) យ៉ាងដូចម្តេច?

សមាជិកសភាអាចប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនជាមួយរដ្ឋាភិបាលរបស់ពួកគេ ដើម្បីបង្កើនការគាំទ្ររបស់រដ្ឋចំពោះទំនួលខុសត្រូវក្នុងការការពារ (RtoP) និងពង្រឹងសមត្ថភាពថ្នាក់ជាតិ ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពាន យោងតាមក្របខ័ណ្ឌនៃបទដ្ឋាន។

នៅថ្ងៃ២៧ ខែមីនា ឆ្នាំ២០១៣ នៅក្នុងសន្និបាទលើកទី ១២៨ របស់ខ្លួននៅទីក្រុង Quito ប្រទេសអេក្វាឌ័រ សហភាពអន្តរសភា (IPU) បានអនុម័តសេចក្តីសម្រេចមួយ "ការអនុវត្តទំនួលខុសត្រូវក្នុងការការពារៈ តួនាទីរបស់សមាជិកសភានៅក្នុងការការពារអាយុជីវិតរបស់ជនស៊ីវិល"។

ឧបករណ៍ពាក់ព័ន្ធមួយចំនួនដែលត្រូវបានកំណត់នៅក្នុងដំណោះស្រាយសហភាពអន្តរសភា (IPU) ដែលតំណាងរាស្ត្រអាចប្រើប្រាស់មានដូចខាងក្រោមៈ

- លើកស្ទួយការអប់រំ និងការលើកកម្ពស់ការយល់ដឹងសាធារណៈក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការលុបបំបាត់ជាតិសាសន៍។
- ប្រើប្រាស់បណ្តាញសង្គម ដើម្បីថ្កោលទោសអំពើហិង្សាប្រឆាំងនឹងស្ត្រី និងកុមារ និងដើម្បីប្រយុទ្ធប្រឆាំងនិទណ្ឌភាព។
- អនុម័តច្បាប់ និងគោលនយោបាយ ដើម្បីការពារស្ត្រី និងកុមារ ទប់ស្កាត់ និងកំណត់អំពើហិង្សាផ្លូវភេទជាបទល្មើសព្រហ្មទណ្ឌ ព្រមទាំងផ្តល់សំណងដល់ជនរងគ្រោះក្នុងពេលមានសន្តិភាព និងជម្លោះ រួមទាំងការអនុវត្តសេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។
- ធានាថា សន្ធិសញ្ញាអន្តរជាតិ ដែលមានបណ្តារដ្ឋនានា ជាភាគី ត្រូវបានបញ្ចូលនៅក្នុងច្បាប់ជាតិ ជាពិសេស ច្បាប់ទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស និងការការពារជនស៊ីវិល។
- អនុម័តវិធានការនានា ដើម្បីគោរពសិទ្ធិជនស៊ីវិលដែលស្ថិតនៅក្នុងជម្លោះប្រដាប់អាវុធ។
- ចាត់វិធានការចាំបាច់នានាដើម្បីនាំមកនូវច្បាប់ព្រហ្មទណ្ឌ និងយោធារបស់រដ្ឋទាំងឡាយស្របតាមច្បាប់អន្តរជាតិ ដើម្បីការពារជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ។
- ប្រើប្រាស់បណ្តាញអន្តរជាតិរបស់សមាជិកសភា ដើម្បីជំរុញឲ្យមានការផ្តល់សច្ចាប័នជាសកលលើលក្ខន្តិកៈទីក្រុងរ៉ូម (តុលាការព្រហ្មទណ្ឌអន្តរជាតិ)។
- លើកទឹកចិត្តដល់រដ្ឋាភិបាលនីមួយៗឲ្យគាំទ្រនូវការបង្កើត និងការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនៃប្រព័ន្ធផ្តល់ការព្រមាន និងការឆ្លើយតបជាមុននៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។
- បញ្ចូលមូលនិធិទៅក្នុងថវិកាជាតិរបស់រដ្ឋសម្រាប់ការការពារប្រជាជនពីអំពើហិង្សា និងធានានូវសុវត្ថិភាពរបស់ពួកគេ និង
- ទទួលយកទំនួលខុសត្រូវក្នុងការការពារសិទ្ធិរបស់ជនភៀសខ្លួន និងសិទ្ធិរបស់ពួកគេក្នុងការទទួលបានកិច្ចការពារជាអន្តរជាតិ រួមទាំងកិច្ចបំពេញកាតព្វកិច្ចរបស់រដ្ឋរបស់ពួកគេក្នុងការការពារជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន។

### តើសមាជិកសភាអាចធ្វើអ្វីខ្លះ ដើម្បីលើកស្ទួយបទដ្ឋាន និងលើកទឹកចិត្តដល់ការទប់ស្កាត់អំពើឃោរឃៅទ្រង់ទ្រាយធំ?

- ស្នើឡើងនូវដំណោះស្រាយដែលអនុម័តទំនួលខុសត្រូវក្នុងការការពារ (RtoP) ដែលអាចរួមមាន៖
  - ការរំឭកឡើងវិញថា ទំនួលខុសត្រូវចម្បងក្នុងការការពារប្រជាជនពីឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ គឺជាទំនួលខុសត្រូវរបស់រដ្ឋ និងថា ទំនួលខុសត្រូវនេះ ត្រូវបានទទួលយកដោយសហគមន៍អន្តរជាតិ ប្រសិនបើរដ្ឋនោះខកខានមិនបានប្រកាន់យកកាតព្វកិច្ចការពាររបស់ខ្លួនទេនោះ។
  - ការអះអាងថា មានឧក្រិដ្ឋកម្មជាក់លាក់បួនប្រភេទ ដែលឈានដល់កម្រិតសម្រាប់ស្ថានភាពទំនួលខុសត្រូវក្នុងការការពារ (RtoP)៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការលុបបំបាត់ជាតិសាសន៍។
  - ការទទួលស្គាល់ថា អ្វីដែលចំបង និងសំខាន់បំផុតនោះគឺទំនួលខុសត្រូវក្នុងការការពារ (RtoP) ពាក់ព័ន្ធនឹងការទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនេះដោយប្រើវិធានការមិនមែនយោធា និងថា ការប្រើប្រាស់កម្លាំង គឺជាជម្រើសចុងក្រោយដែលអាចត្រូវបានអនុញ្ញាតដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិប៉ុណ្ណោះ ដើម្បីទប់ស្កាត់ ឬបញ្ឈៀសអំពើឃោរឃៅទ្រង់ទ្រាយធំ ប្រសិនបើរដ្ឋនោះពុំមានឆន្ទៈ ឬមិនអាចធ្វើដូច្នោះបាន និងប្រសិនបើមធ្យោបាយដោយសន្តិវិធីនានាបានបរាជ័យ។
- បែងចែកមូលនិធិសម្រាប់ការការពារជនរងគ្រោះ។
- បង្កើតក្រុមសភាតាមមូលបទដែលផ្តោតលើការទប់ស្កាត់អំពើឃោរឃៅទ្រង់ទ្រាយធំ និងចូលរួមជាមួយក្រុមសមាជិកសភាបែបនេះមកពីបណ្តាប្រទេសផ្សេងទៀតលើការទប់ស្កាត់អំពើឃោរឃៅទ្រង់ទ្រាយធំ។

### តើសមាជិកសភាអាចបង្កើនការចូលរួមរបស់រដ្ឋាភិបាល និងការអនុវត្តទំនួលខុសត្រូវក្នុងការការពារយ៉ាងដូចម្តេច?

- អំពាវនាវឲ្យមានយុទ្ធសាស្ត្រសន្តិសុខថ្នាក់ជាតិ ដើម្បីបញ្ចូលការការពារប្រជាជនពីឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការរំលោភបំពាន។
- ធ្វើសវនាការ និងរៀបចំការពិភាក្សាដេញដោល ដើម្បីវាយតម្លៃសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់ អំពើឃោរឃៅទ្រង់ទ្រាយធំ រួមទាំង តាមរយៈការពិនិត្យឡើងវិញនូវព័ត៌មានសម្ងាត់ និងសមត្ថភាពព្រមានជាមុន ការវាយតម្លៃធនធានដែលអាចមានសម្រាប់ការទប់ស្កាត់ការឆ្លើយតប និងការកសាងឡើងវិញ និងការពិនិត្យមើលស្ថាប័ន គោលនយោបាយ និងសមត្ថភាពទូទៅរបស់រដ្ឋក្នុងការប្រើប្រាស់វិធានការនានា ដើម្បីទប់ស្កាត់ ឬបញ្ឈប់ឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការរំលោភបំពាន និងដាក់ទណ្ឌកម្មចំពោះជនល្មើស។
- បោះពុម្ពផ្សាយរបាយការណ៍ និងផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលផ្អែកលើលទ្ធផលរកឃើញនៃសវនាការ និងការពិភាក្សាដេញដោលអំពីសមត្ថភាពរបស់រដ្ឋ។

## តើកិច្ចព្រមព្រៀងថ្នាក់តំបន់ និងអនុតំបន់អាចការពារប្រជាជនពីឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការរំលោភបំពានយ៉ាងដូចម្តេច?

កិច្ចព្រមព្រៀងថ្នាក់តំបន់ និងអនុតំបន់កំពុងតែបង្កើនការអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួន ដើម្បីឆ្លើយតបឲ្យបានទាន់ពេលវេលា និងម៉ឺងម៉ាត់ សំដៅការពារប្រជាជនដែលស្ថិតក្នុងហានិភ័យនៃអំពើឃោរឃៅទ្រង់ទ្រាយធំ។ ជាញឹកញាប់ បុគ្គលដំបូងគេដែលដឹងអំពីស្ថានភាពទាំងនេះ ពួកគេអាចចាត់វិធានការទប់ស្កាត់ ដោយប្រើប្រាស់ការយល់ដឹងជាក់លាក់របស់ពួកគេ និងឥទ្ធិពលនៅក្នុងតំបន់របស់ពួកគេ ឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងវិបត្តិដែលនឹងកើតមានឡើង ឬកំពុងបន្ត និងព្រមានតួអង្គផ្សេងទៀតអំពីភាពបន្ទាន់នៃស្ថានភាព៖

### ១.ទប់ស្កាត់ឧក្រិដ្ឋកម្មទំនួលខុសត្រូវក្នុងការការពារ (RtoP) និងការរំលោភបំពាន

- បង្កើត និងអនុវត្តលក្ខណៈវិនិច្ឆ័យសមាជិកភាពអង្គការទាក់ទងនឹងការរំលោភបំពានសិទ្ធិមនុស្ស និងឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ។
- បង្កើត ឬប្រើប្រាស់យន្តការព្រមានជាមុនដែលមានស្រាប់ ដើម្បីទាក់ទាញចំណាប់អារម្មណ៍ចំពោះស្ថានភាពនានាដែលប្រជាជនត្រូវបានគំរាមកំហែង។
- ចែករំលែកព័ត៌មានអំពីវិបត្តិដែលអាចកើតមាន ឬកំពុងបន្ត ជាមួយនឹងសមាជិករបស់ខ្លួន និងអង្គការថ្នាក់តំបន់ និងអន្តរជាតិផ្សេងទៀត។
- ទប់ស្កាត់ការញុះញង់ តាមរយៈការពិនិត្យតាមដានសេចក្តីថ្លែងការណ៍អុចអាលដែលចេញដោយប្រព័ន្ធផ្សព្វផ្សាយថ្នាក់ជាតិ និងតំបន់ និងទីភ្នាក់ងាររដ្ឋាភិបាល។

### ២.ឆ្លើយតបយ៉ាងទាន់ពេលវេលា និងម៉ឺងម៉ាត់ចំពោះការគំរាមកំហែង ឬការកើតឡើងនូវអំពើឃោរឃៅទ្រង់ទ្រាយធំ

- ដាក់សម្ពាធផ្នែកការទូត តាមរយៈសេចក្តីថ្លែងការណ៍អំពីកង្វល់ និង/ឬការរំឭកអំពីបេសកជន។
- បង្កើតបេសកកម្មស្វែងរកការពិត និងគណៈកម្មការស៊ើបសួរ ដើម្បីស៊ើបអង្កេត និងរាយការណ៍អំពីករណីដែលត្រូវបានអះអាងថាជាការគំរាមកំហែងដល់ប្រជាជន។
- សម្របសម្រួលទំនាក់ទំនងការទូតជាការបង្ការ ដែលអាចមានជាការបញ្ជូនបុគ្គលដ៏ឧត្តុងឧត្តម និងការតែងតាំងបេសកជនឲ្យផ្តួចផ្តើមកិច្ចពិភាក្សា ឬជំនួយក្នុងការសម្រុះសម្រួល។
- អនុម័តទណ្ឌកម្មការទូតដែលផ្តោតគោលដៅជាក់លាក់ បម្រាមលើការធ្វើដំណើរ ការបង្កកទ្រព្យសម្បត្តិ ទណ្ឌកម្មសេដ្ឋកិច្ច និងអាវុធ ព្រមទាំងផ្អាកជំនួយ។
- ដាក់ពង្រាយយោធា នគរបាល និងបុគ្គលិកស៊ីវិលសម្រាប់ការរក្សាសន្តិភាព ការពិនិត្យតាមដាន និងបេសកកម្មការពារជនស៊ីវិល ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ។
- សហប្រតិបត្តិការជាមួយនឹងស្ថាប័នតុលាការថ្នាក់តំបន់ ឬអំពាវនាវឲ្យមានការបញ្ជូនសំណុំរឿងទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។



សម្ព័ន្ធរដ្ឋអារ៉ាប់រៀបចំសន្និសីទស្តីពីប្រទេសលីប៊ីនៅទីក្រុងគៃរ៉ូក្នុងខែមេសា ឆ្នាំ២០១១។ ប្រភព៖ រូបថតរបស់អង្គការសហប្រជាជាតិ ដោយ Paulo Filgueiras។

# ផ្នែកទី ៣៖

# សម្រាប់ព័ត៌មានបន្ថែមអំពីទំនួលខុសត្រូវក្នុងការការពារ

## ស្វែងយល់បន្ថែមទៀតអំពីទំនួលខុសត្រូវក្នុងការការពារ (RtoP)

### ឯកសារស្នូល

- ច្បាប់ស្ថាប័ននៃសហភាពអាហ្វ្រិក (ឆ្នាំ២០០០)
- របាយការណ៍របស់គណៈកម្មការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍ និងអធិបតេយ្យភាពរដ្ឋ (ឆ្នាំ២០០១)
- របាយការណ៍របស់គណៈកម្មាធិការជាន់ខ្ពស់នៃអគ្គលេខាធិការ ទទួលបន្ទុកការគំរាមកំហែង បញ្ហាប្រឈម និងការផ្លាស់ប្តូរ "ពិភពលោកកាន់តែមានសន្តិសុខ៖ ទំនួលខុសត្រូវរួមរបស់យើង" (ឆ្នាំ២០០៤)
- របាយការណ៍របស់អគ្គលេខាធិការ "នៅក្នុងសេរីភាពកាន់តែទូលំទូលាយ៖ ឆ្ពោះទៅរកការអភិវឌ្ឍន៍ សន្តិសុខ និងសិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា" (ឆ្នាំ២០០៥)
- ឯកសារលទ្ធផលជំនួបកំពូលពិភពលោក ឆ្នាំ២០០៥ (សូមមើលកថាខ័ណ្ឌ ១៣៨-១៤០)
- របាយការណ៍របស់អគ្គលេខាធិការ លោក បាន គីមូន៖ "ការអនុវត្តទំនួលខុសត្រូវក្នុងការការពារ" (ឆ្នាំ២០០៩) "ការព្រមានជាមុន ការវាយតម្លៃ និងទំនួលខុសត្រូវក្នុងការការពារ" (ឆ្នាំ២០១០) "តួនាទីនៃកិច្ចព្រមព្រៀងថ្នាក់តំបន់ និងអនុតំបន់ក្នុងការអនុវត្តទំនួលខុសត្រូវក្នុងការការពារ" (ឆ្នាំ២០១១) "ទំនួលខុសត្រូវក្នុងការការពារ៖ ការឆ្លើយតបទាន់ពេលវេលា និងម៉ឺងម៉ាត់" (ឆ្នាំ២០១២) និង "ទំនួលខុសត្រូវក្នុងការការពារ៖ ទំនួលខុសត្រូវរបស់រដ្ឋ និងការការពារ" (ឆ្នាំ២០១៣)
- សហភាពអន្តរសភា៖ "ការអនុវត្តទំនួលខុសត្រូវក្នុងការការពារ៖ តួនាទីរបស់សមាជិកសភានៅក្នុងការការពារអាយុជីវិតជនស៊ីវិល" (ឆ្នាំ២០១៣)។

### ធនធានគន្លឹះ

វែបសាយត៍របស់**សម្ព័ន្ធអន្តរជាតិសម្រាប់ទំនួលខុសត្រូវក្នុងការការពារ** មានមជ្ឈមណ្ឌលធនធានដ៏ពេញលេញមួយស្តីពីបទដ្ឋាន។ សូមចូលទៅកាន់វែបសាយត៍ **www.responsibilitytoprotect.org** ដើម្បីស្វែងយល់បន្ថែម។ វែបសាយត៍ និងគេហទំព័រតំណភ្ជាប់ (Portals)សំខាន់ៗផ្សេងទៀត រួមមាន៖

- មជ្ឈមណ្ឌលអាស៊ីប៉ាស៊ីហ្វិកសម្រាប់ទំនួលខុសត្រូវក្នុងការការពារ www.r2pasiapacific.org
- សហការថ្នាក់តំបន់ទៅលើការស៊ើបអង្កេតសេដ្ឋកិច្ច និងសង្គម (ភាសាអេស្ប៉ាញ) www.cries.org
- ការព្រមានអំពីអំពើប្រល័យពូជសាសន៍ (ភាសាអាល្លឺម៉ង់) www.schutzverantwortung.de
- មជ្ឈមណ្ឌលសកលសម្រាប់ទំនួលខុសត្រូវក្នុងការការពារ www.globalr2p.org
- មូលនិធិ Stanley, http://www.stanleyfoundation.org/programs.cfm?id=27
- ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងទំនួលខុសត្រូវក្នុងការការពារ www.un.org/en/preventgenocide/adviser
- សហព័ន្ធពិភពលោកនៃសមាគមអង្គការសហប្រជាជាតិ, www.wfuna.org/r2p-activities

# អំពីសម្ព័ន្ធអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ

សម្ព័ន្ធអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ ឬ ICRtoP គឺជាបណ្តាញសកលមួយនៃអង្គការសង្គមស៊ីវិល ដែលប្តេជ្ញាចិត្តចំពោះការពង្រឹងទំនួលខុសត្រូវក្នុងការការពារ (RtoP) នៅថ្នាក់អន្តរជាតិ តំបន់ អនុតំបន់ និងថ្នាក់ជាតិ។ ដោយត្រូវបានបង្កើតឡើងក្នុងខែមករា ឆ្នាំ២០០៩ សម្ព័ន្ធអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពា (ICRtoP) មានសមាជិកនានាដែលតំណាងឲ្យគ្រប់តំបន់ និងធ្វើការនៅក្នុងវិស័យជាច្រើន ដូចជា សិទ្ធិនារី ការបង្ការជម្លោះ សិទ្ធិមនុស្ស យុត្តិធម៌អន្តរជាតិ និងតំបន់ និងការផ្តល់សេវាមនុស្សធម៌។

សមាជិកសម្ព័ន្ធអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ (ICRtoP) ព្យាយាម ដើម្បីៈ

១. បង្កើនការយល់ដឹងអំពីទំនួលខុសត្រូវក្នុងការការពារ (RtoP) ក្នុងចំណោមរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងសាធារណជន។
២. ជំរុញឲ្យមានការអនុម័តទំនួលខុសត្រូវក្នុងការការពារ (RtoP) នៅថ្នាក់អន្តរជាតិ តំបន់ អនុតំបន់ និងថ្នាក់ជាតិ។
៣. លើកទឹកចិត្តដល់រដ្ឋាភិបាលនានា អង្គការថ្នាក់តំបន់ និងអនុតំបន់ និងអង្គការសហប្រជាជាតិឲ្យកសាងសមត្ថភាព ដើម្បីទប់ស្កាត់ និងបញ្ឈប់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការលុបបំបាត់ជាតិសាសន៍។
៤. ជួយកសាង និងពង្រឹងការគាំទ្រជាសកលសម្រាប់ទំនួលខុសត្រូវក្នុងការការពារ (RtoP)។
៥. ប្រមូលផ្តុំអង្គការសង្គមស៊ីវិល ដើម្បីជំរុញឲ្យមានវិធានការសង្គ្រោះអាយុជីវិតនៅក្នុងស្ថានភាពនៃប្រទេសជាក់លាក់ សម្រាប់ទំនួលខុសត្រូវក្នុងការការពារ (RtoP)។

សមាជិកសម្ព័ន្ធអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ (ICRtoP) ប្តេជ្ញាចិត្តចំពោះការលើកស្ទួយទំនួលខុសត្រូវក្នុងការការពារ))RtoP) តាមរយៈការកែលម្អ ការយល់ដឹង និងការកៀរគរការគាំទ្រចំពោះគោលការណ៍នៃបទដ្ឋាន ព្រមទាំងការតស៊ូមតិចំពោះ - និង ប្រសិនបើអាចធ្វើទៅបាន ពង្រឹងដោយផ្ទាល់ - នូវសមត្ថភាពនានាដែលចាំបាច់ ដើម្បីទប់ស្កាត់ និងបញ្ឈប់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការលុបបំបាត់ជាតិសាសន៍។ សមាជិកសម្ព័ន្ធបោះពុម្ពផ្សាយទិនានុប្បវត្តិនានា បង្កើតបណ្តុំឧបករណ៍ និងឯកសារអប់រំ ព្រមទាំងរៀបចំសិក្ខាសាលា និងសន្និសីទសម្រាប់មន្ត្រីការទូត មន្ត្រីអង្គការសហប្រជាជាតិ និងមន្ត្រីថ្នាក់តំបន់ តំណាងរាស្ត្រ បណ្ឌិត្យសភា ក្រុមប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិលផ្សេងទៀត។ លេខាធិការដ្ឋានសមាជិកសម្ព័ន្ធអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ (ICRtoP) ដែលរៀបចំឡើងដោយចលនាសហព័ន្ធពិភពលោក-វិទ្យាស្ថានគោលនយោបាយសកលក្នុងទីក្រុងញូវយ៉ក រក្សាព័ត៌មាន និងបណ្តាញផ្សព្វផ្សាយសង្គមជាច្រើន ដែលអាចត្រូវបានប្រើប្រាស់ ដើម្បីធ្វើបច្ចុប្បន្នកម្មសមាជិកភាពយ៉ាងឆាប់រហ័ស និងដៃគូផ្សេងទៀត ផ្អែកលើស្ថានភាពក្នុងប្រទេស ជួយនៅក្នុងការស្រាវជ្រាវ និងសម្របសម្រួលទំនាក់ទំនង និងកិច្ចសហការ។

ការបកប្រែឯកសារនេះត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលអាស៊ីប៉ាស៊ីហ្វិកដើម្បីទំនួលខុសត្រូវក្នុងការការពារ។ មជ្ឈមណ្ឌលអាស៊ីប៉ាស៊ីហ្វិកដើម្បីទំនួលខុសត្រូវក្នុងការការពារ គឺជាមជ្ឈមណ្ឌលប្រចាំតំបន់តែមួយគត់ដែលមានការប្តេជ្ញាខ្ពស់ក្នុងការពង្រឹងគោលការណ៍ស្តីពីទំនួលខុសត្រូវក្នុងការការពារ និងកសាងសមត្ថភាព ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ មជ្ឈមណ្ឌលនេះ គឺជាគំនិតផ្តួចផ្តើមរួមគ្នានៃក្រសួងការបរទេស និងពាណិជ្ជកម្ម រដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី និងសកលវិទ្យាល័យ Queensland ប្រទេសអូស្ត្រាលី។

# សូមចូលរួម!

ក្លាយជា**សមាជិក** www.responsibilitytoprotect.org/join-the-coalition

- ចុះឈ្មោះសម្រាប់ listserv របស់យើង៖ www.responsibilitytoprotect.org/subscribe
- ស្វែងរកយើងនៅលើ Facebook៖ www.facebook.com/icrtop
- តាមដានយើងនៅលើ Twitter៖ www.twitter.com/icrtop
- អាន blog របស់យើង៖ www.icrtopblog.org
- **គាំទ្រការងាររបស់យើង**៖ www.responsibilitytoprotect.org/donate

សម្រាប់ព័ត៌មានបន្ថែមអំពីសម្ព័ន្ធ និងសមាជិកសម្ព័ន្ធអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ (ICRtoP) សូមចូលកាន់វែបសាយត៍របស់យើង៖ **www.responsibilitytoprotect.org**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
**សម្ព័ន្ធអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ (ICRtoP)**
708 Third Avenue, Suite 1715, New York, NY 10017
ទូរស័ព្ទ៖ +១-៦៤៦-៤៦៥-៨៥២៣ ទូរសារ៖ +១-២១២-៥៩៩-១៣៣២
អ៊ីមែល៖ info@responsibilitytoprotect.org
វែបសាយត៍៖ www.responsibilitytoprotect.org

## សេចក្តីថ្លែងអំណរគុណ

សម្ព័ន្ធអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ សូមថ្លែងអំណរគុណដល់បុគ្គល និងអង្គការដូចខាងក្រោមដែលបានជួយគាំទ្រ និងផ្តល់ការណែនាំក្នុងអំឡុងពេលបង្កើតបណ្តុំឧបករណ៍នេះ៖ Nana Afadzinu និងសហសេវិករបស់គាត់នៅវិទ្យាស្ថានសង្គមស៊ីវិលអាហ្វ្រិកខាងលិច សាស្ត្រាចារ្យ Alex Bellamy, TibiGalis, Rachel Gerber បណ្ដាញសិទ្ធិមនុស្សប្រទេសអ៊ុយហ្គង់ដា បណ្ឌិត Noel Morada, Willaim Pace បណ្ឌិត Sheri Rosenberg និងសហសេវិករបស់គាត់នៅសាលាច្បាប់ Benjamin N. Cardozo បណ្ឌិត Monica Serrano, Laura Spano មូលនិធិ Stanley, Shrah Teitt ចលនាសហព័ន្ធពិភពលោក-វិទ្យាស្ថានគោលនយោបាយសកល បណ្ឌិត Robert Zuber និង Alex Zucker។

## ភាពជាដៃគូសកល

សម្ព័ន្ធអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រប្រកបដោយសប្បុរសធម៌ ដែលផ្តល់ដោយដៃគូ និងម្ចាស់ជំនួយទាំងអស់របស់ខ្លួនមកពីជុំវិញពិភពលោក។ មូលនិធិចម្បងត្រូវបានផ្តល់ដោយ Arsenault Family Foundation, HermodLannungs Fond, John D. និង Catherine T. MacArthur Foundation និង Oak Foundation ព្រមទាំងរដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី ហូល្លង់ និងស៊ុយអែត និងម្ចាស់ជំនួយជាលក្ខណៈបុគ្គលមួយចំនួន។

សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបដែលអ្នកអាចគាំទ្រការងាររបស់យើង សូមចូលកាន់វែបសាយត៍របស់យើងនៅ www.responsibilitytoprotect.org/donate ឬទាក់ទងមកកាន់យើងខ្ញុំ តាមរយៈលេខ +១.៦៤៦.៤៦៥.៨៥២៧ ឬ development@responsibilitytoprotect.org។

បណ្ដុំឧបករណ៍នេះអាចសម្រេចទៅបានដោយសារមានការឧបត្ថម្ភដ៏ថ្លៃថ្លាពីក្រសួងការបរទេស និងពាណិជ្ជកម្មនៃរដ្ឋាភិបាលអូស្ត្រាលី និងក្រសួងការបរទេសនៃប្រទេសហុល្លង់។ ខ្លឹមសារនៃអត្ថបទបោះពុម្ពផ្សាយនេះ គឺជាទំនួលខុសត្រូវទាំងស្រុងរបស់សម្ព័ន្ធអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ និងមិនត្រូវបានបកស្រាយដើម្បីឆ្លុះបញ្ចាំងទស្សនៈរបស់ម្ចាស់ជំនួយ ឬដៃគូណាមួយឡើយ។

រដ្ឋាភិបាលអូស្ត្រាលី

ក្រសួងការបរទេស និងពាណិជ្ជកម្ម

ក្រសួងការបរទេសនៃប្រទេសហូល្លង់

AP R2P

Asia Pacific Centre for the Responsibility to Protect

ICRtoP

INTERNATIONAL COALITION FOR **THE RESPONSIBILITY TO PROTECT |**
សម្ព័ន្ធអន្តរជាតិដើម្បីទំនួលខុសត្រូវក្នុងការការពារ

708 Third Avenue, Suite 1715, New York, NY 10017
ទូរស័ព្ទ៖ +១-៦៤៦-៤៦៥-៨៥២៣ ទូរសារ៖ +១-២១២-៥៩៩-១៣៣២
info@responsibilitytoprotect.org
www.responsibilitytoprotect.org